គណៈកម្មការទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ១ ខែមករា

ព.ស. ២៥០៣ គ.ស. ១៩៦១

ភ្នំពេញ

# ដំណឹងគួរសោកស្ដាយ

ព្រះតេជព្រះគុណ ព្រះសាសនមុនី មាស-គង់ ចៅអធិការវត្ត ពិភទ្ធរង្សី (ចិនដំដែក) សង្កាត់លេខ ២ ក្រុងភ្នំពេញ, ពជាគណៈថ្នាក់ទោ បានទទួលអនិច្ចធម្មនៅថ្ងៃសៅរ៍ ២ រោចខែកត្តិក ឆ្នាំជូតទោស័ក ព.ស. ២៥០៣ (៥ វិច្ឆិកា ១៩៦០) ដោយរោគជរា ។

ក្រុមសិស្សានុសិស្សនិងក្រុមញាតិមិត្ត ទាំងបព្វជិតទាំងគ្រហស្ថ បាន តម្កល់សពរបស់លោកទុកអស់រយៈវេលា ៣ ខែ ១៧ថ្ងៃ ដើម្បីធ្វើទក្ខិណានុប្បទាន ឧទ្ទិសកុសលប្រគេនចំពោះវិញ្ញាណក្ខន្ធរបស់លោក ។

នៅថ្ងៃសៅរ៍–អាទិត្យ–ច័ន្ទ–អង្គារ ៤–៥–៦–៧ កើត ខែផល្គុណ ឆ្នាំជូតទោស័ក ព.ស. ២៥០៣ (១៨_១៩-២០ និង ២១ ខែកុម្ភៈ១៩៦១) ក្រុមសិស្សានុសិស្ស និងក្រុមញាតិមិត្តទាំងបព្វជិតទាំងគ្រហស្ថ បាន ធ្វើបុណ្យឈាបនកិច្ច តាមប្រពៃណីនៃព្រះពុទ្ធសាសនា យ៉ាងអធិកអធម ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ មានសេចក្ដីវិយោគសោកស្ដាយពន់ពេក ដោយព្រះតេជព្រះគុណអង្គនេះ ជាបណ្ឌិតប្រកបដោយឧត្ដមគតិមួយរូប ខាងផ្នែកព្រះពុទ្ធសាសនា ។ ការអនិច្ចធម្មរបស់ព្រះតេជព្រះគុណអង្គនេះ ឈ្មោះថាខាតបង់អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាមួយរូបយ៉ាងធំធេង ។

ជូន

F278

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

### ផ្នែកសាសនា


- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង - ខាត់ រៀបរៀង . . . . . ១
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ - ប៊ូ រៀបរៀង. . . . ១៧
- ខុទ្ទសភិហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី - ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ - ឈិន ពិនិត្យ . . . . . . . . . . ៣១
- មហោសថជាតក (តមក) លោក អ៊ុម - ភន ចម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម - តួរ ពិនិត្យ . . . . . . . . . . . ៣៩


### ផ្នែកអក្សរសាស្ត្រ


- វប្បធម៌ខ្មែរ លោក លី - ធាមតេង រៀបរៀង . . ៤៩
- ពាក្យខ្មែរ ប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ៥៧
- វចនានុក្រម សំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង - ខាត់ រៀបរៀង . . ៥៩
- រឿងសាមកុក (តមក) ឧកញ៉ា នូ - កន់ ប្រែ . . ៦០
- ល្បែងគៀវ លោក ញុង - សឿង រៀបរៀង . . ៧០
- រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរ លោក ប្រ៊ុម - ទឹម រៀបរៀង ៨១


### ផ្នែកកំណត់ហេតុនិងប្រវត្តិការណ៍


- ពិធីអនុសាវរីយ៍មហាសន្និបាតនៃអន្តរសង្ឃលើកទី១៧ . . . . . . . . ៩២
- ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ . . . , . . ១០៩


មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃផ្សារ ២៣០ ០០

33e Année — No 1 — Janvier 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire, publiée par l'Institut - Bouddhique de Phnom-Penh.

## Sommaire

### Partie religieuse

Pages


- La Vie du Buddha (suite) par Vèn - *PANG KHAT* . . . . . 1
- Prah Abhidhammapitaka, Kampi Preah Kathavathu (suite) par *M. BOU - FO* . . . . . 17
- Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . 31
- Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu etcorrigé par Vèn. *KEM - TO* . . . 39


### Partie litétraire


- La Culture Khmère par *M. LY - THEAM - TENG* . . . . . 49
- Activités de la Commission Culturelle . . . . . . . . . . . . . . . 57
- Dictionnaire Sanscrit-Khmèr (suite) par *VÉN . PANG - KHAT* . . 59
- Histoire de Sam-Kok (suite) traduite par Oknha *NOU - KAN* . . . . . . 61
- Le jeu de "Eav" par *M. NHOUNG - SŒUNG* . . . . . 70
- La fondation d'Angkor d'après une légende khmère par *M. NHEM - KHEM* . . . . . 81


### Notes et chroniques


- Le 17ème Congrès des Dignitaires religieux . . . . . . . . . . 92
- Cérémonie d'ensvelissement des cendres de *S.M. PRÉAH MOHA KANCHANAKAUD* . . . . . 109


Prix d'abonnement annuel (comprenant 12 numéros): 23oloo

ផ្នែកសាសនា

## ពុទ្ធជីវប្បវត្តិ

(តមក)

ព្រះមហាប៉ាង-ខាត់ រៀបរៀង

## អវិទូរេនិទាន ពុទ្ធបូជាកថាទី៣

១- សេចក្ដីប្រាថ្នានាងសុជាតា, ២- ទ្រង់ឧបមាសុបិន ៥ យ៉ាង, ៣- នាងសុជាតាថ្វាយមធុបាយាស, ៤- ទ្រង់សោយមធុបាយាស, ៥ ពុទ្ធដំណើរទៅកាន់ពោធិមណ្ឌល ។

### ១- សេចក្ដីប្រាថ្នានាងសុជាតា

មាននាងនារីកាម្នាក់ឈ្មោះ សុជាតា កើតក្នុងត្រកូលសេនកុដុម្ពីនៅក្នុងសេនានិគម ឧរុវេលាប្រទេស កាលនាងមានវ័យវឌ្ឍនាចំរើនឡើង នាងបានធ្វើសច្ចប្រណិធានចំពោះទេវតា ដែលអាស្រ័យនៅនិគ្រោធព្រឹក្សធំមួយដើមថា "ខ្ញុំម្ចាស់សូមឲ្យបានស្វាមីប្រកបដោយបុញ្ញសម្បត្តិ ហើយឲ្យបានបុត្រប្រុសនៅក្នុងបឋមគភ៌, បើខ្ញុំម្ចាស់បានសម្រេចសេចក្ដីប្រាថ្នា ក្នុងកាលណា, ខ្ញុំម្ចាស់នឹងធ្វើពលិកម្មបូជាដែលមានតម្លៃមួយសែនកហាបនៈ ក្នុងកាលនោះ" ។ ចំណេរកាលមក នាងសុជាតាបានសម្រេចសមតាមសេចក្ដីប្រាថ្នា នាងរៀបចំពលិកម្មបូជាទេវតា ដោយមធុបាយាសនៅថ្ងៃ១៥ កើតខែពិសាខ ។

មានសេចក្ដីដំណាលថា មធុបាយាសនេះអស្ចារ្យចំឡែកណាស់

នាងសុជាតាធីតាសេនកុដុម្ពី បានឲ្យយកមេគោ១.០០០ទៅឃ្វាលនៅព្រៃរលឹះឈើឯម ហើយនាងរូតយកទឹកដោះពីមេគោ ៥០០ ក្នុងចំនួនមេគោទាំង ១.០០០ នោះ ទៅឲ្យមេគោ៥០០ផឹក; រូតយកទឹកដោះពីមេគោ២៥០ ក្នុងចំនួនមេគោ៥០០នោះ ទៅឲ្យមេគោ ២៥០ ផឹកហើយបន្ថយយ៉ាងនេះ ហូតទៅដល់មេគោ ៨ ។ នាងសុជាតាធ្វើដូច្នេះ ប្រាថ្នាឲ្យទឹកដោះគោមានខ្លាញ់សផ្អែមដ៏ក្រៃលែង ។ ពេលរូតទឹកដោះគោ ក៏មានអស្ចារ្យចំលែកហូរចុះ គាន់តាជន៍មិនចាំបាច់យកដៃរូត ពេលចំអិនមធុបាយាស ក៏មានអស្ចារ្យ ពពុះទឹកដោះហូរវិលជាទក្ខិណាវដ្ដ ដើងក្រានមិនមានផ្សែង ពួកទេពតាយកខ្លាញ់សមកបង់ក្នុងតាជន៍មធុបាយាសនោះ ។ នាងសុជាតាឃើញហេតុអស្ចារ្យដូច្នោះ មានចិត្តត្រេកអរក្រៃលែង ហើយប្រើនាងបុណ្ណទាសីថា "នាងចូរទៅបោសជម្រះនៅក្រោមដើមនិគ្រោធឲ្យស្អាតបាត" ។

## ២-ទ្រង់មហាសុបិន ៥ យ៉ាង

ក្នុងរាត្រីយប់ ១៤ កើតខែពិសាខនោះ ព្រះបរមពោធិសត្វទ្រង់មហាសុបិន ៥ ប្រការ ដែលជាបុព្វនិមិត្តអស្ចារ្យ ជាហេតុនាំឲ្យទ្រង់ជ្រាបថាទ្រង់នឹងបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា(១)

---

១ អង្គុត្តរនិកាយ បញ្ចកនិបាតសៀ.៤៥ ទំព័រ ២២៤ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ មុនពីការត្រាស់ដឹង មានមហាសុបិន៥យ៉ាង កើតប្រាកដឡើង ។ មហាសុបិន ៥ យ៉ាងនោះ តើដូចម្តេច ?

១-ម្នាលភិក្ខុទាំងឡាយ! មហាប្រឹថពីនេះ ជាសំណឹងដ៏ប្រសើរ ស្តេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្តូកចុះក្នុងសមុទ្រខាងកើត ព្រះហស្តស្តាំសណ្តូកចុះក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្តូកចុះក្នុងសមុទ្រខាងត្បូង,

២-ម្នាលភិក្ខុទាំងឡាយ ! មានស្មៅចិញ្ចៀនមួយសរសៃផុះលេចពីផ្ចិតទៅទល់នឹងអាកាស,

៣- ម្នាលភិក្ខុទាំងឡាយ! មានដង្កូវខ្លួនសក្បាលខ្មៅវារចេញពីព្រះបាទទាំងគូ (ចាប់ដើមពីចុងក្រចក) ចោមរោមជិតជិវាបដល់មណ្ឌលនៃជង្គង់,

៤-ម្នាលភិក្ខុទាំងឡាយ មានបក្សី៤ពួក មានសម្បុរផ្សេងៗគ្នា ហើរមកពីទិសទាំង ៤ មកក្រាបចុះទៀបបាទមូល

ក៏ត្រឡប់ជាសម្បុរសទាំងអស់ទៅវិញ,

៥ - ម្នាលភិក្ខុទាំងឡាយ តថាគតបង្រ្កមលើភ្នំលាមកធំ មិនប្រឡាក់ដោយលាមកឡើយ ។

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ១ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ដែលតថាគតត្រាស់ដឹងហើយ,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ២ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលតថាគតត្រាស់ដឹងហើយ ត្រាតែទេវតា និងមនុស្សទាំងឡាយប្រកាសបានដោយប្រពៃ,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៣ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវគុណ ដែលពួកគ្រហស្ថច្រើន ស្លៀកពាក់គ្រឿងប្រដាប់មានពណ៌ស ដល់នូវតថាគតជាសរណៈស្មើដោយជីវិត,

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៤ ប្រាកដឡើង ដើម្បី

ត្រាស់ដឹងនូវគុណ ដែលវណ្ណៈទាំង ៤ នេះគឺ ខត្តិយៈ ១ ព្រាហ្មណៈ ១ វេស្សៈ ១ សូទ្ទៈ ១ ចេញចាកផ្ទះមកបួសក្នុងធម៌វិន័យដែលតថាគតសំដែង ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ។

ម្នាលភិក្ខុទាំងឡាយ! មហាសុបិនទី ៥ ប្រាកដឡើង ដើម្បីត្រាស់ដឹងនូវគុណ ដែលតថាគត ជាបុគ្គលមានលាភ គឺបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយបរិក្ខារ តែតថាគតមិនជាប់ជំពាក់ មិនជ្រប់សុបសៅ ក្នុងលាភទាំងនោះឡើយ មានការឃើញនូវលាភនោះថាជាទោស មានបញ្ញាជាគ្រឿងរលាស់ចេញ ទើបបរិភោគ ។

ម្នាលភិក្ខុទាំងឡាយ! កាលតថាគតអរហន្តសម្មាសម្ពុទ្ធនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនពីការត្រាស់ដឹង មហាសុបិនទាំង ៥ នោះ ក៏បានកើតប្រាកដឡើង ។

## ៣–នាងសុជាតាថ្វាយមធុបាយាស

*ព្រះមហាបុរសរត្ន បានបំពេញទុក្ករកិរិយាគម្រប់ ៦ វស្សាហើយ ថ្ងៃ ១៥កើតខែពិសាខឆ្នាំរកា វេលាព្រឹក ទ្រង់ពុទ្ធដំណើរទៅប្រថាប់ក្រោមនិគ្រោធព្រឹក្ស ញុំាងសកលមណ្ឌលនិគ្រោធព្រឹក្សឲ្យភ្លឺរុងរឿងដោយរស្មី*

ដែលផ្សាយចេញពីព្រះសរីរកាយ ។ នាងបុណ្ណទាសីទៅបោសសំអាតទីឋាននោះ ឃើញព្រះបរមពោធិសត្វគង់បែរព្រះភក្ត្រ ទៅកាន់ទាបទិស មានរស្មីព្រោងព្រាយដូចមាស ក៏គិតថា ថ្ងៃនេះ ទេពតានិគ្រោធព្រឹក្ស ចុះមកចាំទទួលពលិកម្មហើយ នាងមានសេចក្តីត្រេកអរក្រៃលែង ក៏ប្រញាប់ប្រញាល់យកសេចក្តីនេះទៅប្រាប់នាងសុជាតាវិញ ។ នាងសុជាតាបានស្តាប់ពាក្យនាងបុណ្ណទាសីហើយ មានបីតិសោមនស្សណាស់និយាយទៅកាន់នាងបុណ្ណទាសីវិញថា បើដំណឹងនេះជាសេចក្តីពិត យើងនឹងតាំងនាងឲ្យជាធីតានៃយើង ។ លុះចំអិនមធុបាយាសរួចស្រេចហើយ នាងសុជាតា មាននាងបុណ្ណទាសីជាគ្នា ទូលមធុបាយាស ធ្វើដំណើរទៅកាន់និគ្រោធមូលដែលជាទេពល័យនោះ នាងបានឃើញព្រះមហាបុរសនោះ នឹកស្មានថា ទេពតានិគ្រោធព្រឹក្ស មានចិត្តសោមនស្សក្រៃលែង បង្អោនកាយ ដើរចូលទៅកាន់ព្រះបរមពោធិសត្វ ហើយលើកភាជន៍មធុបាយាសដាក់ថ្វាយលើព្រះហស្ត ។ ព្រះមហាបុរសបើកនេត្រាទតនាងសុជាតា, នាងសុជាតា ដឹងអាការដូច្នោះហើយ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំម្ចាស់ថ្វាយមធុបាយាស ព្រមទាំងភាជន៍មាសនេះផង ហើយក្រាបទូលតទៅទៀតថា សេចក្តីប្រាថ្នានៃខ្ញុំម្ចាស់បានសម្រេចបរិបូណ៌ហើយ ទើបនាងសុជាតា វិលត្រឡប់ទៅកាន់គេហដ្ឋាន

ខ្លួនវិញ ដោយសេចក្ដីត្រេកអរក្រៃលែង ។

## ៤– ទ្រង់សោយមធុបាយាស

លុះព្រះបរមពោធិសត្វបានទទួលមធុបាយាសហើយ ទ្រង់ក្រោកចាកនិគ្រោធព្រឹក្ស ធ្វើពុទ្ធដំណើរទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ចុះស្រង់ទឹករួចហើយ ទើបស្ដេចនិសីទនាការទៀបឆ្នេរស្ទឹង បែរព្រះភ័ក្ត្រទៅកាន់បូព៌ទិស ទ្រង់ពូតបាយាសជាដុំតូចៗ ប៉ុនផ្លែត្នោត ចំនួន ៧ដុំតូច ៧ ដង ជា ៤៩ដុំតូច ហើយទ្រង់ធ្វើភត្តកិច្ចអស់ឥតសេសសល់ សមគួរនឹងពាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ៤៩ថ្ងៃដោយបរិបូណ៌ ។ ធ្វើភត្តកិច្ចរួចហើយ ព្រះមហាបុរសរត្ន កាន់យកភាជន៍នៃមធុបាយាស ទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ទ្រង់អធិដ្ឋានថា បើតថាគត បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ សូមឲ្យភាជន៍នេះអណ្ដែតច្រាសខ្សែទឹក អធិដ្ឋានហើយ ស្ដេចបណ្ដែតភាជន៍លើខ្ទកធាក ។ ខណៈនោះ ភាជន៍មាសនោះ ហាក់ដូចមានចិត្តសំដែងអាការដូចសុវណ្ណហង្ស អណ្ដែតលឿនលយ ច្រាសខ្សែទឹកទៅឆ្ងាយប្រមាណ ៨០ ហត្ថ ទើបលិចចុះ ត្រង់ទៅវិមានកាឡនាគរាជ ទៅប៉ះទង្គិចនឹងភាជន៍នៃអតីតពុទ្ធទាំង ៣ អង្គ ឮសូរគិរ ៗ ហើយចុះទៅប្រតិស្ឋាននៅខាងក្រោមភាជន៍នៃអតីតពុទ្ធទាំងឡាយនោះ ។ កាលនោះ កាឡនាគរាជកំពុងនិទ្រាលក់ និមិត្តតែឮសំឡេងគិរៗនេះហើយ ភ្ញាក់

ទៀតពោលពាក្យថា ថ្ងៃនេះ មានព្រះពុទ្ធមួយអង្គត្រាស់ដឹងទៀតហើយ ពីថ្ងៃមុន មានព្រះពុទ្ធមួយព្រះអង្គត្រាស់រួចទៅហើយ ក៏មានចិត្តត្រេកអរក្រៃលែង ហើយទៅកាន់ទីប្រតិស្ឋានកាជន៍ ពោលសរសើរពុទ្ធគុណជាអនេកប្រការ ។

ឯព្រះបរមពោធិសត្វ ទតព្រះនេត្រឃើញកាជន៍ អណ្តែតច្រាសទឹកដោយសេចក្តីអស្ចារ្យយ៉ាងនេះហើយ ទ្រង់អស់សង្ស័យ នឹកក្នុងព្រះទ័យថា អាត្មាអញនឹងបានត្រាស់ដឹងសម្មាសម្ពោធិញាណពិតប្រាកដ ហើយស្តេចវិលត្រឡប់ចូលទៅកាន់សាលវ័ន ដែលកំពុងតែរីកផ្កាស្គុសស្គាយក្រអូបឈ្ងុយឈ្ងប់ ទ្រង់សម្រេចសម្រាន្តអិរិយាបថក្នុងទិវាវិហារក្រោមសាល-ព្រឹក្សមួយដើម ។ សាយណ្ហសម័យ ព្រះពាយបក់ក្លិនផ្កាក្រអូបផ្សាយពេញអរញ្ញមណ្ឌលសន្ទឹករលកាលគាល្វ៍ មានសាខាទោរទន់ បក់រវិចដោយរំយោលបក់រំកើយ ហើយត្រសៀក ហាក់ដូចជាមានចិត្តវិញ្ញាណក្រាបនមស្ការ ជាសក្តៀនដង្ហោយហៅ សូមនិមន្តទៅត្រាស់ដឹងឆាប់ទៅ ព្រះបរមពោធិសត្វ ស្តេចលីលាឆ្ពោះព្រះភ័ក្ត្រទៅកាន់ពោធិមណ្ឌល ។

## ៥-ពុទ្ធដំណើរទៅកាន់ពោធិមណ្ឌល

ព្រះបរមពោធិសត្វ ប្រកបដោយសិរីសម្បត្តិដ៏ប្រសើរ ទ្រង់ពុទ្ធដំណើរសីហនាទគគាតឥតក្តីគាមមគ្គវិថី មានព្រាហ្មណ៍ម្នាក់ឈ្មោះ

សោត្ថិយ បានស្បូវ ៨ ក្ដាប់យកទៅថ្វាយ ទ្រង់ទទួលហើយ យាត្រាឆ្ពោះទៅកាន់ពោធិមណ្ឌល ដល់ហើយទ្រង់ប្រទក្សិណអស្សត្ថព្រឹក្ស ៣ ជុំ ទើបស្ដេចក្រាលស្បូវនោះខាងទក្ខិណទិសាភាគនៃពោធិព្រឹក្ស ឯផែនពសុធាក៏កម្បនាការសំដែងអាការហាក់ដូចជាក្រាបទូលថា ទីនេះមិនមែនជារតនបល្ល័ង្កទេ ស្ដេចលើកទៅក្រាលខាងបច្ឆិមទិសាភាគ តទៅខាងឧត្តរទិសាភាគទៀត ទិសទាំង ២ នេះ ក៏សំដែងកម្បនាការដូចគ្នាទៀត ទីបំផុតទើបស្ដេចលើកទៅក្រាលខាងបុព្វទិសាភាគ នៃពោធិព្រឹក្ស ផែនពសុធាក្រឡាប្រឹថពីតាំងនៅស្ងៀម ហាក់ដូចជាក្រាបទូលថា ទីនេះជារតនបល្ល័ង្កហើយ ក៏ទ្រង់សម្រេចនិសីទនាការ ពត់ព្រះភ្នែនពែនព្រះបាទដ៏ស្អាត បែរព្រះប្រឹស្ដាង្គទៅកាន់ពោធិមូល បែរព្រះភ័ក្ត្រទៅកាន់បុព្វទិស ហើយតាំងសច្ចាធិដ្ឋានដ៏មាំថា (១)

កាមំ តចោ ចន្ហារុ ច អដ្ឋិ ច អវសិស្សតុ
សរីរេ មំសលោហិតំ ឧបសុស្សតុ

សូមឲ្យនៅសល់តែស្បែក សរសៃនឹងឆ្អឹងចុះ តែឯសាច់ឈាមក្នុងសរីរៈទាំងមូលនេះ ចូលឲ្យរីងស្ងួតស្វិតក្រៀមក្រញង់ទៅ បើមិនបានត្រាស់ដឹងម្ដងនេះទេ អាត្មាអញមិនព្រមក្រោកចាកបល្ល័ង្កនេះឡើយ ,, ។

---

១– ឯកនិបាតជាតក ។

# អវិទូរេនិទាន មារវិជយកថាទី ៨

១-មារកេណ្ឌពល, ២-មារាធិរាជដណ្ដើមបល្ល័ង្ករត្ន, ៣-ទេវតាសរសើរបារមី ។

## ១-មារកេណ្ឌពល

ក្នុងសម័យនោះ ទេវបុត្តមារ(១) មានចិត្តបាបកំពុងស្វែងរកទោសព្រះបរមពោធិសត្វ លុះបានឮសំឡេងសាធុការពរនៃពួកទេវនិករដូច្នោះហើយ ក៏ក្រេវក្រោធក្រៃពេក គិតថា ព្រះសិទ្ធត្ថកុមារនេះ ប្រាថ្នាចង់ឲ្យផុតអំណាចនៃអាត្មាអញ បើដូច្នោះ គួរអាត្មាអញនឹងទៅបំផ្ចិចបំផ្លាញ កុំឲ្យកន្លងអំណាចអាត្មាអញបាន ក៏ឃោសនាកេណ្ឌពលយាត្រាទ័ពចេញទៅ ។ ឯសេនាមារនោះច្រើនណាស់ មីរដេរដាសរាប់ពុំបាន ខាងមុខ ខាងឆ្វេង ខាងស្តាំ ខាងក្រោយរហូតដល់កណ្តាប់ចក្រវាឡជាបំផុត ស្រែកហ៊ោរកញ្ជ្រៀវឮសូរកងរំពងទាំងផែនពសុធា ក៏រើករំពើកញាប់ញ័រសកលលោក ។ វសវត្តីមារ ឡើងកាន់ដំរីគិរីមេខល និមិត្តជាដៃច្រើនកាន់អាវុធបរពួកពលយាត្រាទ័ពចរចេញទៅ, គួរខ្លាចតក់ស្លុតរន្ធត់ក្រៃពេក ខ្លះពណ៌ខ្មៅ ខៀវ លឿង ក្រហម ខ្លះមានខ្លួនជាឧដ្ឋ ក្បាលជាសេះ, ខ្លះមានខ្លួនជាមនុស្ស ក្បាលជាខ្លា, ខ្លះមានក្បាលច្រើន ផ្សេងគ្នាជាអនេករាប់មិនបាន មកកំញើញព្រះពោធិសត្វ ។ ពួកទេវតាទាំងមួយម៉ឺនលោកធាតុ មានសក្កទេវរាជនឹងព្រះព្រហ្មជាប្រធាន ដែល

---

១ វសវត្តីមារ ។

ចូលមកកាន់ទីសមោសរសរសើរបារមី ធ្វើគ្រឿងសក្ការបូជាថ្វាយព្រះបរមពោធិសត្វ កាលណា សេនាមារលើកទ័ពចូលមកដោយជិតពោធិមណ្ឌលហើយ កាលនោះក៏បបួលគ្នាហោះព្រៀវប្រែទៅកាន់ទីស្ថានលំនៅសព្វខ្លួនវិញ ឥតមានទេវតាណាមួយ អាចហ៊ានស្ថិតនៅកំដរព្រះពោធិសត្វឡើយ, ស្តេចទ្រង់ប្រថាប់នៅទីនោះតែមួយព្រះអង្គឯង ៗ

មារពធិ៍ពជក្រែកបញ្ជាកងទ័ពថា នៃអ្នកនិរទុក្ខទាំងឡាយ ! សិទ្ធត្ថកុមារជាបុត្រព្រះបាទសុទ្ធោទនៈនេះ ឥតអ្នកណាមួយប្រៀបផ្ទឹមឲ្យត្រឹមស្មើឡើយ យើងទាំងឡាយនឹងចូលទៅតយុទ្ធពីមុខមិនបានទេ ត្រូវយើងចូលលុកពីខាងក្រោយវិញ ៗ ឯព្រះមហាបុរសស្តេចក្រឡេកទតទៅទីជុំវិញព្រះអង្គ មិនឃើញមានអ្នកណាមួយឡើយ សក្កទេវរាជកាន់ស័ង្ខជ័យ ព្រះមហាព្រហ្មកាន់ស្វេតច្ឆត្រ ហោះត្រឡប់ទៅកាន់វិមានវិញ ទេវតាទាំងឡាយ ក៏រត់ខ្ចាត់ខ្ចាយចោលព្រះអង្គអស់រលីង ស្តេចទតទៅឧត្តរទិសឃើញពួកពលសកលយោធាសេនាមារ លុកចូលមកមីរដេរដាសពាសពេញគ្រៀបគ្រាស្តេចទ្រង់នឹកក្នុងព្រះទ័យថា " អាត្មាអញឥតមានអ្នកណាមួយជាទីពឹងពំនាក់សោះ ក្នុងទីនេះមានតែបារមីទាំង ១០ ប្រការនេះជាបរិស័ទ បើដូច្នោះ គួរតែអាត្មាអញយកបារមីទាំង ១០ ប្រការនេះជាខែល ជាគ្រឿងសស្ត្រាវុធ ច្បាំងតតាំងពពួកពលស្តេចមារ នឹង

សេនាមារ កំចាត់បង់ឲ្យបរាជ័យ ចាលចាញ់គេជាដៃ ក្នុងគ្រាឥឡូវនេះ" ។

## ២- មារាធិរាជជំណេំមបល្ល័ង្ក

លំដាប់នោះ មហាបុរសត្រាស់ថា "ព្រះពោធិសត្វដែលមានបារមី បំពេញហើយ គ្រាប់បានបល្ល័ង្កនេះក្នុងថ្ងៃដែលបានត្រាស់ជាព្រះពុទ្ធ នែមារ! បើអ្នកបានបំពេញពុទ្ធការកធម៌មែន តើអ្នកណាជាសាក្សីអ្នក? មារាធិរាជឆ្លើយថា ពួកពលយើងទាំងអស់នេះ ជាបន្ទាល់សាក្សីយើង ! ថាហើយក៏លើកដៃចង្អុលទៅពួកពល ពេលនោះ ពួកពលសកលយោធា ទាំងអស់ក៏ឆ្លើយតបមកវិញ ឮសន្ធឹកគឹកកងរំពងបាក់ដូចជារហែកផែនដី ថា "យើងទាំងអស់គ្នានេះជាបន្ទាល់សាក្សី", មារាធិរាជក្រាបទូលតប ទៅវិញថា „សិទ្ធត្ថ? ថាបើអ្នកបានបំពេញបារមី ចុះអ្នកមានអ្នកណាជា បន្ទាល់សាក្សីឬទេ?" ព្រះមហាសត្វឆ្លើយតបមារវិញថា "បន្ទាល់សាក្សី អ្នក សុទ្ធតែជាបុគ្គលមានចេតនាដឹងថា អ្នកបានបរិច្ចាគទានជាដើម·, តែអាត្មាមិនមានបុគ្គលណាមួយ ដែលមានចេតនាជាបន្ទាល់សាក្សីទេ, ឯរឿងបរិច្ចាគទានក្នុងអត្តភាពឯទៀតៗនោះ យើងស្ទះទុកសិនចុះ យើង យកតែរឿងឲ្យទាន ក្នុងកាលដែលយើងកើតជា មហាវេស្សន្តរពោធិសត្វ យើងបានឲ្យទាន ១០៧ ដង, រឿងនេះមហាប្រថពីទាំងមូលនេះ ឥត មានចេតនាទេ តែអាចធ្វើជាបន្ទាល់សាក្សីយើងបាន, មានព្រះបន្ទូលរួច

ហើយ ទ្រង់ចង្អុលទៅត្រង់ផែនដី ហើយទ្រង់ត្រាស់ថា កាលយើងកើតជាមហាវេស្សន្តរពោធិសត្វ យើងបានឲ្យទាន ១០៧ ដង អ្នកជាបន្ទាល់សាក្សីបានដឹងឮមែនឬទេ ? មហាប្រថពីស្រែកឮសូរសន្ធឹកសន្ធាប់ខ្ទាំងក្រៃ លើសលែងសេនាមារទៅទៀត ឆ្លើយឮសំឡេងតែមួយថា បពិត្រព្រះសិទ្ធត្ថ ! យើងជាបន្ទាល់សាក្សីព្រះអង្គ, មហាទានដែលព្រះអង្គបានបរិច្ចាគហើយនោះជាឧត្តមទានមែន ៗ ដំរីគិរីមេខលនៃពួកមារ និមិត្តតែបានឮថា ទានព្រះមហាវេស្សន្តរពោធិសត្វ ក៏ស្ទុតជង្គង់ដល់ដី មារសេនាក៏រត់ខ្វាត់ខ្វាយប្រញាយទៅកាន់ទិសានុទិស , ឥតមានពលណាមួយទៅកាន់ផ្លូវមួយគ្នាពីនោក់ឡើយ បោលគ្រឿងសីសាភរណៈនិងនិវត្ថាភរណៈគ្រឿងអាវុធយុទ្ធភណ្ឌ ដេរដាសពាសពេញលើផ្ទៃប្រថពី យកជីវិតគេរៀងៗខ្លួន ៗ

## ៣_ទេវតាសរសើរបារមី

លំដាប់នោះ ទេវតា កាលឃើញពួកពលមារអន្តរធានដូច្នោះ ក៏ស្រែកថ្វាយពរសព្ទសាធុការថា: ព្រះសិទ្ធត្ថរាជកុមារ មានជ័យហើយៗ ៗ នាគគ្រុឌទាំងឡាយបន្លឺសំឡេងគឹកកងឡើង ទេពតាព្រហ្មបបួលគ្នាកាន់គ្រឿងសក្ការបូជាភីផ្កា ហោះហើរច្រៀវច្រៃ ចូលមកគាល់ព្រះមហា

ពោធិសត្វ ពោលសរសើរគុណបារមីថ្វាយពរគ្រប់ ៗ គាថា(១)

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ទេវគណា មហេសិនោ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ,
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោ ។

---
១ ឯកនិបាតជាតក ។

ប្រែថា កាលនោះ ពួកនាគទាំងឡាយ ជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកឃោសនាទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារមានសន្តានចិត្តបាប បរាជ័យហើយ!" ។

ឯគ្រុឌទាំងឡាយ ជាអ្នកស្វែងរកគុណធម៌ដ៏ធំ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកឃោសនាទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារពិតជាមានសន្តានចិត្តលាមកអាក្រក់ បរាជ័យហើយ!" ។

លំដាប់នោះ ពួកទេវតា ជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំទូលាយ ត្រេកអរក្រៃពេកនឹងជ័យជំនះ ស្រែកឱឃោសនាការទៀបពោធិមណ្ឌលថា "ឱហ្ន៎! ព្រះពុទ្ធអង្គ ទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារសន្តានចិត្តលាមក បរាជ័យហើយ!" ។

គ្រានោះ ពួកព្រហ្មជាអ្នកស្វែងរកប្រយោជន៍ដូចគ្នាដែរ ត្រេកអរក្រៃលែងនឹងជ័យជំនះ ស្រែកលាន់ឮសន្ធឹកគឹកកងរំពងក្រៃ ទៀបពោធិមណ្ឌថា "ឱហ្ន៎! ព្រះពុទ្ធអង្គ ទ្រង់ប្រកបដោយសិរីសួស្តី ព្រះអង្គមានជ័យហើយ! ឯមារមានសន្តានចិត្តអាក្រក់ក្រៃ បរាជ័យចាញ់ព្រះអង្គហើយ!" ។

ទេវតាទាំងឡាយ ទាំងមួយម៉ឺនលោកធាតុ បប្ដូលគ្នា កាន់គ្រឿងសក្ការបូជាមាលាផ្កាកម្រងគ្រឿងលាប ហោះហើរដេរដាសពាសពេញគ្រៀបគ្រាមូលមកបូជាព្រះមហាសត្វហើយស្ថិតនៅរៀងកាយ ។ កាលព្រះអាទិត្យ មិនទាន់អស្ដង្គតនៅឡើយ ព្រះមហាបុរសទ្រង់កំចាត់បង់នូវមារនឹងពលសេនាមារហើយ ពួកទេវតាទាំងឡាយ កំពុងបូជា ដោយគ្រឿងសក្ការៈ បោះផ្កាព្រោងព្រាត ធ្លាក់ដេរដាសពាសពេញនៅជិតពោធិមណ្ឌល ទ្រង់គង់ពត់ព្រះភ្នែនពែនព្រះបាទស្អាតបរិសុទ្ធ តាំងសមាធិបម្រុងឲ្យបានត្រាស់ក្នុងថ្ងៃនោះ ។

(នៅមានត)

## ព្រះអភិធម្មបិដក

## គម្ពីរព្រះកថាវត្ថុ

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

### ឧទ្ទិសកថា

(តមក)

---

អសង្ខារបរិនិព្វាយីនោះ បានដល់ព្រះអនាគាមីបុគ្គលកើតក្នុងជាន់សុទ្ធាវាសណាមួយ ប្រកបសេចក្ដីព្យាយាមមិនលំបាក ដល់នូវព្រះអរហត្ត ដោយសប្បាយឥតលំបាក យ៉ាងនេះឈ្មោះថា អសង្ខារបរិនិព្វាយី ។

៥ជ អនាគាមិផលំ បត្វា ឧទ្ធំសោតអកនិដ្ឋគាមី នោះ

បានដល់ព្រះអរិយបុគ្គលដល់នូវអនាគាមិផលក្នុងមនុស្សលោកនេះ អស់ជីវិតិន្ទ្រិយ៍ចាកមនុស្សលោកហើយ ទៅកើតក្នុងជាន់សុទ្ធាវាសទាំងបួន ចាប់ដើមអំពីជាន់អវិហាឡើងទៅ កើតក្នុងជាន់ណា មិនអាចដល់នូវព្រះអរហត្តក្នុងជាន់នោះទេ, លុះរលត់បញ្ចក្ខន្ធ ឡើងទៅកើតក្នុងជាន់អកនិដ្ឋ ដល់នូវព្រះអរហត្តយ៉ាងនេះ មាននាមថា ឧទ្ធំសោតអកនិដ្ឋគាមី ។

សកវាទី ព្រះអរហន្តលះកិលេសបានប៉ុន្មាន ? មានប៉ុន្មានពួក ?

បរវាទី – ព្រះអរហន្តលះកិលេសបានទាំងអស់ ឥតសល់កិលេសណាមួយទេ បើចាត់ដោយសង្ខេបមានពីរពួក គឺព្រះអរហន្តសុក្ខវិបស្សកៈមួយពួក ព្រះអរហន្តបានអភិញ្ញាប្រាំមួយនឹងបានវិជ្ជាបីមួយពួក, បើចាត់

ដោយពិស្តារមានមួយរយប្រាំបី (១០៨) ពួក ។

ព្រះអរហន្តឈ្មោះថាសុក្ខវិបស្សកៈនោះ ជាព្រះអរហន្តសម្រេចព្រះអរហត្ត កាត់បាបធម៌អស់អាសវៈក៏ពិតហើយ ប៉ុន្តែហោះហើរដើរឰដ៏អាកាសពុំបាន ដូចជាព្រះចក្ខុបាលត្ថេរ ។

ព្រះអរហន្តបានអភិញ្ញាប្រាំមួយ នឹងបានវិជ្ជាបីនោះ ហោះទៅឰដ៏អាកាសបាន ឮកប្បុព្វេនិវាសញ្ញាណឃើញ បានទិព្វចក្ខុនឹងទិព្វសោតដឹងចិត្តរបស់អ្នកដទៃ ធ្វើឫទ្ធិបានផ្សេង ៗ ដូចជាព្រះមហាមោគ្គល្លា-នត្ថេរជាដើម ។

ព្រះអរហន្តដែលចែកដោយពិស្តារមាន១០៨ពួកនោះ ដោយអំណាចនៃសទ្ធាធិក, បញ្ញាធិក នឹងបដិបត្តិបួនជាប្រធាន អ្នកប្រាជ្ញគប្បីសន្និដ្ឋានដោយន័យដែលវិសជ្ជនាមកនេះចុះ ។

កង្ខុធិសកថានេះ មានសេចក្តីថា សកវាទីសួរព្រះអរិយបុគ្គលថា : ព្រះអរិយបុគ្គលលះកិលេសបានដោយឯកទេសនោះ តើព្រះអរិយ-បុគ្គលមានឈ្មោះថា ឯកទេសអរិយបុគ្គលដែរឬទេ ? ។

បរវាទីអាចារ្យវិសជ្ជនាថា ព្រះអរិយបុគ្គលទាំងឡាយពុំមានឈ្មោះថា ឯកទេសអរិយបុគ្គលទេ ក្រនឹងវិសជ្ជនាឲ្យច្បាស់លាស់ ក្រនឹងស្តាប់ឲ្យចូលចិត្ត; ព្រោះថាគម្ពីរព្រះបរមត្ថមានខអត្ថស្សុខុមគម្ភីរភាពណាស់ ក្រ

ទាំងអ្នកស្តាប់ ក្រុទាំងអ្នកសំដែងទាំងពីរខាង ប៉ុន្តែបណ្ឌិតជាតិគប្បីធ្វើ មនសិការកំណត់ថា ជាព្រះពុទ្ធាធិប្បាយប្រោសប្រទានព្រះសទ្ធម្មទេសនា ហើយតាំងចិត្តគោរពចំពោះព្រះធម៌ដ៏ជាក្រសែព្រះពុទ្ធដីកា គ្រាន់បានជាធម្មសវនានុត្តរិយានិសង្ស នឹងប្រកបដោយផល អាចការពារនូវទុគ្គតិបានអស់សែននៃកប្ប ហេតុតែបានស្តាប់ព្រះសទ្ធម្មទេសនា សមតាមក្រសែព្រះពុទ្ធដីកាដែលត្រាស់ទុកក្នុងនុពទប្បាដិមោក្ខថា៖

សទ្ធម្មស្សវនំ សុត្វា សព្វញ្ញូ ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ ។

បុគ្គលណាបានស្តាប់ព្រះសទ្ធម្មទេសនា ក្នុងព្រះពុទ្ធសាសនានៃសម្តេចព្រះជិនស្រីសព្វញ្ញូសព្វញ្ញុពុទ្ធជាអម្ចាស់ទាំងពួង បុគ្គលនោះនឹងកន្លងបង់នូវទុគ្គតិ គឺមិនបានទៅកាន់ទុគ្គតិ អស់កាលដ៏យូរប្រមាណបានសែននៃកប្ប អានិសង្សដែលបានស្តាប់ព្រះសទ្ធម្មនោះ សម្តេចព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកយ៉ាងនេះ ។

**ធិសកថាចប់**

អនេញ្ជកថា

អរហា អនេញ្ជឋិតោ បរិនិព្វាយតីតិ អាមន្តា ។

ននុ អរហា បកតិចិត្តេ ឋិតោ បរិនិព្វាយតីតិ អាមន្តា ។

អរហា កិរិយាចិត្តេ ឋិតោ បរិនិព្វាយតីតិ ។

វារៈនេះ នឹងបានវិសជ្ជនាក្នុងអនេញ្ជកថាតទៅ ដំណើរសេចក្តីតាមព្រះបាលីថា ភគវា សម្តេចព្រះមានព្រះភាគ ដ៏ជាទីសេពគប់នៃទេវតានិងមនុស្សទាំងឡាយ កាលព្រះអង្គប្រទានព្រះសទ្ធម្មទេសនា ទុជិសកថាចប់ហើយ លំដាប់ពីនោះ ទ្រង់ត្រាស់ទេសនានូវអនេញ្ជកថាតទៅ តាំងជាសកវាទីនឹងបរវាទី ដូចន័យខាងដើមថា៖

សកវាទី អរហា អនេញ្ជឋិតោ បរិនិព្វាយតិ ព្រះអរហន្តអស់អាសវៈហើយ ឋិតនៅក្នុងអនេញ្ជធម៌ គឺតាំងនៅក្នុងភាពជាអ្នកពុំមានចិត្តញាប់ញ័រ ហើយទើបចូលកាន់ព្រះនិព្វានពិតមែនឬ ?

បរវាទី ទទួលថា អាមន្តា អើ! ព្រះអរហន្តឋិតនៅក្នុងអនេញ្ជធម៌ហើយ ទើបចូលកាន់ព្រះនិព្វានពិតមែន ។

សកវាទី– ននុ អរហា បកតិចិត្តេ ឋិតោ បរិនិព្វាយតិ ព្រះអរហន្តឋិតនៅក្នុងចិត្តជាប្រក្រតីហើយ ទើបចូលកាន់ព្រះនិព្វាន និងឋិតនៅក្នុងកិរិយាចិត្តហើយ ទើបចូលកាន់ព្រះនិព្វានពិតមែនឬ ?

បរាជ័ទី- អាមន្តា អើ! ពិតមែនដូចពាក្យអ្នកថាហើយ ។

សកវាទី វិបាកាតិតេ្ត បិតោ ព្រះអរហន្តបិតនៅក្នុងវិបាកចិត្តហើយ ទើបចូលទៅកាន់ព្រះនិព្វាន, បិតនៅក្នុងវិបាកអព្យាកតចិត្តហើយ ទើបចូលកាន់ព្រះនិព្វាន ពិតមែនឬទេ ?

បរាជ័ទី- ព្រះអរហន្តដែលនឹងចូលកាន់ព្រះនិព្វាននោះ រមែងបិតនៅក្នុងវិបាកចិត្ត, បិតនៅក្នុងវិបាកអព្យាកតចិត្តហើយ ទើបចូលកាន់ព្រះនិព្វាន ដូចពាក្យអ្នកថាពិតមែនហើយ ។

សកវាទី- ភគវា ចតុត្ថជ្ឈានា វុដ្ឋហិត្វា សម្តេចព្រះមានព្រះភាគជាម្ចាស់ កាលនឹងស្តេចចូលកាន់ព្រះនិព្វាន ព្រះអង្គចូលកាន់ចតុត្ថជ្ឈាន ចេញចាកចតុត្ថជ្ឈានហើយ ទើបចូលកាន់ព្រះនិព្វានមែនឬ? ឬថាព្រះអង្គចូលកាន់ព្រះនិព្វានក្នុងចន្លោះនៃចតុត្ថជ្ឈាន ?

បរាជ័ទី- ទទួលថា អាមន្តា អើ! មែនដូចពាក្យអ្នកថាហើយ សម្តេចព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលកាន់ព្រះនិព្វានក្នុងចន្លោះនៃចតុត្ថជ្ឈាននឹងបញ្ចមជ្ឈានគត្វា ក្នុងចន្លោះកណ្តាលនៃចតុត្ថជ្ឈាន នឹងបញ្ចមជ្ឈាននោះឯង ព្រះអង្គចូលកាន់ព្រះនិព្វាន; ករិវុត្តចិត្តេ បិតោ សម្តេចព្រះមានព្រះភាគ កាលនឹងស្តេចចូលកាន់ព្រះនិព្វាននោះ ព្រះអង្គបិតនៅក្នុងករិវុត្តចិត្តជាអព្យាក្រឹត មិនចាត់ជាកុសលជាអកុសលឡើយ ។

សព្វេ ហិ សត្តា មែនពិត សត្វទាំងឡាយទាំងពួងដែលកើតមកជាសត្វជាបុគ្គលមានជីវិតទាំងអស់ កាលនឹងស្លាប់នោះមិនដែលកន្លងភវង្គចិត្តទេ; ភវង្គបរិយោសានេ សត្តា សត្វទាំងឡាយធ្វើមរណ-កាលដោយចុតិចិត្ត ក្នុងទីបំផុតនៃភវង្គចិត្តដូចគ្នាទាំងអស់ ឯភវង្គចិត្តនេះមិនមែនជាចំណែកកុសល នឹងអកុសលទេ ភវង្គចិត្តនោះជាភ្នាក់ងារញុំាងជីវិតឲ្យរស់នៅតែប៉ុណ្ណោះ ដូចជាទឹកដែលមាននៅក្នុងជលាល័យគឺសមុទ្រ ទឹកនោះថាស្អាតជាប្រក្រតី; បើមានទឹកពណ៌ខៀវជាដើម ចូលមកលាយឲ្យវេលាណា ក៏ក្លាយជាទឹកមានពណ៌ខៀវទៅវិញ ទឹកនោះនឹងថាជាទឹកចាស់ក៏មិនបាន នឹងថាជាទឹកថ្មីក៏មិនត្រូវ ទឹកចាស់នោះ គឺជាទឹកថ្លា ប៉ុន្តែជាទឹកមានពណ៌ខៀវទៅវិញ ព្រោះហេតុទឹកឯទៀតចូលមកលាយឲ្យ ។ ឯភវង្គចិត្តនេះសោត នឹងចាត់ជាកុសលក៏ចាត់មិនបាន នឹងថាជាអកុសលក៏ថាមិនបាន ព្រោះភវង្គចិត្តនោះមិនមែនជាកុសល មិនមែនជាអកុសល គឺជាអព្យាក្រឹត បើចេតសិកខាងកុសលមកអាស្រ័យ ក៏ឈ្មោះថាកុសលចិត្ត បើអកុសលចេតសិកមកអាស្រ័យ ក៏ឈ្មោះថាអកុ-សលចិត្ត ។ ភវង្គចិត្តនេះ បើទោសមានអភិជ្ឈាជាដើម ចូលមកបៀតបៀនហើយ ក៏សៅហ្មងទៅ; អនភិជ្ឈាទិហិ គុណេហិ បើគុណទាំងឡាយគឺអនភិជ្ឈា សេចក្ដីមិនលោភជាដើម មកពាល់ត្រូវហើយ

កំថា ស្អាតបរិសុទ្ធផុតសៅហ្មង; ភវង្គចិត្តជាអព្យាក្រិត កាលបើគសិក មកអាស្រ័យនោះជាទោសជាគុណទៅ ភវង្គចិត្តនោះទំនុកបម្រុងតែគ្រង់ មិនឲ្យអស់ជីវិតប៉ុណ្ណោះ បានជាចិត្តជាប្រក្រតីដើម ៗ បកតិមនោ ហិ មែនពិត បកតិចិត្តនោះឯងឈ្មោះថាភវង្គចិត្ត កាលសត្វនឹងអស់ជីវិត ក៏អស់ដោយអំណាចភវង្គចិត្តឃ្លាតចាកទី (ចុតិ) ៗ ការសំដែងចិត្តនេះ កម្រនឹងពន្យល់ឲ្យឃើញច្បាស់បានណាស់; ហេតុនេះ សូមលើកឧទា-ហរណ៍មកបញ្ជាក់ដូចនាងឧបាសិកាម្នាក់ជាអ្នកមានសទ្ធា ជាទីពឹងពាក់ អាស្រ័យរបស់ព្រះមហាមិត្តត្ថេរ មានសេចក្តីដំណាលថា ៖

ថេរោ កិរ កាសកលេណេ បដិវសតិ បានឮមកថា ព្រះមហាមិត្តត្ថេរនោះ អាស្រ័យនៅក្នុងកសកលេណវិហារ ៗ តស្ស គោចរគាមេ ក្នុងស្រុកជាទីត្រាច់គោចរភិក្ខាចារនៃព្រះមហាមិត្តត្ថេរ នោះ មានមហាឧបាសិកាម្នាក់ ជាមនុស្សមានសទ្ធាជ្រះថ្លា បុត្តំ វិយ កត្វា ធ្វើព្រះមហាថេរនោះឲ្យដូចជាកូនប្រុសរបស់ខ្លួន ឧស្សាហ៍ប្រតិបត្តិ បំរើដោយចតុប្បច្ច័យ ៗ ឯកទិវសំ អរញ្ញំ គច្ឆតិ មានមួយថ្ងៃ មហាឧបាសិកាវៀបចំដំណើរនឹងចេញទៅព្រៃ ទើបហៅកូនស្រីមកផ្តាំថា អម្ម ម្នាលនាង ឯងចូរកុំធ្វេសប្រហែសនឹងការកុសល ចូរខំយកចិត្តទុក ដាក់ បុរាណតណ្ឌុលា អង្ករចាស់ម៉ែដាក់ក្នុងភាជន៍ឯណោះ ទឹកដោះ

សម្បុទឹកអំពៅនៅក្នុងទីឯណោះ ឯងចូរយកមកដណ្តាំបាយ រួចលាយជាមួយនឹងទឹកដោះទឹកអំពៅ នឹងសប្បិប្រគេនលោកម្ចាស់មហាមិត្តត្ថេរជាបងប្រុសរបស់ឯងផង សល់អំពីនោះឯងចូរបរិភោគជាអាហារទៅចុះ ។

នាងពីតាសួរមាតាថា កឹ ភុញ្ជិស្សសិ ចុះម៉ែនឹងបរិភោគនូវភោជនឯណា ? មហាឧបាសិកាប្រាប់ថា រត្តិយោ បក្កំ អញ្ញបរិភោគបាយកកដែលដណ្តាំសល់ពីល្ងាចមិញ ជាមួយទឹកជ្រក់រួចស្រេចហើយ ។ នាងពីតាសួរថា ទិវា កឹ ភុញ្ជិស្សសិ ចុះវេលាថ្ងៃម៉ែនឹងបរិភោគភោជនាហារឯណា? ។ មហាឧបាសិកាប្រាប់ថា សាកបណ្ណំ បក្ខិ-បិត្វា ឯងចូរដាក់ស្លឹកឈើដំដូរ បបរជាមួយនឹងអង្ករទុកឲ្យម៉ែ ។ វិលមកវិញ នឹងបរិភោគបបរនោះពេលថ្ងៃ; មហាឧបាសិកាផ្តាំពីតាស្រេចហើយ ក៏ទៅឯព្រៃតាមកិច្ចនៃខ្លួន ។

ចីរំ ចារុប្បេត្វា ចំណែកព្រះមហាមិត្តត្ថេរនោះ កាលមហា-ឧបាសិកាកំពុងតែនិយាយជាមួយកូនស្រី លោកក៏និមន្តចូលទៅដល់ផ្ទះហើយ បានឮមហាឧបាសិកាផ្តាំកូនស្រីដូច្នោះ ទើបឲ្យឱវាទខ្លួនឯងខ្លួនលោកថា តាវ កញ្ជិយេន ភុញ្ជិ បានឮថា មហាឧបាសិកាបរិភោគបាយកកជាមួយទឹកជ្រក់ពីព្រលឹម ហើយបរិភោគចុងអង្ករដែលផ្តាំឲ្យកូនស្រីបបរទុកឲ្យក្នុងពេលថ្ងៃត្រង់; ចំណែកខ្លួនអ្នកឯងគេប្រាប់ពីតាឲ្យចំអិន

គោជនាហារ យ៉ាងឧត្តមថ្លៃថ្លាណាស់; ព្រោះតែខ្លួនអ្នកឯងនេះ បានជាមហាឧបាសិកាមានកង្វល់ច្រើន ស្ទើរតែចេញទៅធ្វើស្រែចម្ការមិនរួច មហាឧបាសិកាខំធ្វើកុសលយ៉ាងនេះ ព្រោះតែចង់បានសម្បត្តិបីប្រការ គឺសម្បត្តិមនុស្ស សម្បត្តិសួគ៌ នឹងសម្បត្តិព្រះនិព្វាន ចុះខ្លួនអ្នកឯងអាចនឹងឲ្យសម្បត្តិទាំងបីប្រការដល់មហាឧបាសិកាបានដែរឬមិនបានទេ? បើខ្លួននៅប្រកបដោយរាគៈទោសៈនឹងមោហៈយ៉ាងនេះ មិនគួរនឹងបរិភោគអាហារបិណ្ឌបាតរបស់មហាឧបាសិកានេះទេ លុះតែប្រាសចាកកិលេសមានរាគៈជាដើម ទើបសមគួរនឹងបរិភោគបាន បត្តំ ថវិកាយ បក្ខិ-បិត្វា គិតដូច្នេះហើយ ក៏ប្រកបាត្រចូលក្នុងស្បោងបាត្រវិញ ដោះឡេវត្រឡប់ទៅឯកសកលេណវិហារ ដាក់បាត្រទុកក្រោមគ្រែហាលចីវរលើខ្សែស្បៀង ហើយអធិដ្ឋានតាំងចិត្តព្យាយាមថា "អរហត្តំ អបា-បុណិត្វា បើអាត្មាអញមិនបានសម្រេចព្រះអរហត្តទេ នឹងមិនលះបង់សេចក្តីព្យាយាមឡើយ" អធិដ្ឋានដូច្នេះហើយ ក៏តាំងចិត្តចំរើនវិបស្សនាកម្មដ្ឋាន បុរេភត្តំ ឯវ បានសម្រេចព្រះអរហត្តផលញាណ ក្នុងកាលជាបុរេភត្ត គឺពេលព្រឹកនោះ ជាព្រះមហាខីណាស្រពដ៏ប្រសើរក្នុងបវរ-ពុទ្ធសាសនា ។ រុក្ខាម្ហិ អធិវត្ថា ទេវតាដែលស្ថិតនៅដើមឈើ ក្បែរទ្វារគុហានោះ បន្លឺឧទានគាថាថា ឆមោ តេ បុរិសាជញ្ញ បពិត្រ

លោកម្ចាស់ឈ្មោះថាបុរិសាជានេយ្យ ខ្ញុំសូមថ្វាយបង្គំដល់លោកម្ចាស់ដ៏ជាជិនបុត្រ នមោ តេ បុរិសុត្តម បពិត្រលោកម្ចាស់អ្នកឧត្តមជាងបុរស ខ្ញុំសូមនមស្ការដល់លោកម្ចាស់, លោកម្ចាស់អស់អាសវៈហើយ ជាទក្ខិណេយ្យបុគ្គលគួរនឹងទទួលទក្ខិណាទាន បពិត្រព្រះករុណា អ្នកមានសីលាទិគុណដ៏បវរ តុម្ហាទិសានំ វត្វា ស្ត្រីជាកបានប្រគេនបិណ្ឌបាតទាន ដល់ព្រះមហាថេរទាំងឡាយដូចជាលោកម្ចាស់ នឹងផុតចាកទុក្ខជាប្រាកដឥតសង្ស័យឡើយ ។

ថេរោ ឧដ្ឋហិត្វា ព្រះមហាមិត្តត្ថេរលុះបានសម្រេចព្រះអរហត្តហើយ ទើបក្រោកពីអាសនៈចេញមកបើកទ្វារបន្ទប់សម្លឹងមើលកាល ក៏ដឹងថានៅជាវេលាភិក្ខាចារ មិនទាន់ហួសកាលបិណ្ឌបាតទេ ក៏ស្លៀកស្បង់ដណ្តប់ឧត្តរាសង្គៈ ឃុំសម្ពត់សង្ឃាដី កាន់បាត្រចូលទៅក្នុងស្រុក សម្បាបេត្វា ចំណែកជីតានៃមហាឧបាសិកា ក៏ចាត់ចែងខាទនីយៈភោជនីយាហារ តាមបណ្តាំមាតាស្រេចហើយ អង្គុយចាំមើលផ្លូវព្រះមហាថេរក្បែរទ្វារផ្ទះដោយសំគាល់ថា ព្រះមហាថេរនឹងមកដល់ឥឡូវនេះ ឃរទ្វារំ សម្បត្តេ ព្រះមហាមិត្តត្ថេរនិមន្តទៅដោយសន្សឹមឥន្ទ្រិយ៍ដល់ទ្វារផ្ទះ, ជីតានៃមហាឧបាសិកាចុះមកទទួលយកបាត្រ ឡើងទៅលើផ្ទះ ដាក់ភោជនាហារដែលខ្លួនចាត់ចែងទុកបម្រុងនោះ ពេញបាត្រហើយយកមកប្រគេន

ព្រះមហាថេរ ៗ ឆ្លើយអនុមោទនាថា សុខំ ហោតុ សេចក្តីសុខចូរ មានដល់នាង; រួចហើយនិមន្តត្រឡប់ទៅឯ កសកលេណវិហារវិញ ៗ

សកវាទី សួរតទៅទៀតថា ព្រះអរហន្តដែលស្ថិតនៅក្នុងអនេញ្ជធម៌ ហើយ បានឈ្មោះថាមានចិត្តប្រាសចាករាគាទិក្កិលេស ដែលត្រាំនៅក្នុង ខន្ធសន្តាន, ព្រះអរហន្តនោះ បង្អោនចិត្តទៅដើម្បីនឹងសំដែងឫទ្ធិមាន ប្រការផ្សេងៗបានដែរ ឬមិនបានទេ ?

បរវាទី- អាមន្តា អើ! អរិយា អនេញ្ជបិតោ ព្រះអរហន្ត ដែលស្ថិតនៅក្នុងអនេញ្ជធម៌ គឺមិនបានញាប់ញ័រដោយតណ្ហា មានៈនឹង ទិដ្ឋិនោះ រមែងសំដែងឫទ្ធិបានផ្សេងៗ តាមសេចក្តីប្រាថ្នា ៗ

សកវាទី- ពាក្យដែលអ្នកថា ព្រះអរហន្តមិនញាប់ញ័រដោយតណ្ហា មានៈនឹងទិដ្ឋិនោះ រមែងសំដែងឫទ្ធិបានផ្សេងៗដូច្នេះ ពាក្យនេះមិនសម នឹងពាក្យខាងចុងទេ; ពាក្យក្នុងព្រះសូត្រនោះថា ព្រះមហាមោគ្គល្លានត្ថេរ ជាអគ្គសាវកខាងឆ្វេង ពួកតិត្ថិយ៍ជួលចោរទាំងឡាយឲ្យទៅសម្លាប់ ចោរ ទាំងនោះទៅប្រុងសម្លាប់ក្នុងថ្ងៃទីមួយ នឹងទីពីរ សម្លាប់មិនបាន ព្រោះ លោកសំដែងឫទ្ធិហោះគេចចេញទៅ លុះដល់ថ្ងៃជាគម្រប់បី លោកមិន សំដែងឫទ្ធិ មិនហោះគេចចេញ លោកនៅឲ្យចោរសម្លាប់ ចោរទាំងនោះ វាយលោកនឹងដំបងឲ្យបែកបាក់ឆ្អឹងល្អិតល្អើចប៉ុនគ្រាប់អង្ករបាក់ ហើយ

លោកចូលឈានសមាបត្តិទៅគាល់សម្តេចព្រះបរមសាស្តា ក្រាបទូលលាទៅបរិនិព្វានក្នុងប្រទេសឈ្មោះកាឡសិលា; បើអាងថាព្រះអរហន្តស្ថិតនៅក្នុងអនេញ្ជធម៌ ហើយអាចសំដែងឫទ្ធិបានតាមចិត្តប្រាថ្នា, ចុះហេតុអ្វីបានជាព្រះមហាមោគ្គល្លានត្ថេរ មិនសំដែងឫទ្ធិផ្សេងៗឲ្យពួកចោរខ្លាចចេញទៅ ? បែរជានៅស្ងៀមឲ្យពួកចោរសម្លាប់បាន? ។ ពាក្យដែលអ្នកថាព្រះអរហន្តស្ថិតនៅក្នុងអនេញ្ជធម៌នោះ អាចសំដែងឫទ្ធិផ្សេងៗបាន ពាក្យនេះមិនស្របគ្នានឹងពាក្យដែលថា ព្រះមហាមោគ្គល្លានត្ថេរពួកចោរប្រហារឲ្យចូលកាន់ព្រះនិព្វាន ពាក្យមុននឹងពាក្យក្រោយមិនសមគ្នា អាជាធាហិ ឆិក្កហំ អ្នកចូរទទួលនូវទោសរបស់អ្នកដែលយើងសង្កត់សង្កិនចុះ ។

បរវាទី- ន ហេវំ វត្តព្វេ អ្នកកុំគប្បីថាដូច្នេះ មិនសមគួរទេ ធម្មតាព្រះអរហន្តដែលស្ថិតនៅក្នុងអនេញ្ជធម៌ហើយ ក៏រមែងសំដែងឫទ្ធិបានផ្សេង ៗ តាមប្រាថ្នា ; ខ្ញុំសូមសួរទៅអ្នកវិញ ចុះស្តេចនន្ទោបនន្ទនាគរាជនោះ ព្រះមហាមោគ្គល្លានត្ថេរទូន្មានឲ្យអស់ពុតកំណាចដោយសំដែងឫទ្ធិពាល់តែបានប្រគល់កាយថ្វាជីវិតដល់ព្រះរតនត្រ័យ តាំងនៅក្នុងសរណ.គមន៍មែនឬទេ ? ។

សកវាទី- អើ! អើចឹងមែនហើយ ការដែលព្រះមហាមោគ្គល្លានត្ថេរនឹងសំដែងឫទ្ធិទូន្មាននន្ទោបនន្ទភុជង្គនោះ ក៏អាស្រ័យសម្តេចព្រះមានព្រះ

ភាគ ទ្រង់ត្រាស់អនុញ្ញាត ជាដើមហេតុដែរ ។

ឯកស្មឹ គិរ សមយេ បានឮថា សម័យមួយ អនាថបិណ្ឌិក-មហាសេដ្ឋីស្តាប់ព្រះសទ្ធម្មទេសនាក្នុងសំណាក់នៃព្រះមានព្រះភាគ កាលចប់ព្រះសទ្ធម្មទេសនាហើយ ទើបនិមន្តសម្តេចព្រះបរមទសពលព្រមទាំងព្រះភិក្ខុសង្ឃប្រាំរយ ឲ្យទៅទទួលអាហារបិណ្ឌបាតទាន ក្នុងផ្ទះនៃខ្លួន អង្គសម្តេចព្រះបរមទសពល ក៏ទទួលអាពធនាដោយតុណ្ហីភាព ។ អនាថបិណ្ឌិកមហាសេដ្ឋី ថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ ។

តំ ទិវសំ បច្ចូសកាលេ ក្នុងវេលាបច្ចូសសម័យជិតភ្លឺថ្ងៃនោះ សម្តេចព្រះមានព្រះភាគចេញចាកមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលពួកវេនេយ្យសត្វទាំងពួង ដែលមានឧបនិស្ស័យក្នុងមុឺននៃលោកជាតុ ក៏ឃើញស្តេចនន្ទោបនន្ទនាគរាជមកជាប់នៅក្នុងសំណាញ់ គឺព្រះពុទ្ធ-ញាណ ទើបទ្រង់អាវជ្ជនាការពិចារណាតទៅទៀត ក៏ទ្រង់ជ្រាបច្បាស់ថា ព្រះមហាមោគ្គល្លាននឹងទូន្មាននាគរាជឲ្យអស់ពុតត្បុតបាន ហើយនឹងឲ្យស្ថិតនៅក្នុងព្រះត្រៃសរណគមន៍ផង លុះរាត្រីភ្លឺជ្រះស្រឡះហើយ ទើបត្រាស់នឹងព្រះអានន្ទឲ្យផ្តៀងព្រះសង្ឃប្រាំរយថា “តថាគតនឹងស្តេចទៅទទួលបិណ្ឌបាតក្នុងផ្ទះអនាថបិណ្ឌិកមហាសេដ្ឋី តាមនភាល័យប្រទេសវិថីទេវចារិក” ។ ព្រះអានន្ទត្ថេរ ក៏ផ្តៀងព្រះសង្ឃប្រាំរយអង្គតាមទ្រង់បង្គាប់ ។

តំ ធិវសំ សជ្ជយឹសុ ក្នុងថ្ងៃនោះ ពួកបរិស័ទនាគចាត់ចែងទីកន្ទែងផឹកស៊ុក ដើម្បីស្តេចនន្ទោបនន្ទនាគរាជ ។ ធិព្វតេ ឆបល្លង្កេ ធិសីធិត្វា គ្រានោះ នាគរាជទ្រង់គង់លើតេនបល្ល័ង្កជាទិព្យក្រោមបាំងស្វេតច្ឆត្រ មាននាគបរិស័ទហោមរោមជុំជិត នាគនារីច្រៀងរាំដេញដំប្រគំដូរ្យតន្ត្រីមានប្រការផ្សេង ៗ សម្លឹងមើលនូវទិព្យក្រយាហារដែលនាគបរិស័ទចាត់ចែងយកមកដម្កល់ទុកក្នុងទីនោះ ។

អដ្ឋខោ ភគវា គ្រានោះ សម្តេចព្រះមានព្រះភាគមានព្រះថេរណាស្រពសង្ឃជាច្រើន ប្រមាណប្រាំរយអង្គ ហោមរោមហែហម ហោះតាមផ្ទៃអាកាស ស្តេចនន្ទោបនន្ទនាគរាជមើលឃើញព្រះអង្គយ៉ាងណា ព្រះអង្គក៏ទ្រង់ឃើញយ៉ាងនោះ បែរព្រះភក្ត្រឆ្ពោះទៅស្ថានតាវត្តិង្សពិភព ។ គ្រានោះ ស្តេចនន្ទោបនន្ទនាគរាជគិតថា ឥមេ មុណ្ឌកា ស្រមណ៍ត្រងោលទាំងនេះ នឹងទៅឯតាវត្តិង្សពិភព ហោះរំលងលើក្បាលអញ ហាក់ដូចជារោយធូលីខាងឆ្វេងស្មាត្រូវក្បាលអញៗ នឹងធ្វើកិច្ចរាំងកុំឲ្យទៅរួច គិតហើយក៏ទៅឯជើងភ្នំព្រះសុមេរុរាជគិរី និរមិតសរីរៈឥន្ទ្រីយ៍ឲ្យធំរួបរឹតភ្នំព្រះសុមេរុដោយភេនប្រាំពីរជុំហើយ បើកពពារបាំងបិទភ្នំព្រះសុមេរុ ។

(នៅមានត)

## មធុរសវាហិណី

(តមក)

# សម្ដេចព្រះធម្មលិខិត លុំ-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

កាលនោះ សេនាគុត្តក៏បានហៅនន្ទកុមារ ឲ្យចូលមកដល់ហើយ ក៏លើកធីតារបស់ខ្លួនឲ្យជាភរិយានៃនន្ទកុមារ ហើយចែកសម្បត្តិជាច្រើនដល់នន្ទកុមារនោះឯង ។

លុះកន្លងទៅបាន ៧ ថ្ងៃ នន្ទកុមារបានដើរចេញទៅក្នុងទីនោះៗ ដើម្បីសម្រាកស្មង ក៏មានគំនិតមួយកើតឡើងជាថ្មីថា: អាត្មាអញនឹងទៅឃើញនូវព្រៃឧទ្យានជាមង្គលរបស់ស្ដេចឥឡូវនេះឯង; ហេតុតែបុណ្យព្រេងមកដាស់តឿន នន្ទកុមារក៏ដើរចូលទៅក្នុងព្រៃឧទ្យាន ហើយឡើងទៅដេកទទូរក្បាលលើផែនថ្មមង្គលសិលា សម្រាប់ធ្វើអភិសេកមហាក្សត្រិយ៍ពីបុរាណ ក្នុងទីនោះឯង ។ ជួនជាថ្ងៃនោះ ព្រះបាទពារាណសីបរមក្សត្រិយ៍ ទ្រង់សោយព្រះទិវង្គតកន្លងទៅបាន ៧ ថ្ងៃហើយ ៗ ពួកសេវកាមាត្យក្ដី បុរោហិតក្ដី ក៏បបួលគ្នាចាត់ចែងធ្វើបូជាសរីរកិច្ច ព្រះបរមក្សត្រិយ៍រួចស្រេចហើយ ក៏អង្គុយប្រជុំគ្នានៅមុខព្រះលាន ប្រឹក្សាគ្នាថា: ព្រះមហាក្សត្រិយ៍ជាម្ចាស់របស់យើងទាំងឡាយ ព្រះអង្គមានតែ

ព្រះរាជធីតាមួយព្រះអង្គ ឯព្រះរាជបុត្រពុំមានឡើយ, ធម្មតារាជសម្បត្តិក្នុងព្រះនគរ តែគ្មានស្តេចសោយរាជ្យហើយ, ពុំបានស្ថិតស្ថេរនៅយូរឡើយ នឹងវិនាសទៅជាពុំខានដោយពិត ។

ដូច្នេះ ត្រូវតែយើងទាំងឡាយគិតផ្សងរកអ្នកមានបុណ្យ នឹងបាននាំយកមកអភិសេកឲ្យសោយរាជ្យទើបបាន ។ ប្រជាពលរដ្ឋទាំងឡាយមានសេនាបតីជាដើម ក៏ព្រមព្រៀងគ្នាបានយកបុស្សរថមកទឹមសេះសិន្ធពបួនគូ មានសម្បុរដូចផ្កាកុមុទ ហើយដម្កល់នូវគ្រឿងរាជកកុធភណ្ឌទាំងប្រាំ មានស្វេតច្ឆត្រជាប្រធាន នឹងខ្សែសម្រាប់បរ លើរាជរថស្រេចហើយក៏ផ្សងលែងរាជរថនោះទៅ ហើយប្រគំនូវភ្លេងតូរ្យតន្ត្រីតាមក្រោយ ។

ឯសេះក៏នាំរាជរថចេញទៅតាមទ្វារខាងកើត មានមុខសំដៅទៅកាន់សួនឧទ្យាន ។ ហេតុដែលបណ្ដាលឲ្យសេះ នាំរាជរថផ្ដោះទៅកាន់ព្រៃឧទ្យាននោះ ដោយបុណ្យដែលននួកកុមារ បានកសាងសន្សំទុកមកអំពីបុព្វជាតិនោះឯង ។

កាលនោះ មនុស្សពួកខ្លះពោលថា: យើងទាំងឡាយត្រូវតែញ៉ាំងរាជរថឲ្យត្រឡប់មកវិញ ។

ចំណែកព្រាហ្មណ៍បុរោហិត ក៏និយាយឃាត់ហាមថា : អ្នកទាំងឡាយមិនត្រូវឃាត់រាជរថឲ្យត្រឡប់មកវិញឡើយ ។ ឯសេះទាំងគូសោត

ក៏នាំរាជរថនោះចូលទៅដល់ឧទ្យានហើយ ធ្វើប្រទក្សិណបីជុំ មានសភាពដូចជា ប្រុងប្រៀបនឹងទទួលកុមារឲ្យជិះលើរាជរថ ទើបស្ថិតនៅនឹងក្នុងទីនោះឯង ។

ទើបបុរោហិត យកដៃបើកសំពត់ដណ្ដប់ចេញ ហើយរមិលមើលលក្ខណៈផ្ទៃបាទជើងទាំងពីរ, លុះបានដឹងបានយល់សព្វគ្រប់ហើយ ក៏ពោលថា ក្នុងជម្ពូទ្វីបនេះ ត្រូវលើកទុកសិនចុះ ឯកុមារដែលប្រកបដោយលក្ខណៈយ៉ាងនេះ ប្រាកដជាបុគ្គលអាចនឹងសោយរាជសម្បត្តិ ជាក្សត្រិយ៍ដ៏ប្រសើរក្នុងទ្វីបធំទាំងបួន, មានទ្វីបតូច ១ ពីរពាន់ជាបរិវារបានដោយពិត; កាលបើបុរោហិត បានពោលដូច្នេះហើយ ក៏ចាត់ពួកក្មេងឲ្យប្រគំនូវភ្លេងតូរ្យតន្ត្រីទាំងឡាយបីដង ដើម្បីពិចារណាមើលនូវប្រាជ្ញានៃកុមារនោះជាថ្មីទៀត ។

កាលនោះ នន្ទកុមារបានបើកភ្នែកឡើងរមិលមើលជនទាំងឡាយនោះ ហើយសួរថា: អ្នកទាំងឡាយចូលមកប្រជុំគ្នានៅទីនេះ តើដោយមានហេតុអ្វី ។

អាមាត្យទាំងឡាយពោលតបព្រមគ្នាថា: បពិត្រព្រះសម្មតិទេព រាជសម្បត្តិក្នុងក្រុងពារាណសីត្រូវបានដល់ព្រះអង្គហើយ ។

នន្ទកុមារសួរថា: ចុះព្រះរាជាជាម្ចាស់នៃអ្នកទាំងឡាយ តើស្ដេច

ទៅណាទៅ? ។ អាមាត្យទាំងឡាយពោលតបវិញថា: បពិត្រព្រះសម្មតិ-ទេព ព្រះរាជាជាម្ចាស់នៃយើងទាំងឡាយ ទ្រង់ព្រះទិវង្គតទៅកាន់បរ-លោកនាយហើយ ។ នន្ទកុមារសួរទៀតថា: ព្រះរាជាជាម្ចាស់នៃអ្នកទាំងឡាយទ្រង់ព្រះទិវង្គតកន្លងទៅបានប៉ុន្មានថ្ងៃហើយ ? ។ អាមាត្យទាំងឡាយពោលតបថា : ព្រះរាជាជាម្ចាស់នៃយើងទាំងឡាយទ្រង់ព្រះទិវង្គតកន្លងទៅបាន ៧ ថ្ងៃហើយ ។ នន្ទកុមារសួរទៀតថា: ស្តេចជាម្ចាស់នៃអ្នកទាំងឡាយមានព្រះរាជបុត្រ ព្រះរាជធីតាខ្លះដែរឬទេ ? ។ អាមាត្យពោលតបថា: ស្តេចជាម្ចាស់នៃយើងមានតែព្រះរាជធីតា ពុំមានព្រះរាជបុត្រឡើយ សូមព្រះអង្គទ្រង់ជ្រាប ។ នន្ទកុមារបានស្តាប់ហើយពោលថា : បើដូច្នេះ អាត្មាអញនឹងទទួលសោយរាជសម្បត្តិដោយពិត ។

លំដាប់នោះ អាមាត្យទាំងឡាយនឹងបុរោហិត ព្រមទាំងមហាជនទាំងអស់ ក៏ព្រមព្រៀងគ្នា បានចាត់ចែងធ្វើមណ្ឌបកែវ ដើម្បីនឹងអភិសេក ទើបទៅដង្ហែព្រះរាជធីតាមកធ្វើប្រដាប់ស្អិតស្អាងស្រេចហើយនាំចូលទៅកាន់សួនឧទ្យាន រៀបធ្វើពិធីអភិសេកកុមារឲ្យសោយរាជ្យជាម្ចាស់ជីវិតនៃខ្លួន ។ ហើយអភិសេកព្រះរាជធីតាឲ្យជាព្រះអគ្គមហេសីក្នុងកាលនោះឯង ។

កាលនោះ អាមាត្យទាំងឡាយ បាននាំយកសំពត់សម្រាប់រាជ្យ

ដីមានដំរៃឡមួយសែនកហាបណៈមកថ្វាយនន្ទកុមារនោះ ដើម្បីទ្រង់ស្លៀកធ្វើអភិសេកតាមព្រះបវេណីអំពីបុរាណរៀងមក ។

នន្ទកុមារសួរថា: តា តា ម្នាលអ្នកទាំងឡាយ ! សំពត់នេះ តើជាសំពត់សម្រាប់ធ្វើអ្វី ? អាមាត្យទាំងឡាយក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព, សំពត់នេះ សម្រាប់ថ្វាយបរមក្សត្រិយ៍ស្ដេចទ្រង់ស្លៀកអភិសេក ។

នន្ទកុមារបានស្ដាប់ហើយក៏សួរផ្ទួនទៀតថា: ម្នាលអ្នកទាំងឡាយសំពត់នេះមានសាច់គ្រាស់ណាស់ មិនដូចេ្នះទេឬ? ។ ពួកអាមាត្យក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព ! បណ្ដាសំពត់សម្រាប់មនុស្សទាំងឡាយប្រើប្រាស់ មិនមានសំពត់ណាដទៃមានសាច់ល្អិតម៉ដ្ឋ ជាងសំពត់នេះឡើយ សូមទ្រង់ជ្រាប ។ នន្ទកុមារសួរទៀតថា: ចុះព្រះកជាជាម្ចាស់នៃអ្នកទាំងឡាយស្លៀកសំពត់យ៉ាងហ្នឹងឬ ? ។

អាមាត្យក្រាបបង្គំទូលថា : បពិត្រព្រះសម្មតិទេព! ក្សត្រិយ៍ជាម្ចាស់នៃយើងទាំងឡាយ ព្រះអង្គតែងទ្រង់សំពត់មានសភាពយ៉ាងនេះឯង ។

លុះនន្ទកបរមក្សត្រិយ៍បានស្ដាប់ហើយ ទ្រង់ត្រាស់ថា : បើដូចនេះយើងសំគាល់ថាព្រះកជាជាអម្ចាស់នៃអ្នកទាំងឡាយ ជាបុគ្គលឥតបុណ្យដោយពិត ; ណ្ហើយចុះ ! ត្រូវអ្នកទាំងឡាយយកកុណ្ឌីមាសមកឲ្យយើង ។

និងបានឲ្យនូវសំពត់សម្រាប់ស្លៀកដណ្តប់ឥឡូវនេះឯង ។

ឯអាមាត្យទាំងឡាយ ក៏បានយកកុណ្ឌីមាសនាំចូលមកថ្វាយមួយរំពេចនោះឯង ។

ទើបនន្ទកបរមក្សត្រិយ៍នោះ ទ្រង់កាន់យកកុណ្ឌីមាសហើយលាងព្រះហស្ត ព្រះឧស្ឋ ចាប់យកទឹកដោយព្រះហស្ត ហើយបាចសាចទៅក្នុងទិសខាងកើត ។

លំដាប់នោះមានកប្បព្រឹក្ស ១៦ ដើម ទំលាយនូវផែនដីដុះឡើងមួយរំពេចនោះដែរ ទើបព្រះនន្ទកពជទ្រង់បាចទឹកទៅទិសខាងត្បូង ក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត; ទ្រង់បាចទឹកទៅទិសខាងលិចក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត; បាចទឹកទៅទិសខាងជើង ក៏មានកប្បព្រឹក្ស ១៦ ដើមដុះឡើងទៀត រួមទាំងអស់ត្រូវជាកប្បព្រឹក្ស ៦៤ ដើមកើតឡើងប្រាកដ ដោយផលានិសង្សចីវរទានពីអតីតកាលនោះឯង ។

ព្រះនន្ទកពជបរមក្សត្រិយ៍សោក ស្តេចកាន់យកសំពត់ទិព្យមួយមកទ្រង់ស្លៀក; យកសំពត់ទិព្យមួយមកទ្រង់ដណ្តប់ ហើយត្រាស់បង្គាប់ទៅសេវកាមាត្យទាំងឡាយ ថា : អ្នកទាំងឡាយ ត្រូវចាត់ឲ្យវាយស្គរ ត្រាច់ទៅក្នុងនគរទាំងអស់ថា : ស្ត្រីទាំងឡាយ ដែលនៅក្នុងដែនព្រះបាទនន្ទកពជទាំងអស់ជាស្ត្រីអ្នកត្បាញរវៃ; ចាប់ដើមអំពីថ្ងៃនេះទៅ មិនត្រូវឲ្យរវល់

ចំពោះការត្បាញវៃទៀតឡើយ ត្រូវយកសំពត់ទិព្យអំពីដើមកប្បព្រឹក្សមកស្លៀកដណ្ដប់ប្រើប្រាស់តាមចិត្តចុះ; ស្រេចហើយស្ដេចតាក់ឲ្យលើកស្វេត.ច្ឆត្របើកបាំងពីលើព្រះអង្គ ដ៏ប្រដាប់ស្អិតស្អាងដោយប្រពៃ គង់លើដំរីដ៏ប្រសើរយាងកួលទៅក្នុងព្រះនគរ; លុះបានដល់ហើយ ក៏យាងចុះពីដំរីឡើងទៅកាន់ប្រាង្គណ៍ប្រាសាទដ៏ប្រសើរ សោយមហាសម្បត្តិ ប្រកបដោយសិរីសួស្ដី ជាសុខក្សេមក្សាន្ត ឥតមានទុក្ខភ័យអ្វីបៀតបៀនព្រះអង្គឡើយ មានព្រះនាមល្បីប្រាកដថា:“ព្រះបាទនន្ទកមហារាជ” ដោយពិតៗ

ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញទាំងឡាយអំពីមុន លោកសំដែងសរសើរផលានិសង្សទាន ដោយបទព្រះគាថាទាំងឡាយដូច្នេះថា :

យថា សាសបមត្តម្ហា ពីជា និគ្រោធបាទបោ
ជាយតេ សតសាខាគ្គោ មហានិលម្ពុទោបមោ
តថេវ បុញ្ញកម្មម្ហា អណុម្ហាវ មហាប្ផលំ
ហោតីតិ អប្បំ បុញ្ញន្តិ ជានមេញ្ញយ្យ បណ្ឌិតោ ៗ

អធិប្បាយថា: ដើមជ្រៃដ៏ស្កុកស្កម្ភមាំមួន ដោយមែកមួយរយមានឧបមាដូចកំពូលភ្នំប្រកបដោយពពកដ៏ធំ ដើមជ្រៃនោះដុះកើតមកតែអំពីពូជប្រមាណប៉ុនគ្រាប់ស្ពៃ មានឧបមាយ៉ាងណាមិញ ផលច្រើនកើតមកតែអំពីបុញ្ញកម្មមានប្រមាណតិចពិត មានឧបមេយ្យយ៉ាងនោះដែរ ៗ

ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញមិនគប្បីមើលងាយថា បុណ្យមានប្រមាណតិចដូច្នេះឡើយ គប្បីចូលចិត្តថា បុណ្យដែលបុគ្គលធ្វើមានប្រមាណតិចទេ តែនឹងឲ្យផលច្រើនចំរើនឡើងដោយវិសេសពិត ៗ

---

(នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ុម-គន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-គួរ ពិនិត្យ

---

បពិត្រអើយ វិបិង្គុត្តមាណពនោះមិញ, ទុព្វេគ្គា ជាអ្នកឥតបុណ្យ ចង្រៃកាឡកណ្ណី ៗ រីនាងកុមារីស្រីរ័ត៌ន៍ប្រសើរ ប្រកបនូវបុណ្យនោះច្រើន ៗ វិបិង្គុត្តមាណព ជាអ្នកឥតបុណ្យ ឥតលក្ខណៈ មិនមានចិត្តជាប់ជំពាក់អាល័យនៃនាងដល់តិចឡើយ ប៉ុន្តែដោយខ្លាចចិត្តទិសាបា-មោក្ខាចារ្យហើយ ពុំអាចដើម្បីនឹងស្រដីទំលាយ ឲ្យអន្តរាយបង់ពាក្យទិសាបាមោក្ខនោះមិញ កំយកនូវកូនក្រមុំសំឡាញ់ឲ្យទៅជាប្រពន្ធបិង្-គុត្តមាណព ៗ លុះវេលារាត្រី បិង្គុត្តមាណពទៅដេកលើកំពលដ៏មានសិរីសួស្តី គឺនាងកុមារីក្រាលប្រដាប់ហើយ, នាងចូលទៅនឹងដេករួមរ៉ាសនាទីនឹងបិង្គុត្តមាណព ។ ដឹងជានាងទៅដេកនឹងអាត្មា ក៏ម៉្ហាក្រោកដោះឡើងទៅដេកលើកំពលដំណេកឯដីវិញ ៗ នាងកុមារីក្រោករត់មកប្រយោជន៍មឹងទៅដេកជាមួយបិង្គុត្តមាណព ៗ បិង្គុត្តមាណពក៏រត់ចុះមកដេកឯដីវិញទៀត ៗ កាឡកណ្ណី ចាម សទ្ធិំ សិរិ-យា ន សមេតិ បពិត្រអើយ រីអ្នកចង្រៃកាឡកណ្ណី នឹងអ្នកដ៏មាន

សិរីសួស្តី មិនដែលនឹងជិតគ្នាបានឡើយ ឧបមាបីដូចជាគេយកភ្លើងទៅជួលពេលក្តៅក្រហាយនឹងគ្នាណាស់ហោង ៗ ឯនាងកុមារីដេកនៅលើសិរីសេយ្យាតែម្នាក់ឯង ៗ ចំណែកបណ្ឌិតមាណពនោះ ទៅដេកឯផែនដីតែម្នាក់ឯង ៗ

ឃរំ សត្តាហំ វីតិនាមេត្វា តំ អាទាយ អាចរិយំ វន្ទិត្វា ឯកកោ និក្ខមិ បពិត្រអើយ រីបណ្ឌិតមាណព នូវនាងកុមារីមិនគប្បីសម្រេច នូវកិច្ចសំឡាញ់ជាគំរប់ ៧ ថ្ងៃ ពង៏ប្រការដូច្នេះឯង ម៉្លោះហើយបណ្ឌិតមាណពចូលទៅក្រាបសំពះលាគ្រូអាចារ្យនឹងទៅលំនៅឋានអាត្មា ៗ ទើបអាចារ្យដណ្តឹងថា ម្នាលបណ្ឌិតមាណពអើយ បើបាទៅស្រុកហើយ តើនាងកុមារីកូនស្រីអញ ចៅនឹងយកទៅផងឬទុកនៅអាយ ? បណ្ឌិត-មាណពស្តាប់ហើយឆ្លើយថា បពិត្រអ្នកគ្រូអើយ ! ថាបើនាងមានចំណង់នឹងបង់ទៅ ក៏ឲ្យនាងនៅនឹងអម្ចាស់ចុះ ៗ ទិសាបាមោក្ខាចារ្យស្តាប់ហើយស្រដីដណ្តឹងទៅនាងកុមារីថា ម្នាលកូនស្ងួនសំឡាញ់អាពុក នាងនឹងទៅជាមួយប្តី ឬ នាងនឹងនៅអាយ ? រីនាងកុមារី ហេតុតែជាស្រីទលក្ខណ៍ នាងគិតពិចារណាថា ធម្មតាស្រីនៅឆ្ងាយពីប្តី គេថាជាមេម៉ាយចំណាយមាត់គេ នាងគិតដូច្នោះហើយ ឆ្លើយប្រាប់អាពុកថា បពិត្រអ្នកអាពុកអើយ ខ្ញុំនឹងទៅជាមួយប្តីខ្ញុំហោង ៗ

រីអ្នកទាំងពីរលោកពាក្យដើររៀនកបដកបមក ធ្វើដំណើរតាមផ្លូវ គ្មានសំណេះសំណាលនឹងគ្នាដល់តិចតួច ទៅវិញទៅមកសោះនឡើយ ៗ រីបិង្គុត្តរមាណព នឹងនាងកុមារី ដើររៀរកបដកបមកដល់ ស្រុកមិថិលា-មហានគរ យល់នូវដើមឧទុម្ពរ បរិបូណ៌ដោយនូវផ្លែទុំច្រើនសព្វកគ្រប់មែក ពុំធ្លាយពីទ្វារព្រះនគរ, បិង្គុត្តរមាណពយល់ហើយ ហេតុសម្រេកឥម្ពានមកបៀតបៀន ក៏ឡើងទៅបេះប្រឡេះផ្លែឧទុម្ពរបរិភោគ ៗ រីនាងកុមារីសោត ហេតុតែសេចក្តីស្រេកឃ្លានខ្លាំង ក៏ដើរចូលទៅកាន់ដើមឧទុម្ពរអង្វរថា សាមិ ហៃអ្នកស្វាមីអើយ! ចូរអ្នកទម្លាក់មកខ្ញុំបរិភោគផងៗ រីបិង្គុត្តរមាណព ស្តាប់ហើយខឹងក្រញឹងថា មេឯងគ្មានដៃជើងឡើងមកបេះឬ? អញនេះ, មិនមែនខ្ញុំមេហាងឯងទេ ៗ រីនាងកុមារី កាលណាបើឮបិង្គុត្តរមាណព ជាប្តីស្រដីដូច្នោះហើយក្តី នាងម្នីម្នាឡើងញដំលើចុងមែកលំនេក្រប្រគាប បេះផ្លែឧទុម្ពរបរិភោគ បន្ទាប់សម្រេកគម្លាន ៗ រីបិង្គុត្តរមាណព ដឹងថានាងឡើងមកដូច្នោះក្តី ក្រញូវស្រូតសំរូតចុះមកអំពីដើមឧទុម្ពរ , កាប់បន្លាសម្រាស់ មកស្រោសដើមឧទុម្ពរ ហើយស្រដីថា ម្នាលស្រីចង្រៃកាឡកណ្ណីអើយ ចូរមេហាងឯងនៅនេះចុះម៉្លឹះហើយ អញបានរួចអំពីហាងហើយ អញអរណាល់, ស្រដីម៉្លោះហើយ បិង្គុត្តរមាណពរត់ចោលនាងកុមារី ទៅកាន់ឋានលំនៅអាត្មា

នោះហោង ៗ នាងកុមារីមិនអាចដើម្បីនឹងចុះមកបានឡើយ បិតនៅ ឮដំបុងមែកលង្វែកប្រគាបឧទុម្ពរនោះឯងហោង ៗ

តំ ទិវសំ រាជា ឧយ្យានំ គច្ឆន្តោ តត្ថ តីទិស្វា សាយណ្ហសមយេ ហត្ថិក្ខន្ធេ និសីទិត្វា ឯកំ បរិសន្តោ តំ ទិស្វា បដិពទ្ធចិត្តោ ហុត្វា សបរិគ្គហា អបរិគ្គហាតិ បុច្ឆាបេសិ បពិត្រអើយ មានកាលសម័យថ្ងៃមួយមិញ ព្រះបាទពិទេហរាជជាមហាក្សត្រធំក្រៃ មានព្រះរាជហឫទ័យស្តេចលីលាចេញទៅប្រពាតឧទ្យាន មានមុខមន្ត្រីហែមពេមជាបរិវារ ស្តេចត្រអាលគង់លើដំរីមង្គលអំពលនូវគ្រឿងប្រដាប់ លុះសម័យថ្ងៃល្ងាចរសៀលទន់ទាបស្តេចនឹងលីលាត្រឡប់ចូលមកកាន់ព្រះនគរ មកដល់ដើមឧទុម្ពរហើយស្តេចទតទៅយល់នាងកុមារីបិតឮដំបុងឧទុម្ពរ ហើយព្រះមហាក្សត្រមានព្រះរាជហឫទ័យប្រតិព័ទ្ធ ស្រឡាញ់នាងនោះមហិមាក្រៃពេក ស្តេចប្រើអាមាត្យទៅដណ្តឹងថា ស្រីនេះមានប្តីពិភក្តិរក្សាហើយ ឬនៅ ? ៗ រាជអាមាត្យស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ក៏ទៅដណ្តឹងនាង ដូចព្រះបន្ទូល, នាងកុមារីឮហើយ ឆ្លើយប្រាប់រាជអាមាត្យថា ប្តីខ្ញុំមាន តែពុំដែលសន្ទនាមកសនាទឹងគ្នាទេ, ឥឡូវនេះ ខ្ញុំឡើងមកនៅលើចុងឧទុម្ពរ គាត់កាប់បន្ទាស្រោសរត់ចោលខ្ញុំទៅ ដូចអ្នករាជអាមាត្យយល់ស្រាប់ ៗ

អមច្ចោ តមត្ថំ រញ្ញោ អារោចេសិ បពិត្រអើយ ឮដំ
កាលនោះ រាជអាមាត្យស្ដាប់ហើយ ក៏វិលត្រឡប់មកក្រាបទូលអាថ៌
ដំណើរនៃនាង ៗ ព្រះមហាក្សត្រជ្រាបហើយ មានព្រះរាជហឫទ័យ
ថ្វៃត្រេកអរដ៏ពេញនូវព្រះអំណរបន្ទូលថា នាទ្រព្យសម្រាប់បរិវារ បើ
ឥតនឹងអម្ចាស់ហើយ គប្បីឡើងជាព្រះរាជទ្រព្យសម្រាប់ព្រះមហាក្សត្រ
នោះហោង ស្ដេចទ្រង់ព្រះចិន្ដាពិចារណា នូវប្រការអម្បាលនោះហើយ
ឲ្យដាក់នាងចុះមក ហើយលើកឡើងដំកើងលើខ្នងបាដ៏វីជ័យ ហើយ
អភិសេកជាព្រះអភិអគ្គមហេសីធំឧត្ដមក្រៃ ៗ បពិត្រអើយ, ចាប់ដើម
អំពីថ្ងៃនោះទៅ រីនាងនោះលុះជាសំឡាញ់ពេញព្រះរាជហឫទ័យ ក្សត្រ
ថ្វៃ សន្មតឲ្យព្រះនាមករ ចំរើនព្រះពរ ហៅឈ្មោះថានាង ខុត្ដរ ៗ
អំពីថ្ងៃអភិសេកនោះទៅហោង ៗ

អថេកទិវសំ រញ្ញោ ឧយ្យានគមនត្ថាយ ទ្វារគាម-
ភសិ គោហិ មគ្គំ បដិជគ្គាបេសុំ ៗ បពិត្រអើយ, មានកាល
សម័យថ្ងៃមួយ ព្រះបាទវិទេហរាជ ស្ដេចមានព្រះចំណង់នឹកចង់ទៅ
ប្រពាតឧទ្យាន មានព្រះបន្ទូលឲ្យប្រាប់បង្គាប់ប្រើអស់អ្នកផងតាំងអម្បាល
មាណ នៅទៀបទ្វារព្រះនគរឲ្យចូលចាំងដំរះមាគ៌ា ប្រយោជន៍ជាដំណើរ
ស្ដេចនឹងទៅឧទ្យាន ៗ រីបរិគ្គរមាណពចង់ក្បែនកន្ទប កាន់បបូកថ្ងវ

ដោយនូវមុខងារពុំទាន់ស្រេច ស្តេចគង់ព្រះរាជរថជាមួយនាងទុក្ខុមារ បររចេញទៅដល់ទ្វារព្រះនគរ ។ នាងទុក្ខុមារទេវី យល់បង្គុតមាណព ជាមនុស្សចៅដ្រែអប្បល័ក្ខណ៍ ជំរះផ្លូវដ្បូងនោះក្តី នាងសើចហើយគិតថា បុរសអប្បល័ក្ខណ៍កាឡកណ្ណីនេះ ពុំអាចដើម្បីនឹងទ្រទ្រង់នូវសិរីសួស្តីបានឡើយ ។ ស្តេចយល់នាងសើចដូច្នោះក្តី ស្តេចទ្រង់ខ្ញាល់មានព្រះបន្ទូលដណ្តឹងនាងថា នាងសើចអ្វី? នាងទុក្ខុមារទេវីទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ បុរសបូកផ្លូវនោះជាប្តីដើមនៃខ្ញុំ វាឲ្យខ្ញុំឡើងលើចុងល្វា វាយកបន្ទាស្រាសរហើយវារត់ទៅ ឥឡូវនេះ, ខ្ញុំមើលយល់បុរសអប្បល័ក្ខណ៍ជាអ្នកចៅដ្រែកាឡកណ្ណីបង់សិរីសួស្តីដូច្នោះ, ហេតុនោះបានជាខ្ញុំសើច ស្តេចស្តាប់ហើយទ្រង់ព្រះក្រោធពិរោធមហិមា ប្រវាចាប់ព្រះខាន់កាន់ហូតចេញ ហើយមានព្រះបន្ទូលថា មឹងស្រដីមុសាវាទពុំពិត សំដីយល់ហេតុប្រសដទៃសង្ស័យក្នុងចិត្តហើយ ទើបមឹងសើច នាងស្តាប់ព្រះបន្ទូលព្រះមហាក្សត្រដូច្នោះហើយ ឥ.ឥកិតភ័យក្រៃមហិមា ទំទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! សូមទានចូរព្រះអង្គដណ្តឹងអ្នកប្រាជ្ញឲ្យពិចារណា .បើខ្ញុំមុសាវាទពុំពិតត្រង់ សូមព្រះអង្គធ្វើតាមដោយនូវទោសកុំសន្តោសខ្ញុំឡើយ ។ ស្តេចស្តាប់ពាក្យនាងហើយ មានព្រះបន្ទូលដណ្តឹងទៅអាចារ្យសេនកថា សេនក! ហៃអាចារ្យសេនកអើយ

នាពាក្យនាងស្រដីដូច្នោះ តើព្រះស្តែងជឿឬទេ? អាចារ្យសេនកទូលថា ទេ! បពិត្រមហារាជអើយ ខ្ញុំមិនជឿទេឡើយ, ពុំដែលមានអ្នកឯណាបោះបង់ចោលនូវស្រីមានរូបល្អនោះបានទេឡើយ ។ នាងឮពាក្យអាចារ្យសេនក ទូលដូច្នោះហើយ រីងកិតភ័យក្រៃមួយសាទៀត ។ រីព្រះមហាក្សត្រាធិពជសោត ព្រះអង្គទ្រង់ព្រះចិន្តាគិតថា រីអាចារ្យសេនកនេះជាអ្នកកំឡៅ តើទឹងដឹងអ្វី? គួរគប្បីអញផ្ចណ្ដឹងទៅមហោសថឲ្យប្រាកដសិន ទើបស្ដេចសូត្រនូវគាថានេះថា ៖

ឥត្ថី សិយា រូបវតី សា ច សីលវតី សិយា
បុរិសោ តំ ន ឥច្ឆេយ្យ សទ្ទហាសិ មហោសថាសិ ។

ហៃបាមហោសថអើយ រីស្រីប្រកបនូវរូបឆោមសល្អ មានសីលព្រឹទ្ធស្រគត់ ប្រតិបត្តិប្ដី គប្បីមានដូចនាងនេះដូច្នេះ, ហើយមានបុរសមិនយកស្រីនោះមកជាភរិយាអាត្មា តើបាជឿឬទេ? រីពោធិសត្វមហា-បុរសរតន៍ប្រសើរ ស្ដាប់ដំណើរព្រះបន្ទូលផ្ចណ្ដឹងដូច្នោះហើយ ទើបពោធិសត្វទូលជាគាថាដូច្នេះថា :

សទ្ទហាមិ មហារាជ បុរិសោ ទុព្ភគោ សិយា
សិរី ច កាឡកណ្ណី ច ន សមេន្តិ កុទាចនំ ។

បពិត្រព្រះភូមិន្ទនរិន្ទនរនាថ ព្រះបាទនារាយណ៍នរបតីស្រីសម្មតិ

ទេពក្សត្រថ្លៃប្រសើរអើយ សម្ដេចព្រះអគ្គមហេសី ស្រដីទូលព្រះអង្គដូច្នោះ នោះខ្ញុំជឿពិត; បុរសឥតបុណ្យអប្បលក្ខណ៍ជាអ្នកចង្រៃកាឡកណ្ណី មិនដែលនឹងឋិតនៅជិតខាងស្រីមានលក្ខណ៍បានឡើយ បីដូចត្រើយសមុទ្រខាងឯអាយ នឹងត្រើយសមុទ្រខាងឯនាយឆ្ងាយពីគ្នា ពុំនោះបីដូចអាកាសនឹងក្រឡាមហាប្រឹថពីពុំដែលនឹងជិតគ្នាបាន មានប្រការម្ដេចមិញ, បុរសចង្រៃអប្បលក្ខណ៍ ពុំដែលឋិតខាងអ្នកមានសិរីសួស្ដីបាន ដូច្នោះហោង ។

ស្ដេចស្ដាប់ពាក្យពោធិសត្វទូល ដោយនូវហេតុប្រការអម្បាលនោះហើយ ស្ដេចស្រាកព្រះហឫទ័យខ្វាល់លត់បង់ ទ្រង់ព្រះអំណរនឹងពោធិសត្វ ហើយមានព្រះបន្ទូលថា ហៃបាមហោសថអើយ បើអញឥតពីបាហើយ ម៉្លេះសមអញនឹងបង់ស្រីរតនប្រសើរ តាមដំណើរពាក្យអាចារ្យសេនក ជាអ្នកអន្ធពាលគ្រោលសេចក្ដីស្រដីខុសនឹងច្បាប់បុរាណ អញបាននាងនោះគង់ជីវិត ហេតុដ្បិតតែពាក្យបាឯង ស្ដេចសរសើរពោធិសត្វនូវប្រការអម្បាលនោះហើយ ស្ដេចឲ្យយកមាសមួយសែនដំឡឹងមកបូជាពោធិសត្វកាលនោះហោង ។

នោះឯទុម្ពរទេវី ក្រាបថ្វាយបង្គំព្រះមហាក្សត្រហើយទូលថា ទេវបពិត្រព្រះអម្ចាស់អើយ ជីវិតនៃអញខ្ញុំ បានគង់នោះនៅតាំងម៉្លេះនេះ

ហេតុអាស្រ័យនឹងចៅមហោសថ ឥឡូវនេះ ខ្ញុំសូមពរអំពីព្រះអង្គ ទុកចៅមហោសថនេះជាប្អូនបង្កើតខ្ញុំហោង ។ ព្រះបាទវិទេហរាជមានព្រះបន្ទូលថាម្នាលនាងឧទុម្ពរទេវីអើយ ពាក្យនាងស្រដីមកនោះពិរោះៗ ពេកអញនឹងឲ្យនាងដូចប្រាថ្នា ចូរនាងទទួលយកហោង ។ ទើបនាងឧទុម្ពរ-ទេវី ទូលព្រះមហាក្សត្រវិញទៀតថា បពិត្រអម្ចាស់អើយ ចាប់ដើមអំពីថ្ងៃនេះទៅ ទោះបីខ្ញុំធ្ងន់នូវសារពើចំណីផ្អែមពិសាតិចតួចក្តី ក៏ខ្ញុំមិនបង់នៃប្អូនខ្ញុំនោះ ទោះវេលាគួរក្តីពុំគួរក្តី ខ្ញុំសូមឲ្យបើកជូននូវចំណីទៅចៅមហោសថកុំឲ្យឃាត់ខាំងឡើយ ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា ភទ្ទេហៃនាងអើយ អញព្រមអនុញ្ញាតឲ្យតាមចិត្តនាងហោង ។ ព្រះបាទវិទេហរាជសោត ស្តេចវិលមកកាន់ព្រះរាជមន្ទីរវិញហោង ។

សិរីកាឡកណ្ណី បញ្ហា និដ្ឋិតា ។ រឿងស្រដីអ្នកមានសិរីសួស្តីនឹងអ្នកចង្រៃអប្បលក្ខណ៍នេះមិញ ក៏សូរេចនូវប្រការអម្បាលនេះឯងហោង ។

អបរស្មឹ ទិវសេ... មានកាលសម័យថ្ងៃមួយ, ព្រះបាទវិទេហរាជ ស្តេចសោយព្រះក្រយាស្ងោយនាព្រឹកស្រេច ស្តេចលីលាយាត្រាទៅ ដោយនូវចំលួយ (ចន្លោះ) ប្រាសាទកូវ ស្តេចមើលមើលទៅដោយនូវលង្វែកបង្អួច យល់ពពែមួយនឹងឆ្កែមួយនោះកំពុងធ្វើជាមិត្ត

សន្ទា:ផងគ្នា ។ គឺ ដូចយើងបានឮមក រីពពែនោះ មានកាលមួយថ្ងៃ ទៅធីស្មៅដែលគេទុកនៅក្នុងរោងដំរីនោះ គេយល់ពពែពាំនាំស្មៅចេញទៅទីធ្លីដូច្នោះក្ដី វាបានដំបងដេញទៅដោយនូវកំឡាំងឆាប់ទាន់ ហើយវាយត្រូវត្រង់ខ្នងពពែលុះនូវវេទនា មានខ្នងនោះខូចក្រញោន ស្រែករត់ទៅដេកអាស្រ័យនៅខាងជញ្ជាំងធំនោះហោង ។

តំ ចិរសមេរ . . . កាលថ្ងៃនោះឯង មានឆ្កែមួយដើរទៅរកធីនៅខាងរោងគ្រួធំ រីអ្នកគ្រួនោះ ចំអិនបាយត្រីសាច់ឆ្អិនស្រេចហើយចេញទៅសម្ងួតញើសឯក្រៅ, រីឆ្កែធុំក្លិនសាច់មានរសឆ្ងាញ់ពិសា ក៏ពុំអាចដើម្បីទ្រាំអត់បានឡើយ លបចូលទៅក្នុងរោងគ្រួធំ ក៏បើកគ្របកាដន៍នោះឡើងហើយ ពាំនាំសាច់នោះចេញមក, រីអ្នកគ្រួនោះឮនូវស័ព្ទឆ្កែបើកនូវគ្របកាដន៍នោះហើយ ម្នីម្នាចូលទៅយល់ឆ្កែពាំនាំសាច់ដូច្នោះក្ដី វាកាំងទាំងម្នីម្នាប្រវាចាប់បានកំណាត់ឈើវាយត្រូវខ្នងឆ្កែ, រីឆ្កែនោះទម្លាក់សាច់ហើយ ស្ទុះរោលចេញទៅ, រីអ្នកគ្រួរត់ដេញតាមទៅ វាយឆ្កែដោយដំបង ត្រូវឆ្កែបាក់ហោង ខ្នងខូចក្រញោន ហើយលើកជើងមួយរត់ទៅខាងដំណេកពពែនោះហោង ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# វប្បធម៌

## លោក លី-ធាមតេង

*សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ*

រៀបរៀង

---

*ដើម្បីនឹងអធិប្បាយ ឲ្យបានជ្រៅជ្រះអំពីវប្បធម៌ យើងសូមធ្វើការវែកញែកបញ្ឆាក់ឲ្យល្អិតល្អន់បន្តិច ក្នុងអត្ថន័យរបស់ពាក្យវប្បធម៌នេះសិន ព្រោះជាការជំរះមន្ទិលសង្ស័យ របស់បណ្ដាមិត្តអ្នកអានខ្លះ ដែលមានសេចក្ដីងឿងឆ្ងល់ក្នុងសន្ដានចិត្តថា៖ ហេតុអ្វីហ្ន៎! ក៏និយាយពីរឿងវប្បធម៌ហើយវប្បធម៌ទៀត មិនចេះអស់មិនចេះហើយសោះ ? តើវប្បធម៌នោះជាអ្វីទៅ ? មានអ្វីខ្លះជាសាខារបស់វប្បធម៌នេះ? នរណាជាអ្នកមានភារៈរក្សានឹងលើកដំកើងវប្បធម៌ ?*

*ចំពោះសំនួរទាំងប៉ុន្មានខាងលើ យើងអាចធ្វើជាសេចក្ដីអធិប្បាយពន្រីកអត្ថន័យតាមទស្សនៈសរុបខាងក្រោមនេះ៖*

*បើតាមរូបសព្ទ ពាក្យថា វប្បធម៌ បានន័យថា៖ ការបណ្ដុះនូវក្បួនតម្រា, ការបង្កើននូវក្បួនខ្នាតឬមុខវិជ្ជាផ្សេងៗ, ដូច្នេះ, បើពោលឲ្យខ្លីថា*

អ្វីដែលជាសេចក្ដីចំរើន, សេចក្ដីចេះដឹង, អំពើល្អគលាស់ គឺសុទ្ធតែហៅថា វប្បធម៌ទាំងអស់ ។ ប្រសិនណាជាយើងល្បង ធ្វើការពិនិត្យសង្កេតបន្តិចទៅទៀត យើងអាចរកឃើញសាខាដែលជាគោលសំខាន់ៗ ក្នុងវប្បធម៌ដូចតទៅ ៖

១- សិល្បៈរបាំ _ ជាការផ្ដិតលំនាំ តាមសេចក្ដីចំរើន ខាងកាយវិការរបស់មនុស្សគឺជាដំណាងដំណើរវិវត្តន៍នៃមនុស្សជាតិ ។

២- តូរ្យតន្ត្រី_ ជានិមិត្តរូបនៃស្មារតីរបស់មនុស្ស គឺជាសូរសំនៀងនៃមនោសញ្ចេតនា ក្នុងដំណើរចំរើនឡើងនៃជីវភាពមនុស្ស ។

៣- អក្សរសាស្ត្រ_ មានកំណាព្យកាព្យឃ្លោង, ពាក្យសំដី, សំនួរវោហារ, ការលាតត្រដាងជាផ្ទៃរឿងរ៉ាវជាដើម សុទ្ធសឹងជាការផ្ដិត យកតាមលំនាំរបបរស់នៅ ដែលចំរើនទៅ គ្មានឈប់ឈរនៃមនុស្សជាតិនិងធម្មជាតិ ។

៤- លទ្ធិសាសនា _ ជាការត្រិះរិះខាងផ្លូវគំនិត, បញ្ញា, ស្មារតីដែលបង្កើតបានជាគុណប្រយោជន៍មួយយ៉ាងសំខាន់ ខាងផ្នែកហ្វឹកហ្វឺនសន្ដានចិត្ត ។

៥- ក្បាច់បំឡាក់របនា_ ជាការសម្ដែងចេញនូវសភាពរបស់គំនិត

ដែលគិតឃើញ តាមដំណើរជឿនលឿនជាលំដាប់នៃប្រាជ្ញាមនុស្ស ។

៦- ការអប់រំ – ពោលគឺចរិយាសាស្ត្រ ឬ សុជីវធម៌ ដែលមនុស្សជាតិចំរើនសព្វថ្ងៃត្រូវការជានិច្ច សំរាប់រៀបចំអត្តភាពក្នុងជីវភាពរបស់ខ្លួន ។

៧- វិទ្យាសាស្ត្រ – ជាវិជ្ជាចំរើនក្នុងការស្រាវជ្រាវរករកចំពោះបញ្ហាឬរូបភាពវត្ថុអ្វីមួយ ឲ្យឃើញដើមចមប្រាកដជាក់ស្តែង ។ ល ។

បើយើងបើកបញ្ចេញអាថ៌កំបាំង រកឃើញអវយវៈរបស់អង្គនៃវប្បធម៌ ដូចមានពោលជាគោល ៗ ខាងលើនេះហើយ យើងនាំគ្នាធ្វើការពិចារណាបន្តិចទៅទៀត ចំពោះវប្បធម៌ជាតិខ្មែរ ដែលជាជាតិកំពូលស្នេហ៍របស់យើង ហើយដែលជាការៈចាំបាច់របស់យើង ជាកុលបុត្រ - កុលធីតាបុព្វបុរសខ្មែរ ដែលបានកសាងវប្បធម៌សំរាប់ជាតិ ជាយូរអង្វែងមកហើយដែរ ។ យើងឆ្លើយឲ្យខ្លីគឺដូចនេះថា៖ "ខ្មែរយើងមានវប្បធម៌ប្រចាំជាតិជាក់ប្រាកដណាស់" ។

បានជាហ៊ានពោលដូចនេះ ព្រោះយើងសង្កេតឃើញពិតជាក់ស្តែងថា ខ្មែរមានសិល្បៈប្រចាំរបស់ជាតិ ប្រកបដោយលក្ខណៈពិសេសបំផុតដែលល្បីរន្ទឺកិត្តិនាមសាយសព្វនៅអាស៊ីអាគ្នេយ៍ និងបច្ចុប្បន្នកាលនេះ ព្រហូតដល់ផ្នែកអឺរ៉ុបនិងអាមេរិកថែមទៀត ។ ក្បាច់ចំលាក់ក្បាច់រចនាប្រចាំពីរកនេះ មានលក្ខណ្ឌជាក់លាក់មិនមែនធ្វើដោយព្រាវ ៗ ទេ ។ មើលចុះ! ការ

ពត់អង្គកាយ អែនអនសមរម្យទៅតាមចង្វាក់ញ៉ាំញ៉ី ប្រកបដោយអវយវៈទន់ភ្លន់កែក្រោយគ្មានខ្ចោះ ៗ ព្រមជាមួយនោះ សៀងជួរដន្ត្រីក្រទុំលាន់លោច ជួយពត់ជួយសម្រួលក្បាច់រាំ ដ៏មានសូរចំរៀងអមជាមួយផង ៗ ការដាក់ទឹកមុខ និងភាពពងកាយ លំអដោយអលង្ការណ៍ផងនោះ ក៏ត្រូវបានជាប្រដាប់លើកដំកើងសិល្បៈរបាំយើងនេះដែរ ៗ ក្បាច់ក្បូរ ដែលយើងពណ៌នានេះ មានអាយុវែងឆ្ងាយណាស់ បើពោលឲ្យឆ្ងាយចាំថា តាំងពីគ្រាដែលខ្មែរកសាងប្រាសាទអង្គររពងជាង ១០ សតវត្សរ៍មកហើយ ៗ ហើយនៅគ្រាជាមួយនោះទៀតការរចនាខាងចំឡាក់រូបភាពផ្សេង ៗ ក៏ឧប្បត្តិឡើងយ៉ាងត្រចះត្រចង់ណាស់ដែរ ៗ យើងឃើញហើយ ប្រាង្គប្រាសាទក្ដី ស្ពាន ឬបង្កាន់ដៃអមសងខាងមាត់នៃប្រាសាទបុរាណយើងក្ដី ឬនៅតាមវត្ថុសក្ការៈផ្សេង ៗ មានព្រះស្តូប និងវត្ថុអាពមជាដើមក្ដី សុទ្ធសឹងតែមានក្បាច់ចំឡាក់ងទន្លាំរស់រវើក សូម្បីពេលវេលាទំបំផ្លិចបំផ្លាញជាយូរមកហើយ ក៏ពុំទាន់អស់សោភ័ណនៅឡើយ បែរជាបង្កើតបានជាបញ្ហាពិសេស ៗ ឲ្យយើងត្រិះរិះក្នុងគ្រាបច្ចុប្បន្ននេះទៅវិញ ៗ

អក្សរសាស្ត្ររបស់ខ្មែរសោតទៀត ក៏មានរូបរាងមកជាអង្វែងហើយដែរ ដែលទទួលការលូតលាស់ជាលំដាប់តាមយុគ តាមសម័យ របស់

ស្រុកទេស ដែលប្រព្រឹត្តទៅតាមដំណើរប្រវត្តិសាស្ត្រ ៗ ជាភស្តុតាងដូច ផ្ទាំងសិលាចារឹក រាប់ពាន់សន្ទឹកដែលអ្នកស្រាវជ្រាវគេឃើញមានចុះកាល-បរិច្ឆេទ តាំងពីសតវត្សរ៍ទី ៤, ទី ៥ មក ៗ ផ្នែកវណ្ណកម្មជារឿងរ៉ាវក៏មាន ជាក់ស្តែងទៀត ដូចជារឿងរាមកេរ្តិ៍ នឹងរឿងមហាភារតៈ ជាគួយ៉ាង ៗ រឿងទាំងនេះ មិនត្រឹមតែចារឹកទុកពីពាក្យសំដីវោហាររបស់ខ្មែរ ក្នុងសម័យនោះទេ ថែមទាំងលាតត្រដាងខាងផ្នែកគំនិតដ៏ជ្រាលជ្រៅទៀត ព្រោះសុទ្ធតែជារឿងនិទានពីការច្បាំង យកឈ្នះចាញ់រវាងសភាវៈទាំងពីរ គឺអំពើល្អ នឹងអំពើអាក្រក់, យុត្តិធម៌ នឹងអយុត្តិធម៌, សប្បុរស នឹងអសប្បុរស ៗលៗ លក្ខណៈពិសេសរបស់វណ្ណកម្មខ្មែរមួយទៀត ត្រង់សំដីតែងជាបទបែបដោយឡែក ១ ពីគ្នា ៗ បើយើងមិនពិចារណាឲ្យជ្រៅទេ យើងអាចយល់ច្រឡំថា ខ្មែរបង្កើតបទបែបក្នុងអក្សរសាស្ត្រនេះ នាំឲ្យវិលពិបាកអានឥតប្រយោជន៍ ៗ តែបើតាមការពិតមិនដូចនោះទេ ៗ មនុស្សយើងក្នុងការប្រព្រឹត្តទៅនៃជីវិត រមែងប្រកបដោយកាយវិការប្លែក ១ ពីគ្នា ក្នុងគ្រាដើរកំសាន្ត, ក្នុងពាក្យសន្ទនា, ក្នុងសំដីកំហឹងរឹងរុះ, ក្នុងភាពកំប្លុកកំប្លែង ឬក្នុងសំដីដំអូញល្ហួងលោមជាដើម ៗ តាមដំណើរកាយវិការទាំងហ្នឹងហើយ ដែលអ្នកអក្សរសាស្ត្រពីបុរាណរបស់យើង បង្កើតជាបទបែបដោយឡែក ១ ដើម្បីដំណាងឫកពាររបស់មនុស្ស ឲ្យបានដូចមែនទែន ៗ

យ៉ាងទៀត គន្លងបទបែបនេះ ក៏មានសព្ទសូររងំ រណ្ដំគ្នាគួរជាទីទាក់អារម្មណ៍អ្នកស្ដាប់ ៗ មិនតែប៉ុណ្ណោះ ជើងកាព្យ ឬពាក្យឃ្លោងរបស់ខ្មែរយើង មានលក្ខណៈប្លែកត្រង់ការចាប់ចុងជួន គឺឲ្យសំដីប្រទាក់ប្រទងណែងណងនឹងគ្នាជិតណាស់ផង ៗ

ចំពោះលទ្ធិសាសនា ដែលយើងបានកាន់ខាងលើ បញ្ចូលក្នុងចំណោមសាខារបស់វប្បធម៌ដែរនោះ, បើយើងប្រមើលបញ្ជាក់បន្តិចទៅទៀត ក៏ឃើញថា ហុចប្រយោជន៍ឲ្យបណ្ដាជនយើងជាច្រើនក្រៃលែងដែរ ដ្បិតជាគោលគំនិតខាងអប់រំសតិបញ្ញាស្មារតីជនិមួយៗ រៀងដរាបតាំងពីដូនមក ៗ យើងពោលឲ្យចំថា: លទ្ធិសាសនាជាមូលដ្ឋានខាងគំនិតមួយយ៉ាងមាំក្នុងស្មារតីសាមគ្គីធម៌ ៗ មើលចុះ បើមនុស្សក្នុងប្រទេសណាកាន់លទ្ធិសាសនាមូលគ្នា អ្នកដឹកនាំប្រទេសនោះ ងាយនឹងណែនាំណាស់ ដ្បិតប្រជាជាតិពុំមានប្រកាន់ចិត្តបង្គំនុំនឹងគ្នា ៗ មួយទៀតបើប្រើវិធីណែនាំនោះ ផ្ទុកទៅតាមទ្រឹស្ដីនៃលទ្ធិសាសនា ដែលធ្លាប់គោរពកាន់មកស្រាប់ផង ក៏រឹងរឹតតែងាយមូលមាត់គ្នាណាស់ទៅទៀត ៗ ដោយមានគុណប្រយោជន៍ដូចនេះ ទើបគ្រប់ប្រទេសក្នុងលោកតែងតែប្រកាន់យកសាសនារៀងៗខ្លួន ៗ

បើពោលពីការអប់រំវិញ ក៏ឃើញថាខ្មែរយើងមានចង្រេងខាងវិធី

អប់រំគ្នីគ្នាជាយូរមកហើយដែរ ។ តាមសាស្ត្រាស្លឹករឹតជាច្រើនច្បាប់ បុព្វបុរសយើងបានតារបង្ក្រង ជាពាក្យទូន្មានប្រៀនប្រដៅដល់កូនចៅខ្មែរ ឲ្យចេះពត់ហាត់កាយវាចាចិត្ត ដើម្បីឲ្យបានត្រឹមត្រង់តាមតម្រាយក្រិត្យក្រម ពោលគឺគន្លងសីលធម៌ដ៏ល្អប្រពៃ ។

ឯវិទ្យាសាស្ត្រ ដែលជាមែកមួយយ៉ាងសំខាន់ក្នុងវប្បធម៌ទំនើបនេះ ពីដើមមក ក៏ខ្មែរយើងសំគីគិតដល់ណាស់ដែរ ។ យើងឃើញភស្តុតាងយ៉ាងឆាយដឹង, ឆាយស្គាល់បំផុតគឺប្រាសាទអង្គរ ដែលបុព្វបុរស បានសាងដោយវិធីប្រើវិទ្យាសាស្ត្រ ដូចយ៉ាងស្ថាបនកម្ម មានគំនូរគំពេងហាត់ដៅនៃតួប្រាសាទ, វិធីលើកស្ទូចដុំថ្មដ៏ធំមហិមាដាក់បន្តបគ្នាឲ្យទាល់តែបានខ្ពស់ស្កឹមស្កៃ និងវិធីលាយធាតុធរណី ឲ្យកើតបានជាថាវរវត្ថុជាប់លាប់បានអាយុវែងក្រៃលែងមកជាដើម ។

យើងមិនមែនចេះតែពោលទន្ទេញពីអង្គរវត្ត ដោយព្រាវ ៗ ឬដោយអាងតែគ្មាននរណាកើតទាន់នោះទេ គឺយើងពោលដោយចេះសិក្សាស្រាវជ្រាវរកន័យរបស់បូជនីយដ្ឋានទាំងនោះផង ទើបប្រសើរ ព្រោះជួនកាលថ្មមួយដុំតូចសោះ តែមានខ្លឹមសារជ្រាលជ្រៅសិក្សាមិនអស់មិនហើយ ។

ហេតុនេះ ភារៈយើងជាខេមរជាតិក្នុងបច្ចុប្បន្នកាល ត្រូវតែនាំគ្នាសើរើនូវវប្បធម៌ចាស់ ៗ ឲ្យរស់សិន សឹមសិក្សាថែមទៅក្នុងវប្បធម៌ទំនើប ។

ទៀត ៗ ព្រោះថា ជាតិណា សាសន៍ណាក៏ដោយ, បើគេចង់សិក្សា
ឲ្យបានចេះពិតប្រាកដខាងវប្បធម៌ គេត្រូវសិក្សាជាដំបូង ពីវប្បធម៌បូរាណរបស់ជាតិខ្លួនជាមុន ដើម្បីបង្កើតមូលដ្ឋាន គឺឫសកែវមួយឲ្យមាំសិន ហើយគេចាប់សិក្សាបំបែកពីវប្បធម៌ទំនើបជាបន្ត ៗ ទៅទៀត ៗ
ត្រង់នេះ យើងនឹកឃើញឧទាហរណ៍មួយ ដូចជាដើមក្រូចជាតិនានា ៗ
ដើម្បីឲ្យដើមក្រូចនោះ មានសភាពមាំទាំត់តព្រួយបារម្ភដោយខ្យល់ព្យុះ
ឬទឹកជន់ ត្រូវដើមឈើនោះចាក់ឫសកែវឲ្យស៊ប់មាំមួនក្នុងធរណីសិន រួច
សឹមបែកមែកសាខាជាក្រោយ ៗ បើដើមឈើណាមានសណ្ឋានដូចនេះ
ប្រាកដជាមែក, ធាង, ស្លឹក, ត្រួយ, លូតលាស់បានល្អគ្រាល ហើយ
ជៀសវាងពីមហន្តរាយពាយុផង ៗ

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

*ដោយយល់ឃើញថា ជាការមានប្រយោជន៍យ៉ាងវិសេសដល់អ្នកអានភាគច្រើន ទើបយើងស្រង់យកមកចុះប្រគេន.ជូនបន្តិចម្ដងៗក្នុងទំព័រនេះ នូវពាក្យដែលគណៈកម្មការវប្បធម៌ បានប្រែចេញពីភាសាបារាំង មកជាខេមរភាសា ដូចតទៅនេះ៖*

| | | |
|---|---|---|
| Livret scolaire | | សៀវភៅសិក្ខាគារិក |
| Racine crampon | | ឫសតោង |
| Racine pivotante | | ឫសស្នឹង |
| Racine adventive | | ឫសព្រយុង |
| Racine fasciculée | | ឫសស្រែ |
| Recensement agricole | | ជំរឿនកសិកម្ម |
| Vulgarisation agricole | | ឧត្តានកសិកម្ម |
| Floraison | n.f. | រដូវផ្កា, បុប្ផការ, បុប្ផកាល |
| Fructification | n.f. | រដូវផ្លែ, ផលការ |
| Renseignements culturaux | | ពត៌មានខាងវប្បកម្ម |
| Pluviométrie | n.m. | វស្សមាត្រវិធី |
| Pluviomètre | n.f. | វស្សមាត្រ |
| Hygrométrie | n.f. | មេឃមាត្រវិធី |
| Nicotine | n.f. | និកូតរស |
| Pipérine | n.f. | ម្រេចរស |

| | | |
|---|---|---|
| Caféine | n.f. | ការហ្មេរស |
| Croisement | n.m. | ការបង្កាត់ |
| Pollinisation | n.f. | រម្ងូវលំអងផ្កា, ការកេយលំអងផ្កា |
| Tout venant | | ពូជរយ |
| Franc pied | | ពូជបណ្ដុះ |
| Acidité du sol | | ភាពជូរនៃដី, អម្លិលភាព |
| Alcalinité du sol | | ភាពប្រៃនៃដី, លោណភាព |
| Neutralité du sol | | អព្យាក្រិតភាពនៃដី |
| Sous-sol | n. m. | អធោប្រថពី |
| Sonde agrologique | | ចង្រប់ក្សេត្រភូមិ |
| Agrologie | n. f. | ក្សេត្រភូមិវិទ្យា |
| Sécateur | n. m. | កន្ត្រៃកាត់ឈើ |
| Ecartement | n. m. | ប្រលោះ, ប្រឡោះ |
| Plante herbacée ou herbe | n. f. | តិណជាតិ |
| Plantes aborescentes | | រុក្ខជាតិ |
| Arbrisseau | n. m. | គុម្ពព្រឹក្ស |
| Arbuste | n. m. | ចុល្លព្រឹក្ស |
| Lianes | n. f. | វល្លិជាតិ |
| Botanique | n. f. | ភូតគាមសាស្ត្រ |
| Plante adventice | | ភូតគាមដុះឯង |
| Modernisation de l'agriculture | | ទំនើបនីយកម្មនៃកសិកម្ម |
| Désherbant | n. m. | ថ្នាំតិណឃាត |
| Phytopharmacie | n. f. | ភូតគាមោសថវិទ្យា (ភូតគាមោសថវិទ្យា) |
| Phytopathotique | | ភូតគាមរោគវិទ្យា |
| Azotobactère | | អស្សូទូប៉ាក់ទែរ |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

ព្រះមហា ប៉ាង · ខាត់ រៀបរៀង

---

អតិបទ្មិន៑ គុ (ដំរី) ដែលមានស្នាមដាំក្រហមក្រៃពេក ។

អតិបរិក្សិប្ត គុ. ដែលឈឺក្រៃលែង ។

អតិបរិក្សត គុ ដែលរបួសក្រៃលែង ។

អតិបរិបយ បុ. កិរិយាសន្សំក្រៃលែង ។

អតិបរុឞ គុ. សាហាវក្រៃលែង, ស្រួចក្រៃពេក ។

អតិបា ធាតុ. ដឹកក្រៃលែង ។

អតិបាត បុ. កិរិយាធ្លាក់ក្រៃលែង, ការធ្វេសប្រហែស, ការភ្លេច ។

អតិបាតក នបុ. ទោសធ្ងន់ក្រៃលែង ។

អតិបាតិន៑ គុ. ដែលធ្លាក់ចុះក្រៃលែង, ដែលលឿនក្រៃលែង, ដែល
បណ្ដែតបណ្ដោយ ។

អតិបាត្យ គុ ដែលគប្បីបណ្ដែតបណ្ដោយ ។

អតិបារ គុ. ដែលទូលាយក្រៃលែង ។

អតិបិតាមហ គុ. អតិបិតមហា ដែលកន្លងជីតាដោយក្រៃលែង ។

អតិបិតឫ គុ. ដែលកន្លងបិតាដោយក្រៃលែង ។

អតិបិសុន គុ. អាក្រក់ក្រៃលែង, ដែលញុះញង់ក្រៃលែង ។

អតិបីឌន ឧបុ. កិរិយាបៀតបៀនក្រៃលែង ។

អតិបុណ្យ គុ. ដែលមានបុណ្យក្រៃលែង។ –វន្ត គុ. ដែលមានបុណ្យក្រៃលែង ។

អតិបូរ ឧបុ. ស្ទឹងហូរខ្លាំង, កិរិយាហូរក្រៃពេក ។

អតិបូរិ គុ. ដែលកន្លងទៅយូរក្រៃពេក ។

អតិភឫ ធាតុ. ពេញក្រៃពេក ។

អតិបេសល គុ. ដែលប្រសប់ក្រៃលែង, ដែលឆ្លាតខ្លាំង ។

អតិបៅរុប គុ. ដែលក្លៀវក្លាក្រៃលែង ។

អតិប្រកាស គុ. ដែលប្រកាសក្រៃលែង, ដែលល្បីល្បាញខ្ទរទៅ ។

អតិប្រគេ ក្រិ. វិ. ព្រឹកព្រហាមណាស់ ។

អតិប្រជ្វល ធាតុ. បំភ្លឺក្រៃលែង, ក្រោល ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៣

ឧកញ៉ាវិបុលរាជសេនា ងួ-ហ៊ង ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

ជីវយីឮដូច្នោះក៏តក់ស្លុតស្មារតី ហើយបង្គាប់ស៊ុនខៀនថាឲ្យវិលទៅវិញចុះ ចាំថ្ងៃក្រោយយើងនឹងទៅសួរឡៅពី ។ ស៊ុនខៀនក៏លាជីវយីទៅវិញ ។ ឡោសុកក៏សួរជីវយីថា ស៊ុនខៀនជំរាបលោកថា ឡៅពីនឹងខុងបេងលើកទាហានទៅតាំងនៅមាត់កំពង់អ៊ីកាំង លោកក៏ភ័យតក់ស្លុតស្មារតីដោយហេតុអ្វី ? ។ ជីវយីថា ពីព្រោះយើងឃើញហេតុថា ឡៅពីនឹងខុងបេងមុខជាដណ្តើមយកស្រុកឡាំកុនជាប្រាកដ បានជាយើងភ័យបារម្ភណាស់ ដែលយើងធ្វើការគ្រានេះក៏ខូចបង់ទ្រព្យរបស់ មាសប្រាក់ដែលចំណាយឲ្យសេនាទាហានប្រើប្រាស់ នឹងស្បៀងអាហារជាច្រើន

ឯស្រុកឡាំកុននោះ ក៏ដូចជានៅក្នុងកណ្ដាប់ដៃយើងហើយ បើត្រឡប់ជាបានស្រុកនោះទៅឡៅពី, ខុងបេងវិញ យើងក៏នឹងមានសេចក្ដីតូចចិត្តដូចជាស្លាប់ខ្លួន, ហេតុនេះ ទើបយើងភ័យបារម្ភណាស់ ។ ឡោសុកថា បើដូច្នោះ តើលោកនឹងគិតប្រការម្ដេចវិញ ដើម្បីនឹងឲ្យឡៅពីនឹងខុងបេងលើកទាហានថយទៅពីទីនោះ ឲ្យឆ្ងាយពីដែនស្រុកឡាំកុនបាន ? ។ ជីវ-យីតបថា យើងត្រូវគិតឲ្យទៅនិយាយនឹងឡៅពី ដោយសេចក្ដីល្អសុភាពសិន បើឡៅពីមិនស្ដាប់យើងទេ សឹមយើងគិតកំចាត់ចេញឲ្យបាន ។ ឡោសុកថា លោកគិតនោះត្រូវណាស់ បើលោកត្រូវការទៅរកឡៅពីវេលាណា ខ្ញុំបាទនឹងទៅផង ។ ខណៈនោះ ជីវយីក៏នាំឡោសុកទៅជាមួយនឹងទាហាន ៣ ពាន់ ចុះទូកចម្លាំងចេញចាកកងទ័ព ដើម្បីនឹងទៅរកឡៅពី ។

ឯស៊ុនខៀនកាលត្រឡប់ទៅដល់ ក៏ចូលទៅជំរាបឡៅពីតាមរឿងជីវយីនិយាយនោះសព្វគ្រប់ ។ ឡៅពីឮដូច្នោះ ក៏ប្រឹក្សានឹងខុងបេងថា ដែលជីវយីប្រុងនឹងមកគំនាប់យើងនោះ លោកយល់ឃើញប្រការម្ដេច? ។ ខុងបេងថា ឯចិត្តជីវយីនោះ មិនមែនរាប់អានខ្ញុំនឹងលោកដោយស្មោះត្រង់ ហើយចង់មកគំនាប់ដោយត្រង់ទេ គឺប្រុងនឹងមកដោយមន្ទិលសង្ស័យថា យើងមុខជាដណ្ដើមយកស្រុកឡាំកុន ។ ឡៅពីថា បើជីវយីមកជាក្បួនទ័ព

តើយើងនឹងត្រូវគិតប្រការម្ដេច ៗ ខុនបេងទូនឲ្យប្រាប់ឡៀវពីឲ្យឆ្លើយ តបពាក្យសំដី ទៅនឹងដីវយើសព្វគ្រប់ ហើយប្រើទាហានឲ្យរៀបចំទូក ចម្បាំងចេញទៅចតនៅមាត់កំពង់ ថាបើឃើញដីវយើមកដោយកាច ក៏ ឲ្យជួយគ្នាច្បាំងការពារតាមការ ទទួលមានបំរើចូលមកជំរាបថា ឃើញ ដីវយើនឹងឡៅសុក លើកទាហានមកប្រហែល ៣ ពាន់ ចតទូកនៅមាត់ កំពង់ ៗ ឡៀវពីក៏ប្រើជួឡុងឲ្យនាំទាហានប្រហែល ៥០ នាក់ ចេញទៅ ទទួលដីវយើដល់ក្រៅបន្ទាយ ដីវយើក៏ឲ្យទាហានតាំងពួនឈប់នៅខាងក្រៅ ហើយនាំឡៅសុក ចូលទៅក្នុងបន្ទាយ, ឡៀវពីនឹងខុនបេង ក៏ចេញទៅ ទទួលដីវយើៗ ចូលមកអង្គុយទីសមគួរ ហើយក៏គំនាប់គ្នាទៅវិញទៅមក ហើយឡៀវពីឲ្យរៀបតុះលៀងអាហារ អញ្ជើញដីវយើនឹងឡៅសុកបរិភោគ ផឹកស្រា ឡៀវពីក៏សរសើរដីវយើថា ដែលលោករិះគិតកំចាត់ចូចូចេញបាន ក្នុងគ្រានេះ អាណាប្រជានុរាស្ត្របានសេចក្ដីសុខក្សេមក្សាន្ត ព្រោះលោក ជាច្រើនណាស់ ៗ ដីវយើសួរឡៀវពីថា ដែលលោកយុំនាំទាហានមក តាំងនៅទីនេះ លោកគិតនឹងទៅវាយយកស្រុកឡាំកុនឬអ្វី? ៗ ឡៀវពី ថា តាមពាក្យដែលខុនបេងឲ្យប្រាប់ទៅដីវយើថា ដែលខ្ញុំលើកមកតាំង នៅទីនេះ ព្រោះគិតថាលោកនឹងលើកទ័ពទៅវាយស្រុកឡាំកុន ខ្ញុំនឹង លើកទាហានទៅជួយជាការរហ័សផង បើលោកមិនទៅទេ ខ្ញុំគិតថា

នឹងលើកទៅវាយស្រុកឡាំកុន ជូនលោកមិនបាច់ឲ្យលោកព្រួយក៏បាន ។ ដីវយីឮដូច្នោះ ក៏អស់សំណើចហើយថា ខ្លួនខ្ញុំជាជាតិទាហាននៅស្រុកកាំងតាំង ខ្ញុំក៏គិតមកជាដកបថា នឹងលើកទ័ពទៅវាយយកអាណាខេត្រខាងទិសឧត្តរ ឲ្យជាបំណាច់ថ្វីដៃជាមុន តែទទួលបួបលើកកងទ័ពចុះមកវាយយកខេត្រទ័ណ្ឌ ខាងទិសទក្សិណគ្រានេះ បានជាខ្ញុំនៅចាំតស៊ូច្បាំងនឹងបួបទាល់តែបែករត់ទៅវិញ ខ្ញុំក៏ខាតបង់ស្បៀងអាហារនឹងរបស់ទ្រព្យដែលត្រូវការបំណាយក្នុងសង្គ្រាមច្រើនណាស់ ឯស្រុកឡាំកុនគ្រានេះ បីដូចជានៅក្នុងកណ្ដាប់ដៃខ្ញុំហើយ បើខ្ញុំប៉ងយកពេលណាក៏បានដោយងាយណាស់ ហេតុម្ដេចលោកថាខ្ញុំនឹងមិនយកវិញ ។ ឡៅពីថា កាលបួបបែកទៅនោះ បានចាត់ហោយិនឲ្យទៅឈររក្សាស្រុកឡាំកុន ហើយទុកទាហានសុទ្ធតែមានថ្វីដៃ ឲ្យទៅរក្សាគយតាមច្រកផ្លូវគ្រប់អន្លើ ឯហោយិននោះ ក៏មានកំឡាំងក្លៀវក្លាហានណាស់ ខ្ញុំក្រែងលោកទៅធ្វើការនោះមិនបានដូចបំណងគិត ។ ដីវយីថា បើខ្ញុំវាយយកស្រុកឡាំកុននោះមិនបានទេ ឲ្យលោកទៅវាយយកចុះ ។ ឡៅពីឮដូច្នោះ ក៏ឆ្លើយថាដែលលោកមានប្រសាសន៍ដូច្នេះ ខ្ញុំសុំឲ្យឡោសុកនឹងខុងបេងដែលមកជួបជុំ
៧ ក្នុងទីនេះ ជួយជាបន្ទាល់សាក្សីដឹងផងចុះ បើអំណើះតទៅមុខ ដីវយីប្រែពាក្យសំដីវិញយ៉ាងម្ដេច ខ្ញុំត្រូវយកអ្នកទាំង ២ ហើយ ។ ដីវយីថា

ខ្ញុំកើតមកជាប្រុសបានចេញនិយាយថាម្តេចហើយ  មិនត្រឡប់កែប្រែវិញទេ ។ ខុនបេងក្លែងថា  ជីវយីនេះ បើនឹងចរចាអ្វីក៏រមែងពិតប្រាកដណាស់ បើដូច្នោះត្រូវឲ្យជីវយីទៅវាយយកស្រុកឡាំគុនជាមុនចុះ  បើក្រងាយប្រការម្តេច សិមឡៅពីលើកទៅធ្វើការជាក្រោយ ។ ជីវយីនឹងឡៅស៊ុកក៏លាឡៅពី ខុនបេង ចុះទូកត្រឡប់ទៅ ។

ឡៅពីនិយាយនឹងខុនបេងថា ឯការដែលជីវយីទៅវាយស្រុកឡាំគុននោះ មុខជានឹងបានជាប្រាកដ ខ្ញុំនៅគិតព្រួយមួយយ៉ាងថា សព្វថ្ងៃនេះខ្លួនយើងនឹងរកស្រុកនៅសំណាក់អាស្រ័យគ្មានសោះ  បើដូច្នោះនឹងត្រូវគិតដូចម្តេច? ។ ខុនបេងថា ពីដើមខ្ញុំបាននិយាយជំពបលោក ឲ្យទទួលយកស្រុកកេងជីវទុកជាទីអាស្រ័យ ដើម្បីនឹងគិតការតទៅ លោកមិនបេះជឿស្តាប់ពាក្យខ្ញុំសោះ គ្រានេះលោកគិតឃើញហើយឬ បានជានិយាយថាព្រួយចិត្តដូច្នេះវិញ ។ ឡៅពីថា កាលពីដើម លោកបាននិយាយមែនហើយ ដែលខ្ញុំមិនព្រមយកស្រុកកេងជីវទុកនោះ ព្រោះហេតុថាជាស្រុករបស់ឡៅពៀវ ឥឡូវស្រុកកេងជីវត្រឡប់បានទៅបូឆូវិញ  ខ្ញុំនឹងរិះគិតវាយយកឲ្យបាន ។ ខុនបេងថា លោកកុំបីព្រួយឡើយ ចូរបង្អង់ឈប់ឲ្យជីវយីវាយយកស្រុកឡាំគុនឲ្យបានសិន  ខ្ញុំនឹងរិះគិតកលឧបាយមិនឲ្យរវល់ដល់ទាហានទាំងពួង នឹងឲ្យបានស្រុកឡាំគុនដោយងាយ ។ –

ទៀតពីសួរថា លោកនឹងរិះគិតប្រការម្ដេច? ។ ខុនបេនថា លោកកុំអាលសួរសិនឡើយ ក្រោយសឹមដឹង ទៀតពីមានអំណរពន់ប្រមាណណាស់ មិនបានសួរតទៅទៀត ។

ឯជីវយីនឹងឡោសុកលុះវិលទៅដល់បន្ទាយ ឡោសុកក៏សួរជីវយីថា ហេតុម្ដេចបានជាលោកនិយាយនឹងទៀតពីថា បើលោកវាយយកស្រុកឡាំគុនមិនបាន ថាឲ្យទៀតពីវាយយកស្រុកឡាំគុនវិញនោះជាយ៉ាងម្ដេច? ។ ជីវយីថា ដែលខ្ញុំថានឹងទៀតពីយ៉ាងនោះគឺជាពាក្យបញ្ឆោតទេតើ ព្រោះខ្ញុំថាឲ្យទៀតពីមានចិត្តក្លៀវកំរើកឡើង ហើយថាគ្រានេះ យើងនឹងលើកទៅវាយយកស្រុកឡាំគុន តើនរណានឹងទទួលអាសាចេញទៅជាទ័ពស្រួចៗ ជីវយីមឆ្លើយថា ខ្ញុំបាទសុំអាសាលើកទាហានជាកងមុខទៅមុន ។ ទើបជីវយីបើកទាហាន ៥ ពាន់ ឲ្យឈីសេង, គេងហងទៅជាមួយនឹងជីវយីម ហើយបង្គាប់ថាឲ្យស្រួតលើកធ្វងទន្ទេហ៊ានតុទៅមុនចុះ យើងនឹងលើកកងទ័ពហ៊ុងទៅតាមជាក្រោយ ជីវយីមនឹងឈីសេង, គេងហងក៏លើកទាហាន ៥ ពាន់ចេញទៅ លុះទៅដល់គយអ៊ុឡេង ឈីសេង, គេងហងក៏លើកគ្នាចូលច្បាំងកាប់យកគយនោះមិនបាន ទើបនាំទាហានពង់ផ្ទុំគយទៅជិតទៀបស្រុកឡាំគុនហើយ ក៏ឲ្យតាំងបន្ទាយនៅប្រចាំទីនោះ ។

ខណៈនោះបំរើសេះចូលទៅប្ដឹងបោយិនថា ឥឡូវកងទ័ពស្រុកកាំង

តាំងលើកមកច្បាំងទៀតហើយ តាំងបន្ទាយនៅជិតស្រុកយើងនេះ ៗ ចៅពិនឮដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា ឥឡូវដីវយើប្រើឈើសេងគេងហង លើកទ័ពមកប៉ងធ្វើឲ្យអន្តរាយស្រុកយើង ឯស្បៀងអាហារដែលមានក្នុងស្រុកនេះក៏ច្រើន យើងត្រូវតែការពាររក្សាស្រុក ទុកខាងក្នុងកុំឲ្យសត្រូវចូលមកបាន បើយូរទៅសត្រូវគង់នឹងដាច់ស្បៀងលើកទៅឯង ៗ ងីវឃឹមថា ដែលនឹងតាំងរក្សាស្រុកតែពីខាងក្នុងឲ្យសត្រូវដាច់ស្បៀងនោះសត្រូវក៏នឹងបានចិត្ត, ប្រការ ១ ទៀត ទាហានរបស់យើងក៏គង់មានគិតតូចចិត្តថា យើងខ្លាចញញើត ខ្ញុំនឹងសុំអាសាលើកទាហាន ៥០០ ចេញទៅតទល់ការពារ ចៅពិនយល់ឃើញត្រូវ ក៏ចាត់ចែងទាហាន ៥០០ ឲ្យ ឯងីវឃឹមក៏លើកទាហាន៥០០ នោះចេញទៅច្បាំងនឹងគេងហងឃើញដូច្នោះក៏ទាញសេះបន្ទន់ឈប់ ហើយប្រកាសប្រាប់ទាហានទាំងពួងឲ្យចោមឡោមព័ទ្ធងីវឃឹមទុកឲ្យជាប់ ងីវឃឹមក៏ស៊ូច្បាំងនៅក្នុងចំណោមទាហានដោយក្លៀវក្លា ៗ

ឯចៅពិននៅលើសើនបន្ទាយ ឃើញគេងហងឡោមព័ទ្ធងីវឃឹមនៅក្នុងចំណោមដូច្នោះ ក៏តែងខ្លួនពាក់ក្រោះឡើងសេះនាំទាហានប្រហែល ៣០០ ស្រូតចេញវាកទ្វារស្រុក ទំលុះការទ័ពសត្រូវចេញទៅ ដើម្បីនឹងជួយងីវឃឹម ៗ ឈើសេងឃើញដូច្នោះ ក៏បរសេះចូលតច្បាំងនឹងចៅពិន

យូរណាស់ ឈីសេងទល់ពុំបានក៏ញាក់សេះថយតទៅ ។ ហោយិនក៏នាំងីវយឺមចេញមកបានពីក្នុងចំណោម លុះក្រឡេកឃើញទាហានដែលសល់តាមចេញមកប្រហែល ៩០ នាក់ ហោយិនក៏នាំងីវយឺមត្រឡប់វិលទៅតដៃវិញ ប៉ននឹងសងសឹកទាហានទាំងពួង ។ ឯហោស៊ុននៅលើសើន ក្រឡេកឃើញហោយិនលើកចេញទៅច្បាំងជាប់ដៃគ្នា ក៏ឡើងសេះកាន់លំពែងនាំទាហានជំនួយចូលទៅជួយប្រឡូកគ្នាជាប្រឡំបល់ បានចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើន ។ ឯងីវយឺម, ឈីសេង, តេងហង លុះតទល់ពុំឈ្នះ ក៏នាំទាហានដែលសល់នោះថយទៅ ហោយិនក៏មានជ័យជំនះ ហើយនាំហោស៊ុននឹងងីវយឺម នូវអស់ទាហានត្រឡប់ចូលទៅស្រុកវិញ ។

កាលងីវយឺម លើកទាហានមកជួបនឹងកងទ័ពងីវយី ក៏ពណ៌នាសេចក្ដីដែលបានទៅធ្វើការសង្គ្រាម ហើយបែកទ័ពត្រឡប់មកនោះ ឲ្យងីវយីស្ដាប់គ្រប់ប្រការ ។ ងីវយីក្រោធខឹងណាស់ បង្គាប់ឲ្យទាហានយកខ្លួនងីវយឺមទៅសម្លាប់ ទីប្រឹក្សានឹងទាហានទាំងពួងក៏នាំគ្នាអង្វរសុំទោសងីវយី ៗ ក៏លើកទោស ហើយប្រមូលទាហានលើកទៅតាំងបន្ទាយភ្ជាប់គ្នាឯស្រុកឡាំគុននោះ ខ្ញុំយល់ឃើញថាមិនត្រូវទេ ព្រោះហោយិនឲ្យហោហងជាប្អូន លើកទាហានទៅតាំងបន្ទាយនៅស្រុកអ៊ីឡេង ឥឡូវកងទ័ពយើង លើកកងចូលទៅហួសគយអ៊ីឡេងហើយ បើហោហងដឹង

គឺនឹងលើកមកវាយខ្ទប់ ខ្ញុំនឹងសុំអាសាលើកទៅវាយគយអ៊ីឡេង ឲ្យទាហានពោហង់បែកខ្ញែកគ្នាសិន រួចសឹមលើកចូលទៅតាំងបន្ទាយភ្ជាប់ជិតគ្នានឹងស្រុកឡាំគុន ដើម្បីនឹងធ្វើសង្គ្រាមតទៅ ។ ជីវយើយល់ឃើញត្រូវ ក៏ចាត់ទាហានឲ្យកាំឡេង ៣ ពាន់ ។ កាំឡេងក៏លើកទាហានស្រួតរូតចេញទៅជិតគយអ៊ីឡេង ។

បំរើសេះក៏ចូលទៅឲ្យដំណឹងពោយិនថា ឥឡូវជីវយើប្រើកាំឡេងលើកទ័ពទៅវាយគយអ៊ីឡេងហើយ ។ ពោយិនឮដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា ត្រូវគិតយ៉ាងម្តេច? ។ ត័នកៀវថា បើនឹងបង្អង់ទុកឲ្យយូរក៏នឹងខូចគយអ៊ីឡេងជាប្រាកដ បើគយនោះខូចហើយ ស្រុកឡាំគុនក៏យើងរក្សាការពារមិនឈ្នះ ។

(នៅមានត)

# ស្បែជអៀវ

## លោក ញង-សឿង រៀបរៀង

មានសេចក្ដីដំណាលថា តាំងពីយូរឆ្នាំណាស់មកហើយ មានលោកគ្រូសង្ឃរាជ១ អង្គគង់គ្រប់គ្រងវត្តមួយ ។ លោកគ្រូនោះមានអំណាចកាចណាស់ ។ ក្នុងការប្រដែប្រដៅសិស្សគណ, លោកតែងប្រើតែរំពាត់នឹងដំបងព្រនង់ជាជំនួសទណ្ឌកម្មក្នុងច្បាប់វិន័យ ។ លោកតែងមានថេរដីកាថា ទណ្ឌកម្មព្រះមិនឈ្នះទណ្ឌកម្មលោកទេ ។ កិច្ចសាមណេរនឹងក្មេងវត្តទាំងអស់ ខ្លាចលោកជាងយក្ស មិនដែលហ៊ានមើលចំព្រះភក្ត្រលោកដល់ម្ដងណាសោះឡើយ ។ នៅកុដិលោកមានបំពង់ឫស្សីធំមួយ បោះដែកគោលភ្ជាប់នឹងសសរ ហើយដាក់រំពាត់ផ្ដៅនឹងឫស្សីគ្រប់ធុន មានតាំងពីប៉ុនចង្កើះរហូតដល់ប៉ុនមេដៃមេជើង ។ ពល់តែពេលដែលលោកគ្រូវាយ, សិស្សណាមានកំហុស សិស្សនោះត្រូវលូនចូលទៅថ្វាយបង្គំរំពាត់ក្នុងបំពង់នោះ ៣ដង ហើយសុំអញ្ជើញដោយពាក្យថា " ខ្ញុំសុំអញ្ជើញលោកទៅជួយកាត់សេចក្ដី " រួចហើយក្រោកឈរឡើងសំឡឹង ជ្រើសរើសតាមស្វ័គ្រចិត្តរបស់ខ្លួន ស្រឡាញ់ធុនណា ទើបដកហូតធុននោះកាន់ទ្រដោយដៃទាំងពីរយកទៅប្រគេនលោកភ្លាម ។ កាលណាលោកបានវាយរួចហើយ សាមីខ្លួនត្រូវទទួលរំពាត់ពីលោកដោយដៃទាំងពីរយកទៅស៊កទុកក្នុងបំពង់

វិញ ថ្វាយបង្គំរំពាត់នោះ ៣ ដងទៀត ទើបថយចេញទៅ ៗ លស់ថ្ងៃតិចណាស់ ដែលមិនត្រូវរំពាត់នឹងមាត់ដេរពោលប្រដែប្រដៅ ៗ តែទោះបីយ៉ាងណា ក៏គង់នៅមានសិស្សគណចិលខូចខ្លះពុំខាន ដូចយើងធ្លាប់បានឮចាស់ ៗ និយាយមកហើយថា "គ្រូកាច សិស្សខូច" ៗ

ពិតដូច្នោះមែន, មានភិក្ខុ ២ រូបជាអ្នកចិលរបុលរប៉ូច ខូចមាត់កណាស់ខាងឯចំអកឡកឡឺយត្លុកកំប្លែង បាននាំគ្នាដាក់គោរម្យងារឲ្យលោកគ្រូសង្ឃរាជពីរបីយ៉ាងថា «មហាជម្ពូ-មហាក្រឡេកឆេះ-អគ្គីនេត្រ» ៗ

ក្នុងពេលដែលលោកគ្រូសង្ឃរាជ មានការនិមន្តចេញទៅកាន់ទីឆ្ងាយពីវត្តម្ដងៗ, បណ្ដាភិក្ខុទាំងពីររូបនោះ ណាមួយតែងតែឡើងទៅលើកុដិលោកគ្រូសង្ឃរាជ ទៅអង្គុយត្រង់កន្លែងលោក ធ្វើឫកពាទឹកមុខនឹងសំដីសំដៅ ត្រាប់តាមដំណើរលោកគ្រូសង្ឃរាជ ហើយនិយាយមុតប្រាយត្លុកកំប្លែងលេងជាល្បែងផ្សេងៗ នាំឲ្យលោកសង្ឃឯទៀតៗ ព្រមទាំងក្មេងវត្តបោមពោមសើចគឹលៗ សប្បាយរីករាយ ជាឯកច្ឆន្ទ ៗ ពាក្យចាស់ថា "ឆ្មាមិននៅ កណ្ដុរឡើងរាជ្យ" ៗ មិនតែប៉ុណ្ណោះទេ ភិក្ខុទាំងពីររូបនោះចូលចិត្តណាស់ទៅទៀតខាងលេងល្បែងអៀវគ្នា ៗ រាល់តែពេលយប់ដែលចេញពីសូត្រធម៌ថ្វាយបង្គំព្រះក្នុងព្រះវិហារ , ភិក្ខុចិលទាំងពីរ តែងព្រួយតប្រគោងជិះកអៀវគ្នា ធ្វើសេះម្ដងម្នាក់តាំងពីដំណើរ

ព្រះវិហាររហូតដល់កុដិរបស់ខ្លួនជាធម្មតា ។ ក្នុងពេលយប់មួយនោះ ជាពេលខាងរនោច, នៅវេលាចេញពីសូត្រធម៌ក្នុងព្រះវិហារ, លោកគ្រូសង្ឃរាជដែលកាលពីមុនៗ ធ្លាប់តែចេញក្រោយគេ លោកបែរជានិមន្តចេញទៅដំណាលនឹងលោកបរិស័ទឯទៀត ៗ ដែរ ដោយលោកមានកិច្ចការនៅកុដិលោក ។ ពេលនោះ ស្រាប់តែភិក្ខុខិល ១ អង្គស្ទុះលោតក្អែត ទៅព្រយិតប្រគោងអៀវលោកគ្រូសង្ឃរាជ ដោយស្មានថាគូកនរបស់ខ្លួន ព្រោះកំពស់កំពពង់ពៅលោកគ្រូសង្ឃរាជ នឹងគូកននោះស្រដៀងៗគ្នា ប្លែកតែលោកគ្រូសង្ឃរាជលោកចាស់ជាងប៉ុណ្ណោះ, ដៃទាំងពីរលូកព័ទ្ធចាក់ស្រេះរឹតកលោកគ្រូសង្ឃរាជយ៉ាងតឹង ជើងទាំងពីរព័ទ្ធបង្កេះពាត់ទៅខាងមុខប្រជុំចួបគ្នាត្រង់ផ្ចិតហើយកេវកៀបត្បៀតប្រទាក់គ្នាយ៉ាងមាំ រួចហើយក៏តាំងគោះក្បាលជង្គង់ទាំងសងខាងរបស់ខ្លួន ត្រង់ចង្កេះលោកគ្រូសង្ឃរាជព្រមទាំងស្រែកបណ្ដើរផងថា « អៀវ ៗ អាចំប៉ា! អៀវ ៗ! មើលអាចំប៉ា ម្ដងណេះលុនឲ្យលឿនបន្តិចមើល! " ។ ពេលនោះលោកគ្រូសង្ឃរាជទៅជាហួសបើគិត នៅស្ងៀមឈឹងឥតមាត់កមួយម៉ឺះសោះ បេះតែខំប្រឹងនិមន្តទៅទាំងត្រដេវត្រដរ ណាមួយពាំងបំពង់កខ្លាំងណាស់ ដកដង្ហើមរកតល់លែងចួបគ្នាម្ដង ៗ ទៅហើយ ណាមួយពាំងធ្ងន់ជាបល្វែងក្រោមណាស់ទៅទៀត រកតែកំសៀកយោលជើងបោះជំហាន ទៅ

មុខស្មើរពុំរួច ប៉ុន្តែលោកចេះតែខំប្រឹងទម្រើប ៗ ទៅទាំងជជ្រុលជជ្រក ដោយលោកគិតថា កុំឲ្យភិក្ខុនោះអៀនខ្មាស ព្រោះវាបានជាជ្រុលហួសទៅហើយ ៗ បន្តិច ៗ ឮសូរតែមាត់ "អៀវ អាចំប៉ា-អៀវ ! យើ ! អាចំប៉ាម្តងណោះ ក៏ដូចជាតគេះតគះអីខ្លាំងម្ល៉េះ ថ្ងៃនេះបែបស៊ីស្មៅមិនសូវឆ្អែតឬយ៉ាងម៉េច" ។ រីឯលោកបរិស័ទឯទៀតៗដែលនិមន្តចេញមកពីព្រះវិហារដែរនោះ ក៏មិនបានជាយកចិត្តទុកដាក់ចាប់ភ្លឹកនឹកនាក្នុងរឿងនេះប៉ុន្មាន ព្រោះស្មានថា គេអៀវគ្នាគេដូចធម្មតាមុន ៗ ។ លុះដិតទៅដល់មុខកុដិ , លោកគ្រូសង្ឃរាជ ហត់ក្រៃណានឹងហត់ អត់ទ្រាំតទៅទៀតមិនបានក៏ឈប់ហើយតាំងមានថេរដីកាទាំងអាក់អួលថា " ម៉េចអាប្រមឹតត្រយូវ[១]! អាឯងចង់ឲ្យអញងាប់ឬយ៉ាងម៉េច ! ។ ឮតែពាក្យប៉ុណ្ណោះ ភិក្ខុនោះភ្ញាក់ព្រើត ដោយស្គាល់ជាក់ជាមាត់លោកគ្រូសង្ឃរាជ មិនដឹងជាដៃនឹងជើងខ្លួន របូតចេញពីកនឹងចង្កេះលោកគ្រូសង្ឃរាជផង ៗ លោកគ្រូសង្ឃរាជ ស្រែកយ៉ាងបន្ទាន់បន្ទាប់នោះភ្លាម " ចាប់ ៗ ជួយចាប់វាឲ្យបាន" ។ ភិក្ខុសាមណេរក្នុងវត្តបានឮដូច្នោះក៏ស្រឡាំងកាំងផ្អើលឆោឡោឈូឆរ មកចោមរោមពិតទូលសួររឿងរ៉ាវលោកគ្រូសង្ឃរាជក្នុងពេលនោះភ្លាម ប៉ុន្តែមានអ្នកណារត់ទៅតាមចាប់បាន បើភិក្ខុនោះប្រាស់ក្រដីងរត់ភីងកែងជាប់គូថ លំហាងកាត់គុម្ពចេកកៀនកុដិ ប៉ុនព្យុះសង្ឃ្រកទៅខាងលិច

---

១ - ក្លាយមក ពីពាក្យ 'ម្រឹត្យុ' ( សេចក្ដីស្លាប់ ) ។

វត្ត បាត់ទៅហើយ; ហើយម្យ៉ាងទៀត គេពុំទាន់បានដឹងរឿងរ៉ាវយ៉ាង ណា ៗ នៅឡើយផង ។

ចំណែកលោកគ្រូសង្ឃរាជ កាលបានរួចពីកណ្ដាប់ដៃភិក្ខុចិលនោះ ហើយ ក៏ដាក់តូចស្រិចនៅលើកាំជណ្ដើរកុដិ ដង្ហក់ហ្ហូសខសៗ ប៉ុនគេ យោលខ្លួន; បែកញើសប៉ុនៗ គ្រាប់ពោត ហានិយាយជាដូចម្ដេចក៏ មិនកើត ។ តមក ១ ស្របក់ ទើបលោកមានថេរដីកាដាច់ ៗ ចាំងនៅ ហត់ហោប ៗ ហើយចាំងទាល់អាក់អន់ព្រះទ័យយ៉ាងហួសប្រមាណផងថា "ហ៊ឹះ ! អា... អានេះ ក៏... ក៏លេងឯងដល់ថ្នាក់តែម្ដងហើយ, ឆាន់[១] គាំងពីកើតមកដរាបដល់ចំណាស់ប៉ុណ្ណេះហើយ មិនដែលដល់ម្ល៉ឹងសោះ ទើបតែលើកនេះ យើអ៊ីនចុះខ្លាំង ធ្លាក់ខ្លួនទៅជាអាចំប៉ារបស់គេតែម្ដង — ឆាន់ទើបនឹងចុះផុតកាំជណ្ដើរវិហារបន្តិចមក ស្រាប់តែក៏លោតក្លូតគោងក អៀវឯងជាប់តែម្ដង — មានផ្លូវអីទៀត; បើក៏លេងវែកបំពង់កឯងកកល់ លឿនអណ្ដាតទៅហើយ; ណាមួយក៏កៀបគៀតក្ដៅឯងចាំងសងខាង យ៉ាងតឹងណែនគាំង រកតែឈានជើងស្ទើរពុំរួច ហើយមានចាំងធ្មៀតយក ក្បាលជង្គង់ក៏គោះត្រង់កណ្ដៀតទឹកឯងថែមទៀតផង; ក៏ឲ្យឯងលុនឲ្យ លឿន, រួចក៏ថាឯងស៊ីស្លៅមិនឆ្អែតពីថ្ងៃ បានជាកងបែបគេះគគះអស់

---

១ លោកគ្រូសង្ឃរាជភ្ញាក់ផ្អើលដើបតែងនិយាយ ទៅកាន់លោកបរិស័ទថា "ឆាន់" (ពាក្យ [illegible]) [illegible] ។

កំឡាំង ហ៊ុះ! ឆាន់ដឹងថាវាប្រឡំនឹងគូកនវាហើយ; តែប្រឡំនេះវាហួសប្រមាណណាស់ រិះៗ តែនឹងដាច់ខ្យល់ផាប់; ឆាន់មិនដឹងជាអាណាមួយ ព្រោះវាពោបអៀវគងពីក្រោយ រកតែងាកមើលមុខវាមិនកើតសោះ; ឆាន់ស្មានថា ប្រហែលជាអាម៉ប់ ឬអាមោឃហើយមើលទៅ ព្រោះឮថាអាពីរនាក់នេះវាចិលខូចណាស់ ចូលចិត្តលេងល្បែងអៀវគ្នាស៊េរីតែពលយប់ៗ ភិក្ខុសាមណេរទាំងអស់ក៏បានឆ្លើយស្របថា ពិតជាលោកម៉ប់ ឬលោកមោឃប្រាកដហើយព្រះតេជព្រះគុណ ព្រោះអ្នកទាំងពីរនាក់នេះ ដូចជាចិលជ្រុលបន្តិចហើយទានព្រោស! គេតែងតែលេងល្បែងអៀវគ្នាជាធម្មតា ៗ លោកគ្រូសង្ឃរាជបានបន្ទរដីកាទៅទៀតថា ឆាន់គុំថា គង់មានថ្ងៃណាមួយ ចាំពិតវាឲ្យធ្ងន់ដៃតែម្តងពីរឿងល្បែងព្រើលនេះ តែឥឡូវនេះ មិនទាន់ចាំងបានសំពងវាផង- វាលេងឯងមុនទ្រមមាតិកាទៅហើយ; ហ៊ុះ! អានេះអត់ទោសឲ្យវាមិនបានទេ គោងតែរកចាប់វាឲ្យបានចាំងយប់នេះ យកមកកចងព្យួរនឹងខ្សែរ៉ត់ សំពងវាឲ្យអស់ដៃពីរបីថ្ងៃ ហើយផ្សំកវាចោលឲ្យស្រឡះចេញទើបបាន ៗ គ្រានោះ លោកបរិស័ទខ្វះបានពិត្រទូលថា ខ្ញុំករុណាបានឃើញដែរ តែនឹកស្មានថា គេអៀវគ្នាគេដូចធម្មតាមុនៗ បានជាមិនអើពើនឹងយកចិត្តទុកដាក់អ្វីប៉ុន្មាន; រឿងនេះ ដូចជាតាស់បន្តិចដែរ ទើព្រះតេជព្រះគុណ ស្រែកឲ្យ..ដឹងខ្លួនតាំងពី

ដំបូងមកម្ល៉េះនោះ មិនដល់ទៅប៉ុណ្ណឹងសោះ ។ លោកគ្រូសង្ឃរាជតប ភ្លាមថា អីចឹងមែន ស្តាយណាស់ តែពេលនោះក៏ដូចជាយ៉ាងម៉េចមិនដឹង នឹកម្តងថានឹងស្រែកឲ្យគេដឹងខ្លួន នឹកម្តងទៀតថា កុំអាលមាត់... ណ្ហើយ ឥឡូវនេះ ក៏ជ្រុលហួសអស់ទៅហើយ; ចូរលោកទាំងអស់គ្នាប្រញាប់ ប្រញាល់ទៅជួយពិនិត្យរកឲ្យឃើញឆាប់ ៗ —ចូររកមើលអាទាំងពីរនាក់ នោះ តើអាណាគេបាត់ខ្លួន អាណាមួយនៅក្នុងវត្តនៅឡើយ; បើបាត់ អាណា គឺអានោះឯងហើយ ដែលក៏អៀវធាន់ —កាលណាបើបានដឹងការ ត្រឹមប៉ុណ្ណោះហើយ ចាំលែលកតទៅទៀត ។ ក៏ភិក្ខុសាមណេរទាំងក្នុងវត្ត ទាំងអស់ ក៏បាននាំគ្នាម្នីម្នាស្ទុះស្ទាទៅរកមើលឯកន្លែងលោកម៉ែបនឹងលោក មោយ តែរកមិនឃើញទាំងពីរនាក់ បានពិនិត្យឆែកឆេររកតទៅទៀត គ្រប់កុដិ សាលាទាំងអស់ក្នុងវត្ត ក៏មិនចួបប្រទះសោះ ទើបនាំគ្នាមក ក្រាបទូល លោកគ្រូសង្ឃរាជវិញតាមដំណើរ ។ លោកមានថេរដីកាថា ណ្ហើយ! បើមិនឃើញយប់នេះ ព្រឹកស្អែកគង់តែឃើញពុំខាន, តែគួរ ឲ្យឆ្ងល់ដែរថា បើអាមនុស្សមានកំហុសតែម្នាក់ទេ ម្តេចក៏បាត់ខ្លួនទៅទាំង ពីរនាក់ ។ លោកគ្រូសង្ឃរាជមានថេរដីកាតែប៉ុណ្ណោះហើយ ក៏និមន្ត ចូលទៅក្នុងកុដិលោកទៅ, តែក្នុងរាត្រីនោះ លោកសឹងមិនលក់សោះ ព្រោះលោកនឹកសព្វៗទៅ រឹងរឹតតែក្តៅឡើង ៗ ក្តៅក្រង់ "អៀវអាចំប៉ា

អៀវ !" ក្តៅណាស់ទៅទៀតត្រង់ដែល "តឹងបំពង់ករកកល់ផុតដង្ហើមម្តង ៗ" នោះឯង ។ ក្នុងពេលយប់នោះ ភិក្ខុសាមណេរដែលបានទៅកាន់កន្ទែងរៀងខ្លួនហើយ ក៏ប្រជុំជំនុំគ្នាសើចលាន់ៗ ថា នេះគឺជាកម្មពៀរវេរាតាមទាន់ ឲ្យផលក្នុងបច្ចុប្បន្នដល់ព្រះតេជព្រះគុណយើង ពីព្រោះលោកវាយគេខ្លាំងណាស់ គ្មានលស់ថ្ងៃណាសោះ ចំណែកម៉ប់នឹងមោយ ដែលល្អំងគេចបាត់ខ្លួនទាំងពីរនាក់ ក៏គឺបាបឲ្យផលទាន់ភ្នែកដែរ មកពីរបុលរប៉ូចខូចខាងឯលេងល្បែងអៀវគ្នា មិនសូវកោតក្រែងរអែង រគារដល់វិន័យសិក្ខា ជាយូរមកហើយ ។

ចំណែកលោកគ្រូសង្ឃរាជព្រឹកឡើងព្រលឹមស្រាងៗ លោកតើនឡើងចេញមកក្រៅ, ស្រាប់តែឃើញញោមប្រុសរបស់ភិក្ខុម៉ប់នឹងភិក្ខុមោយ អង្គុយបត់ជើងត្រង់កនហាលយ៉មុខកុដិ លោកក៏ធ្វើព្រះភក្ត្រក្រញូវហើយឥតភាកសួរអ្វីមួយម៉ាត់សោះ ដោយលោកស្មានថាប្រាកដជាភិក្ខុទាំងពីររូបនោះ បានទៅនិយាយពីងពញោមរបស់ខ្លួនពីល្ងាច ឲ្យចូលមកសុំលន់តួទោសនៃលោកហើយមើលទៅ ។ ឯបុរសទាំងពីរនាក់ក៏តាំងក្រាបថ្វាយបង្គំផ្ដិតផ្ដួងៗ ហើយអង្គុយប្រហោងប្រណម្យ ដោយមានទឹកមុខស្លុតក្រៀមទឹងស្ងៀមស្ងាត់ មិនទាន់ហ៊ានផ្ដើមពិត្រទូលសាកសួរអ្វីនៅឡើយ ព្រោះឃើញព្រះភក្ត្រលោកមិនស្រួល ៗ មួយស្របក់

ក្រោយដែលបានបឺតបារីស្លឹកសង្កែ បង្ហុយផ្សែងទ្រលោម ពីរ-បី សារួច ហើយ ស្រាប់តែលោកគ្រូមានថេរដីកាថា កុំបាច់នាំគ្នាមកអង្វរគេសុំទោសពៃរ៍អើ៖ ម្ល៉េះហើយ គ្មានអត់ឱនឲ្យអាណាទេ, តាមចិត្តក្ដៅ ចង់តែសំពងអាឌុ ជំនួសកូនឥឡូវហ្នឹងផង(១) ព្រោះឪពុកខូច បានជាជាប់ពូជមកកូនពាល ចុះចេញឲ្យឆាប់ៗ កុំមករ៉ៃ ៗ បុរសទាំងពីរនាក់ ភិតភ័យញ័ររន្ធត់ ម្នាក់ក្រោកឈរឡើងសំឡឹងរកមើលប្រករត់ តែម្នាក់ទៀត មិចភ្នែកជាសញ្ញាឲ្យអង្គុយមកវិញ ហើយក៏ប្រថុយទូលតបទាំងញញើញញ័រថា "សូមព្រះតេជព្រះគុណម្ចាស់មេត្តាអត់ទោស តើកូនរបស់សត្វជាខ្ញុំ(២) មានរឿងរ៉ាវទើងទោសកំហុសដូចម្ដេចខ្លះ ទានប្រោស?" ៗ លោកគ្រូសង្ឃរាជគំហក "កុំបាច់ធ្វើពើហាក់មិនដឹង ! ក្រែងពីយប់មិញបានជួបគ្នាដឹងរឿងរ៉ាវអស់ហើយតើ" ៗ ឧបាសក : "ករុណាទានប្រោស ! លោកទាំងពីរអង្គ បាននិមន្តទៅផ្ទះពីយប់មិញ បានប្រាប់រឿងរ៉ាវអស់ហើយអ៊ីចឹងមែន ទើបបានសត្វជាខ្ញុំទាំងពីរនាក់នាំគ្នាមកនេះ, តែរឿងដែលបានដឹងពីយប់នោះគឺជាការប្រសើរល្អណាស់ទានប្រោស; លុះដល់មកជួបព្រះតេជព្រះគុណផ្ទាល់ក្នុងពេលនេះ ក៏ស្រាប់តែប្រែត្រឡប់ទៅ

---

១- លោកគ្រូសង្ឃរាជដាន់ដើម មានអំណាចណាស់ អាចវាយដាំងពីកូនរហូតដល់ឪពុកម្ដាយក៏បាន ។ ២- ឧបាសកយើងពីដើមនិយាយជាមួយព្រះសង្ឃថា "សត្វជាខ្ញុំ" ។ សព្វថ្ងៃនេះ គេប្រើពាក្យថា "ខ្ញុំព្រះករុណា ដែលអានក្លាយមកទៀតថា "ខ្ញុំកូរណា" ជួរច្រេះវិញ ។

ជារឿងកំរមួយផ្សេងដែលនាំឲ្យកើតទុក្ខព្រួយខ្លាំងទៅវិញ" ។ លោកគ្រូសង្ឃរាជហាក់ដូចជាអន់ខ្វាល់បន្តិច ហើយសួរបញ្ជាក់ ដោយបន្ទូរសំឡេងថា "រឿងយ៉ាងម៉េចវិញ និយាយមកមើល" ។ ឧបាសកៈ "ពាន ទោស! ពីយប់មិញប្រហែលជាម៉ោងជាង១០ ទៅហើយ, លោកកូនម៉ប់នឹងលោកក្មួយមោយ បាននិមន្តទៅផ្ទះសត្វជាខ្ញុំទាំងពីរនាក់ហើយប្រាប់ថា ព្រឹកស្អែកនេះ ព្រះតេជព្រះគុណ- មានកិច្ចត្រូវនិមន្តទៅភ្នំពេញ សុំឲ្យសត្វជាខ្ញុំទាំងពីរនាក់រៀបចំគោរទេះ ស្រូតរូតឲ្យដល់មកវត្តនេះពីព្រលឹមស្រាង ៗ ដើម្បីជូនដំណើរព្រះតេជព្រះគុណទៅដល់ថ្នល់ឡាន; ថាព្រះតេជព្រះគុណ យកខ្លួនលោកទាំងពីរអង្គជូនទៅភ្នំពេញជាមួយដែរ លោកទាំងពីរអង្គ បានទាំងសុំបច្ច័យសម្រាប់ធ្វើសោហ៊ុយនឹងទិញអីវ៉ាន់នេះនោះខ្លះផង; សត្វជាខ្ញុំទាំងពីរនាក់ក៏បានប្រគេនបច្ច័យ តាមសមគួរ ហើយបានទាំងនិយាយទៀតផងថា មានសេចក្ដីត្រេកអរណាស់ ដោយបានព្រះតេជព្រះគុណមានមេត្តាអនុគ្រោះរាប់រកជាកូនជាចៅ; និមន្តទៅណាម្ដងៗ យកតាមជាប់ទៅជាមួយផង ។ លោកទាំងពីរអង្គ កាលបានទទួលបច្ច័យហើយ ក៏ចំរើនពរលាត្រឡប់មកវត្តវិញតាំងពីយប់មិញម្ល៉េះ, ចំណែកសត្វជាខ្ញុំ ពីយប់មិញនេះ មិនហ៊ានទទួលទានដំណេកសោះ ព្រោះខ្លាចក្រែងដេកជ្រុលហួសម៉ោងខកដំណើរព្រះតេជព្រះគុណ នាំគ្នា

ប្រញាប់ប្រញាល់ស្ទូតរូតតាំងពីមាន់រងាវម្ដង បានមកដល់ទី នេះតាំងពីនៅងងឹតព្រលឹម ម្ល៉េះ ទានប្រោស ! ទុះគោរទេះដាក់ទៅកៀនរបងខាងត្បូងកុដិ បានប្រុងប្រៀបរៀបចំ មានទាំងបង្ហាន់បង្ការតាមផ្លូវទុកជាស្រេច; សូមទានមេត្តាប្រោស ! រឿងរ៉ាវខាងសត្វជាខ្ញុំទាំងពីរនាក់មានតែត្រឹមប៉ុណ្ណោះ សូមទានជ្រាប" ។ ឧបាសកបានបន្តសំដីទៅទៀតថា ចំណែករឿងរ៉ាវខាងព្រះតេជព្រះគុណឯណោះ តើយ៉ាងណាវិញ បានជាកផ្ទុយគ្នាស្រឡះយ៉ាងនេះ? សូមទានមេត្តាពន្យល់សត្វជាខ្ញុំឲ្យបានដឹងផងទានប្រោស? ។ លោកគ្រូសង្ឃរាជ លោតែញញឹមបន្តិចហើយមានថេរដីកាថា "ហ៊ឹះ ! អីដូច្នោះវិញទេ អាត្មាស្ថាននេះខុសស្រឡះតែម្ដង ឮយ៉ា ! អាចោរនេះ វាលេងដើរស្មៀតច្រើនគន្ទាក់ណាស់តើ វាលេងឯងឯណោះទ្រមខ្លួនមួយធាក់រួចហើយ វាទៅកុហកបោកប្រាស់ញោមឯផ្ទះឯណោះមួយឈុតថែមទៀត ដើម្បីយកសោហ៊ុយធ្វើដំណើររត់ឲ្យបានឆ្ងាយ- ឃើអើ ! រឿងនេះ វីវរធំណាស់តើ ! បើដូច្នោះ ឃើញថាអត់ទុនឲ្យវារួចខ្លួនមិនបានទេ ព្រោះវាមានទោសដល់ទៅពីរជាន់ តោងតែប្រឹងប្រែងតាមរកវាទាំងពីរនាក់ឲ្យឃើញជាដាច់ខាត ។

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងទាក់ទងដោយការស្ថាបនាប្រាសាទអង្គរវត្ត

### លោក ញ៉ែម-ខឹម រៀបរៀង

កាលពី ព.ស. ៦០០ មានចិនម្នាក់ឈ្មោះ លិម-សេង រស់នៅក្នុងខេត្តសៀងហៃ ។ លិម-សេង អាយុចំនួន ៤០ ឆ្នាំ ។ គាត់ជាមនុស្សកំសត់ទុគ៌តណាស់, គាត់បានខ្ចីប្រាក់អ្នកជំនួញម្នាក់ ចំនួន ៤ ណែន ហើយទៅនៅស៊ីឈ្នួលបំរើអ្នកម្ចាស់បំណុលនោះ ។ ម្ចាស់បំណុលបានគម្រូវឲ្យគាត់កាប់ឆ្ការព្រៃមួយកន្លែងនៅក្បែរមាត់ទន្លេ ដើម្បីដាំដំណាំ ។ នៅរដូវដែលបុប្ផជាតិទាំងឡាយត្រូវរីកផ្កា, លិម-សេង តែងបេះផលដំណាំដែលគាត់បានដាំជារាល់ថ្ងៃ យកទៅជូនម្ចាស់គាត់ ។

ថ្ងៃមួយ, មាននាងទេពធីតា ៤ នាក់ស្ថិតនៅឯប្រាសាទព្រះឥន្ទ្របានហោះមករត់លេងប្រឡែងគ្នាឯស្ថានក្រោម, ហើយបានឃើញផ្កានៅក្នុងសួនច្បារតាលិម-សេង រីកព្រោងព្រាតស្គុះស្គាយ ក៏បបួលគ្នាចូលទៅក្នុងសួននោះ ។ ទេពធីតាម្នាក់ឈ្មោះ ទិព្វសុតាចន្ទ ក៏បានបេះផ្កាលិម-សេង អស់ ៦ ទង ព្រោះផ្កានោះមានក្លិនក្រអូបសាយល្អ ។ ចំណែកទេពធីតាឯទៀត បានដើរលេងពាសពេញក្នុងសួនច្បារនោះដែរ

តែឥតបានកាច់ផ្កាលេងទេ ។

លុះត្រឡប់ទៅដល់ស្ថានទេវតាវិញ, ទេពធីតាសួគត្រង់ក៏បានទូល ព្រះឥន្ទ្រពីរឿងនាងទិព្វសុគាចន្ទលួចបេះផ្កាគេ ។ ព្រះឥន្ទ្រក៏ទ្រង់ សួរទៅនាងមានទោស ហើយផ្តន្ទាទោសថា ត្រូវឲ្យចុះមកនៅស្ថាន កណ្តាលរស់នៅជាមួយមនុស្សលោក ចំនួន ៦ ឆ្នាំ នឹងត្រូវបានទៅជា ប្រពន្ធ តាលិម សេងនោះ ។

នាងទិព្វសុគាចន្ទ ខ្មាសគេផង អស់សង្ឃឹមក្នុងចិត្តផង, ក៏ហោះ ចុះមកស្ថានក្រោមជួបនឹងតាលិម.សេង ហើយនិយាយប្រាប់គាត់ថា នាងបានលួចបេះផ្កាគាត់អស់ ៦ ទង ឥឡូវ ព្រះឥន្ទ្រដាក់ទោសឲ្យ នាងចុះមកធ្វើជាប្រពន្ធចំនួន៦ ឆ្នាំ ។

- លិម.សេងក៏ឆ្លើយថា "ខ្ញុំក្រណាស់ ខ្ញុំពុំអាចទទួលនាងធ្វើ ជាប្រពន្ធបានទេ ទៅហ្វាយខ្ញុំចិត្តអាក្រក់ណាស់ គាត់ឲ្យបាយខ្ញុំ ទទួលទានល្មមគ្រាន់តែរស់ ។

- យ៉ាងម៉េចក៏ដោយ (នាងទេវីឆ្លើយ) ចាំខ្ញុំជួយលោកតា ។ ខ្ញុំនឹងបង្រៀនវិជ្ជាសិល្បៈលោកតា ដែលគ្មាននរណាមួយចេះ ។ បើ លោកតាមិនព្រមទទួលខ្ញុំធ្វើជាប្រពន្ធ, តើធ្វើម្តេចខ្ញុំនឹងបានប្រតិបត្តិតាម ការវិនិច្ឆ័យនៃព្រះឥន្ទ្រ ។ សូមលោកតាអាណិតទៅផង ។

គាលិម-សេង ក៏ព្រមទទួលនាងទិព្វសុគាចន្ទ មកនៅជាក្រុមញាតិគាត់ ។ គាត់ពេញចិត្តនឹងនាងទេវីនេះណាស់ព្រោះជាស្ត្រីមានរូបសម្ផស្សល្អលើសស្រីនានា ។ មិនយូរប៉ុន្មានគាត់ក៏មានសេចក្ដីស្នេហាលើរូបនាង ។

នាងទិព្វសុគាចន្ទ កាលបើបានមករស់នៅជាមួយលោកគាយើងយូរមក, សង្កេតឃើញនូវសេចក្ដីលំបាកវេទនានឹងចិត្តស្មោះត្រង់របស់គាត់, ក៏កើតមានចិត្តអាណិតគាយើងជាខ្លាំង ។ ទើបនាងសួរទៅគាយើងថា :

– គាបានខ្ចីលុយគេអស់ប៉ុន្មាន ?

ប្រាំមួយណែន !

– កាលបើលោកគាខ្ចីគេតែ ៦ ណែនដូច្នេះ លោកគានឹងត្រូវរស់នៅតែម្នាក់ឯងទេ ? ។ ឥឡូវនេះ, សូមលោកគាទៅខ្ចីគេឲ្យបាន ៤ ណែនថែមទៀត, ចៅនឹងបានមកនៅបំរើគេជាមួយលោកគាផង ។ លុយដែលយើងនឹងទៅខ្ចីគេថែមទៀតនោះ យើងនឹងយកចាយវាយប្រើការឲ្យបានផលប្រយោជន៍ច្រើន ។

លិម-សេង ក៏បានទៅខ្ចីលុយពីម្ចាស់បំណុលខ្លួនបាន ៤ ណែនទៀត យកមកឲ្យនាងទិព្វសុគាចន្ទ ។ នាងទិព្វសុគាចន្ទ ក៏សុំឲ្យលោកគាទៅរកទិញសូត្រឲ្យអស់តំឡៃចំនួន ៤ ណែនប្រាក់ យកមកឲ្យនាង ។

តាយើងក៏ទិញបានសូត្រនៅជាសំបុកចំនួន២០នារៀ ។ នាងទិព្វសុតាចន្ទក៏រវៃសូត្រនោះ ហើយត្បាញធ្វើជាសំពត់ផ្សេង ៗ មានសំពត់ប៉ាក់ជារូបស្លឹកឈើ, រូបសត្វ នឹងជារូបគំនូរផ្សេង ៗ ទៀតច្រើនកប់ពុំអស់ ។ នាងបានត្បាញសំពត់ល្អ ៗ ណាស់ ដែលសម័យនោះគ្មាននរណាធ្វើបានដូចនាងឡើយ ។ កាលបើត្បាញបានសំពត់ច្រើនហើយ នាងក៏ប្រើប្ដីនាង ឲ្យយកសំពត់ទាំងនោះទៅជូនចៅហ្វាយខ្លួន ។ អ្នកម្ចាស់បំណុលយកដៃស្ទាបសំពត់មើល មានសេចក្ដីស្ងើចក្នុងចិត្តក្រៃលែង, ព្រោះគ្មាននរណាមួយអាចចេះត្បាញដូច្នេះបានឡើយ ។ អ្នកម្ចាស់បំណុលពោលសរសើរលោកតា លិម-សេង ជាច្រើន, ហើយដោយអំណាចគាត់កើតសេចក្ដីសប្បាយពន់ពេក, គាត់ក៏បានឲ្យលុយ៥០ណែនទៅតា·យើង, ព្រមទាំងឈប់ទាយកវិញ នូវប្រាក់ដែលតាយើងបានជំពាក់គាត់ពីពេលមុនមកទាំងអម្បាលម៉ាណ ។ មិនតែប៉ុណ្ណោះ, អ្នកម្ចាស់បំណុលបានទាំងបញ្ជូនមនុស្សឲ្យទៅរៀនវិជ្ជាត្បាញសូត្រពីនាងទិព្វសុតាចន្ទផង ។ នាងទិព្វសុតាចន្ទក៏បានទិញសំបុកសូត្រ (សំបុកដង្កូវនាង) ជាច្រើនហាប យកមកបង្រៀនសិស្សចៅហ្វាយតា យើងឲ្យរវៃ ឲ្យត្បាញរាល់ថ្ងៃ ។

មិនយូរប៉ុន្មាន តា លិម-សេង ក៏បានឡើងទៅជាអ្នកមានម្នាក់មានអំណាច នឹងមានគេគប់រកជាច្រើន ។

ចំនួនជាមួយឆ្នាំក្រោយមក , នាងទិព្វសុគាចន្ទ បានបុត្រប្រុសម្នាក់ ។ ទារកនេះរពិសពន់ពេក នៅពេលដែលវាចេះវារ វាបានជីកដីធ្វើជាកំពែងការពារ, ពេលចេះអង្គុយ វាគូរលេងនៅដីធ្វើជារូបសត្វ, រូបមនុស្ស គឺថាវាចូលចិត្តតែគូរដីលេងឥតចេះខ្ជិល, ឥតឈប់ឈរ ។ វាជាក្មេងពុំចេះនៅស្ងៀមមួយស្របក់បានឡើយ ។ អាស្រ័យហេតុដូច្នេះ ម្ដាយក៏ដាក់ឈ្មោះថាព្រះពិស្ណុការ(១) ។

លុះកុមារបានវ័យចំនួន៥ ឆ្នាំ, នាងទិព្វសុគាចន្ទ ក៏ត្រូវផុតកំណត់ ៦ ឆ្នាំ, ដែលព្រះឥន្ទ្របានផ្ដន្ទាទោសតម្រូវឲ្យនាងមកធ្វើជាប្រពន្ធ តា លិម-សេង ។ ដូច្នេះ, នាងក៏បេះផ្កាចំនួន ៦ ទង យកទៅដាក់នៅលើខ្នើយដេក រួចក៏ហោះទៅកាន់ស្ថានព្រះឥន្ទ្រវិញ ។

លុះដល់ពេលបាយ, តា លិម-សេង ដោយមានសេចក្ដីងឿងឆ្ងល់មិនឃើញប្រពន្ធចេញមកញ៉ាំបាយ, ក៏ចូលទៅក្នុងបន្ទប់ឃើញផ្កា៦ ទង ដាក់ចោលលើខ្នើយក៏យល់ន័យនេះមួយរំពេច ។ តា លិម-សេងក៏យំទួញសោករលឹកប្រពន្ធក្មេង ដែលគេរត់ចោលគាត់បាត់ទៅ ។ អ្នកជិតខាងបានដឹង គេជួយអាណិតគាត់គ្រប់ ៗ គ្នា ។ ចំណែកព្រះពិស្ណុការវិញ បានរត់រកម្ដាយគ្រប់ច្រកល្ហកទាំងអស់ បង្ហូរស្រែក

១ ព្រះវិស្សុកម្ម ។

ហៅលាន់ឮរំពង ហើយយំទួញសោកបោកខ្លួនជាមួយឪពុក ។

គ្រានោះ នៅក្នុងព្រះរាជអាណាចក្រកម្ពុជា ព្រះបាទប្រទេសរាជ ទ្រង់សោយព្រះទីវង្គតទៅ ព្រះអង្គឥតមានព្រះរាជបុត្រាបុត្រី១អង្គ ដើម្បីសោយរាជ្យស្នងព្រះអង្គទេ ។ ព្រះញាតិវង្សព្រះបាទថោងក៏ផុតរលត់ត្រឹមនេះ ។ គេសង្កេតមាននៅសល់តែក្រុងហ៊្វូ នឹងក្រាយហ៊្វូ ពីរនាក់ប៉ុណ្ណោះទេ ដែលជាអ្នកជាប់លោហិតក្សត្រ ។ កាលបើដូច្នេះ, ព្រះរាជបល្ល័ង្កក៏ត្រូវស្ងិតនៅទំនេរ ។

ដំណាលពីបុរសកំសត់ម្នាក់ដែលប្រកបរបរចិញ្ចឹមជីវិតដោយកាប់ឧសលក់នៅក្នុងព្រៃ ។ ថ្ងៃមួយ, នៅពេលដែលបុរសនោះកំពុងប្រកបកិច្ចការខ្លួនតាមធម្មតា ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង បុរសបានរត់ទៅជ្រកនៅក្នុងខ្ទមអ្នកតាមួយ ។ និយាយពីព្រះឥន្ទ្រាធិរាជ ដែលជាស្តេចនៃទេវតា នៅពេលនោះព្រះអង្គបាននិម្មិតខ្លួនធ្វើជាមាន់គកពីរ មួយពណ៌សមួយពណ៌ខ្មៅ ។ មាន់ខ្មៅមកទំលើសសរកន្ទោងនៃខ្ទម មាន់សមកទំលើដំបូលខ្ទម ។ មួយសន្ទុះមក មាន់សរងាវ ។ ឯមាន់ខ្មៅដែលចេះនិយាយភាសាមនុស្សក៏និយាយថា: "នរណាហ៊ានមករងាវលើក្បាលអញដូច្នេះ? តើអ្នកឯងមានឫទ្ធិអំណាចយ៉ាងណាទៅ ?

-យើងមានឫទ្ធិអំណាចខ្លាំងណាស់ (មាន់សឆ្លើយ) ។ បើសិនជា

នរណាមួយបានស៊ីសាច់ខ្ញុំ អ្នកនោះនឹងបានឡើងជាស្ដេចផែនដី ។

មាន់ខ្មៅក៏ឆ្លើយថា:

"បើសិនជាមនុស្សប្រុសណាមួយស៊ីក្បាលខ្ញុំ អ្នកនោះឯងនឹងបានជាស្ដេចសង្ឃ ។ បើសិនជាមនុស្សស្រីណាស៊ីសាច់ភ្លៅខ្ញុំ ស្រីនោះនឹងបានជាអគ្គមហេសីស្ដេច ។ បើសិនជាជនប្រុសណាស៊ីសាច់ទ្រូងខ្ញុំ ជននោះនឹងបានសោយរាជ្យ ។ ដូច្នេះ, កុំមើលងាយខ្ញុំឲ្យសោះ ! "

តមក, មាន់សក៏ហើរបាត់ទៅ ឯមាន់ខ្មៅនៅទំនឹងសសរកន្ទោងដដែល: ប្ដីសក៏សត់ក៏លប ៗ ចូលទៅចាប់មាន់ខ្មៅបាន ហើយសម្លាប់ភ្លាមយួរយកទៅផ្ទះខ្លួន ។ ប្ដីសក៏និយាយការសម្ងាត់នេះប្រាប់ប្រពន្ធ។ មានសេចក្ដីរីករាយក្រៃលែង យកមាន់នោះទៅចំអិនធ្វើម្ហូប រួចដួសដាក់ចាន ដាក់ថាសលើកយកមកបម្រុងនឹងអាស្រ័យ ។ ប៉ុន្តែនៅពេលនោះ ប្ដីសក៏និយាយទៅកាន់ប្រពន្ធថា:

"យើងជិតបានម្ហូបពាក់ហើយ ដូច្នេះ ត្រូវយើងយកម្ហូបវិសេសនេះទៅឯមាត់ស្ទឹង យើងមុជទឹកដុសខ្លួនឲ្យស្អាត យកសំលៀកបំពាក់ថ្មី ១ មកស្លៀកពាក់ហ៊ុំហា រួចសឹមយើងចាប់ញុំាម្ហូបមាន់នេះ ។

ប្ដីប្រពន្ធក៏ដឹកនាំម្ហូបអាហារទៅដាក់មាត់ទឹក រួចមុជទឹកក្នុងស្ទឹងលេងយ៉ាងសប្បាយ លុះងើបពីទឹកឡើងប្ដីប្រពន្ធរកមើលថាស

ដាក់ម្ហូបពុំឃើញ ។ ទឹករលកបានគួចយកថាសនោះរសាត់ទៅតាមខ្សែទឹកបាត់ទៅ ។

នៅថ្ងៃនោះ មានទ្រមាក់ដំរីម្នាក់ឈ្មោះតា គាត់បាននាំដំរីគាត់ជាច្រើនទៅចុះត្រាំទឹកស្ទឹងនោះ បានឃើញថាសនោះអណ្តែតមករកគាត់ៗ លើកយកថាសនោះទៅបង្ហាញព្រះសង្ឃជាមេកុដិមួយអង្គ ។ លោកសង្ឃបានស្គាល់ច្បាស់នូវគុណភាពនៃសាប់នោះ ក៏ចាប់យកក្បាលមាន់ធាន់ទៅរូបលោកប្រទានសាប់ទ្រង់ទៅឈ្មោះតា សាប់ក្បៅទៅនាង វង់ ប្រពន្ធឈ្មោះតា ប៉ុន្តែលោកឥតមានពុទ្ធដីកាថាដូចម្តេចឡើយ ។ តា និងនាងវង់ ក៏បបួលគ្នាត្រឡប់ទៅផ្ទះវិញទៅ ។

និយាយពីបុរសប្តីប្រពន្ធ គាត់បានចំដើររកថាសម្ហូបនោះគ្រប់កន្លែងអស់ ប៉ុន្តែពុំឃើញ គិតថាប្រាកដជានរណាមកលួចយករបស់គាត់ហើយ ក៏ប្រទេចផ្តាសាជនពុំស្គាល់មុខនោះជាច្រើនកប់ពុំអស់ ។

បន្ទាប់ពីនោះមកបីថ្ងៃ, នៅក្នុងនគរក៏មានការប្រជុំគណៈរដ្ឋមន្ត្រី ។ នៅក្នុងសម័យប្រជុំនោះ រដ្ឋមន្ត្រីទាំងឡាយក៏ប្ញរយោបល់គ្នាថា: "ព្រះរាជាណាចក្រយើង ពុំទាន់មានព្រះមហាក្សត្រគ្រងរាជ្យនៅឡើយ ។ ដូច្នេះ, ត្រូវបញ្ចេញដំរីមកបង្កូប ហើយបួងសួងដល់ទេវតា សូមឲ្យដំរីទាំងឡាយចេញទៅលុតជង្គង់ដោយខ្លួនឯង នៅមុខជនណាមួយដែល

អាចអង្គុយលើកដបល័ង្កបាន ហើយសូមឲ្យដំរីលើកបុរសនោះដាក់លើក្បាល នាំមកទីនេះ ដើម្បីយើងនឹងរៀបធ្វើបុណ្យអភិសេក ឲ្យបុរសនោះឡើងសោយរាជ្យក្នុងព្រះនគរ ។

គេក៏យកដំរីមករៀបចំចងកូប និងគ្រឿងលំអឯទៀតជាច្រើនស្តោកស្តះ ហើយលែងឲ្យវាដើរទៅតាមចិត្តវា ។ ដំរីក៏ដើរសំដៅទៅរកតា នឹងនានវង, ហើយលុតជង្គង់នៅមុខជនទាំងពីរ រួចវាលើកជនទាំងពីរនោះដាក់លើក្បាល បញ្ជូនមកកាន់ព្រះបរមរាជវាំង ។ គណៈនោះរដ្ឋមន្ត្រីក៏រៀបចំធ្វើបុណ្យរាជាភិសេកក្រាមតាមប្រពៃណី ។ បុរសតាក៏បានទទួលព្រះបរមនាមថាជា ទេវង់អស្ចារ្យ ។

ក្រុង-ហ៊ូវ នឹងក្រាយ ហ៊ូវ មានសេចក្តីអាក់អន់ព្រះទ័យមិនព្រមចំណុះចូលនឹងមហាក្សត្រអង្គថ្មី ក៏រត់ទៅឯស្រុកបាកាន ខេត្តពោធិ៍សាត់ ហើយទ្រង់បានសង់ប្រាសាទមួយនៅទីនោះ ។

ដំណាលពីព្រះឥន្ទ្រាធិរាជ ទ្រង់សង្កេតឃើញព្រះអគ្គមហេសីនៃមហាក្សត្រអង្គថ្មី ពុំទាន់មានព្រះរាជបុត្រានៅឡើយ. ក៏ទ្រង់ព្រះចិន្តាថា:

"យើងនឹងផ្តល់ព្រះរាជបុត្រមួយអង្គដល់ព្រះនានវង ។ ព្រះរាជបុត្រនេះមានសញ្ជាតិជាព្រះឥន្ទ្រសុទ្ធ ដើម្បីឲ្យជាប់ជាព្រះញាតិវង្សសោយរាជ្យក្នុងប្រទេសខ្មែរជានិរន្តរ៍តទៅ ។

ថ្ងៃមួយ, នៅពេលដែលព្រះមហាក្សត្រិយានីវង់ ទ្រង់យាងចេញពីមហាប្រាសាទ, ព្រះឥន្ទ្រទ្រង់ហោះចេញមកនៅលើអាកាស ។ មនុស្សលោកមើលព្រះអង្គពុំឃើញទេ; ប៉ុន្តែ គេគ្រាន់តែឃើញពន្លឺមួយយ៉ាងធំទៀវសន្ធឹងកាត់អាកាស ។ អ្នកស្រុកស្រែកនោទ្យេឡើងថា "ពន្លឺធ្លាក់! ពន្លឺធ្លាក់! ព្រះឥន្ទ្រក៏ទម្លាក់កម្រងផ្កាមកលើព្រះកាយព្រះនាងវង់, ហើយទ្រង់ហោះត្រឡប់ទៅនគរព្រះអង្គវិញបាត់ទៅ ។

ព្រះនាងអគ្គមហេសីវង់ ទ្រង់មានព្រះគភ៌ពីត្រឹមពេលនោះមក ហើយទ្រង់ប្រសូតព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាម "ព្រះកោតុមាលា" មានន័យថា ពន្លឺផ្កា ។

សូមដំណាលពីព្រះពិស្ណុការវិញ, អ្នកចំរើនរកម្ដាយគ្រប់ប្រកល្ហកអស់ហើយ, ប៉ុន្តែឥតបានដឹងថាម្ដាយទៅឯណា ។ កុមារក៏កើតទុក្ខរកទីបំផុតគ្មាន ទើបថ្ងៃមួយសួរឪពុកថា:

"តើនរណាមួយជាម្ដាយខ្ញុំ ?

–ម្ដាយកូនឯងជាទេពធីតា គាត់ត្រូវមករស់នៅក្នុងស្ថានមនុស្សយើងនេះតែត្រឹម ៦ ឆ្នាំទេ, ឥឡូវគាត់ត្រឡប់ទៅស្ថានទេវតាវិញហើយ ។ ស្ថាននោះនៅឆ្ងាយណាស់, ឪពុកពុំដឹងជាម្ដាយឯងនៅត្រង់ណាទេ !" ។

កុមារនៅស្ងៀម; ប៉ុន្តែចេះតែនឹកទៅរកម្ដាយឥតមានភ្លេច ក៏សម្រេច

ចិត្តថានឹងចេញទៅរកម្តាយឲ្យទាល់តែឃើញ ទោះជួបការលំបាកយ៉ាងណា, ក៏កុមារពុំយល់ស្របតាមជាដាច់ខាត ៗ ព្រះពិស្ណុការកុមារបានធ្វើដំណើរចេញទៅ, ដើរកាត់ព្រៃចូលវាល, លេចវាលចូលព្រៃ, ពេលឃ្លានបេះផ្លែឈើជាតិនានាធ្វើជាអាហារ, សំលៀកបំពាក់រហែករយ៉ីរយ៉ៃអស់ ៗ ប៉ុន្តែដោយហេតុតែកុមារមានវាសនាល្អ, ថ្ងៃមួយ ពួកទេពធីតាបានចុះមកលេងនៅលើភ្នំមួយ ហើយបណ្តាទេពធីតាទាំងនោះ, ព្រះនាងទិពសុគាចន្ទ ក៏បានមកលេងនៅទីនោះនឹងគេដែរ ៗ នាងកំពុងដើរកាច់ផ្កាតាមដងព្រៃចង់ជាបាច់ ៗ ព្រះពិស្ណុការបានឃើញស្ត្រីយ៉ាងល្អដូច្នោះក៏នឹកថា:

"អស់ពេលជាច្រើនឆ្នាំណាស់មក ហើយ ដែលអញដើរចេញពីទីភូមិដែលមានមនុស្សលោកនៅ, អស់ពេលជាច្រើនឆ្នាំណាស់មកហើយដែលអញឥតដែលបានជួបមនុស្សលោកណាម្នាក់សោះ សំលៀកបំពាក់អញក៏រហែកដាច់ដាច, ហើយអញពុំអាចរកអ្វីមកផ្លាស់បានទេក្រៅពីយកស្លឹកឈើមកចងបិទបាំងខ្លួន ដូច្នេះ, មនុស្សស្រីទាំងឡាយដ៏ល្អក្រៃលែងនេះ មកពីទីស្ថានណា? មិនមែនជាពួកទេពធីតាទេឬ?» ៗ

(នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

### ពិធីអនុសំវច្ឆរៈមហាសន្និបាត
### នៃមន្ត្រីសង្ឃលើកទី ១៧

ពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី១៧ បានចាប់ធ្វើឡើងនៅថ្ងៃទី ១មករា ឆ្នាំ ១៩៦១ ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ គឺនៅវត្តឧណ្ណាលោម និងវត្តបទុមវតីរាជវរារាម ។

ពីម៉ោង ១៤ ទៅម៉ោង ១៥ នៃថ្ងៃនោះ ជាពេលបើកឱកាសធ្វើមហាសន្និបាតនៃមន្ត្រីសង្ឃនេះ លោក សរ-គឹមក្វយ អនុរដ្ឋលេខាធិការក្រសួងធម្មការ ដោយមានសហការីរបស់លោក ជូនដំណើរអមផង បានអញ្ជើញទៅកាន់វត្តឧណ្ណាលោម និងវត្តបទុមវតីរាជវរារាម ដើម្បីបើកសម័យធ្វើមហាសន្និបាត ។

នៅព្រឹកថ្ងៃ ទី ២ មករា, វេលាម៉ោង ៧ និង ៣០នាទី មាននិមន្តព្រះសង្ឃទាំង ២ គណៈ ចំនួន ៣០ អង្គ សូធ្យាយព្រះសត្តប្បករណាភិធម្ម ឧទ្ទិសព្រះរាជកុសលថ្វាយចំពោះព្រះបិតរ នៅព្រះចេតិយទាំងគូខាងមុខព្រះវិហារព្រះកែវមរកត ។ លុះដល់ម៉ោង ១០ និង ៣០ នាទី, ព្រះសង្ឃទាំង ២ គណៈ [illegible] គឺនៅវត្តឧណ្ណាលោម និងនៅវត្តបទុមវតី ចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ។

ក្នុងថ្ងៃទី ២ មករាដដែល វេលាម៉ោង ១៦ នឹង ៣០ នាទី ក្រសួងធម្មការ បានបើកធ្វើពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៧ នៅក្នុងវិហារនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។

ពេលបើកពិធីនេះ គេសង្កេតឃើញព្រះរាជាគណៈឋានានុក្រម មេគណ, អនុគណ, ចៅអធិការ នឹងភិក្ខុ-សាមណេរទាំងឡាយ ទាំងពីរគណៈ ដែលគង់នៅវត្តនានាក្នុងព្រះរាជធានី នឹងមកពីខេត្តក្រៅជាច្រើនរយអង្គ បាននិមន្តមកកាន់មហាសន្និបាត មីរដេរដាសពាសពេញបរិវេណនៃពុទ្ធិ-កវិទ្យាល័យព្រះសុរាម្រឹត ប្រកបដោយរបៀបរៀបរយ សមរម្យទៅតាមសមណសារូប ដើម្បីចង់ឃើញព្រះភក្ត្រសម្តេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គទើបតែនឹងទ្រង់ព្រះនិវត្តន៍អំពីបរទេស មកកាន់មាតុប្រទេសវិញ; ជាពិសេស គឺសំដែងនូវសេចក្តីនឹករលឹកចំពោះព្រះអង្គ ។ មានឥស្សរសមណៈ នឹងឥស្សរជនជាច្រើនបាននិមន្ត បានអញ្ជើញមកក្នុងពិធីនេះ ។

ផ្នែកឥស្សរសមណៈខាងបព្វជិតគឺ: សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ដែលមានព្រះពោធិវង្ស ហួត-តាត, ព្រះវនរតន៍ ប៊ុវ-ខួត, ព្រះធម្មលិខិត ម៉ុង-សេស, ព្រះមង្គលទេពាចារ្យ ព្រះពុទ្ធាចារ្យ ,

ព្រះមហាព្រហ្មមុនី ទេព-អ៊ូ, ព្រះធម្មុត្តម, ព្រះអរិយកស្សប និងព្រះរាជា-
គណៈ ឋានានុក្រមជាច្រើនអង្គទៀត និមន្តអមផងបាននិមន្តមកជាប្រធាន
ក្នុងឱកាសនោះ ។

ផ្នែកឥស្សរជនខាងគ្រហស្ថ គេសង្កេតឃើញលោក ជួប-ហែល
ប្រធានរដ្ឋសភា ព្រមទាំងសមាជិកសភាទាំងពីរ, ឯកឧត្តម ជូ-ព្រឿង
នាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងធម្មការ, ឯកឧត្តម ទេព-ផន ឧបនា-
យករដ្ឋមន្ត្រី, ឧត្តមសេនី លន់-ណុល, សហជីវិន គូ-រុន, សហជីវិន ជា-
ជិនកុក ជាទេសរដ្ឋមន្ត្រី, ព្រមទាំងសមាជិករាជរដ្ឋាភិបាលជាច្រើនទៀត,
ដែលយើងសូមអភ័យទោស ដោយពុំបានកប់នាមឲ្យសព្វគ្រប់, លោក
ឧកញ៉ាមហាមន្ត្រី ឆេង-ហាក់ នាយកក្រុមព្រះរាជមន្ទីរ, លោកក្លួង-សន
នាយកការិយាល័យ លោក លឹម-ឆ្នួនសេង នាយខុទ្ទកាល័យ ក្រសួង
ធម្មការ ព្រមទាំងបុគ្គលិកក្រសួងនេះ និងពុទ្ធបរិស័ទជាច្រើនទៀត បាន
យាង បានអញ្ជើញទៅរួបរួមក្នុងពិធីនោះផង ។

នៅវេលាម៉ោង ១៧ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើ
ត្បូង ជាព្រះមាតាជាតិ, សម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ, សម្ដេច
ក្រុមព្រះ ស៊ីសុវត្ថិ-មុនីរ៉េត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ដោយ
មានឯកឧត្តម សាន-យុន អគ្គនាយកក្រសួងនានាក្នុងព្រះបរមរាជវាំង ,

ឯកឧត្តម ពីទូដីម៉ុងតេរ៉ូ សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក,លោកអ៊ុង-ហ៊ុង-សាធ លេខាធិការផ្ទាល់នៃសម្តេចព្រះឧបយុវរាជ លោកយឹម-ត្រយ៉ង់ នាយខុទ្ទកាល័យមន្ទីរព្រះរាជាយុត្តកៈ, អ្នកអង្គម្ចាស់ស៊ីសុវត្ថិពង្សមុនី លេខាធិការផ្ទាល់នៃសម្តេចព្រះមហាក្សត្រិយានី, លោក វរសេនីទោ មាស-ហ៊ុល, លោកវរសេនីត្រី សរ-ហោ, លោកអនុសេនីឯក ផេង-គង់, លោក ប៊ូ-ហ៊ល ព្រះរាជង្គរក្ស, លោកឧកញ៉ាពិភ័ក្តិរាជាមៅ-ចយ ព្រមទាំងព្រះរាជបរិពារជាច្រើនទៀត ហែអមព្រះអង្គផង បានស្តេចយាងទៅកាន់កន្លែងប្រារព្ធពិធី ។ នៅពេលនោះ ក្រុមទាហានរក្សាព្រះអង្គនិងក្រុមភ្លេងព្រះរាជទ្រព្យបានធ្វើគារវកិច្ច និងបន្លឺបទចរយាត្រាថ្វាយជាព្រះរាជកិត្តិយស ។

ក្រោយដែលសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ទ្រង់ទទួលបដិសណ្ឋារកិច្ច អំពីឥស្សរជន និងយាងថ្វាយបង្គំព្រះសង្ឃរួចហើយ ក្រុមតន្ត្រីព្រះរាជទ្រព្យក៏បានបន្លឺបទនគររាជថ្វាយ ជាព្រះរាជកិត្តិយស ។

ឥស្សរជនទាំងឡាយ ដែលនៅរង់ចាំក្រាបថ្វាយបង្គំទទួល និងសំដែងសេចក្តីស្វាមីភក្តិចំពោះព្រះអង្គ ក៏បានដង្ហែព្រះរាជដំណើរចូលគង់ប្រថាប់នៅលើព្រះសុវណ្ណកោដ្ឋៈ នាយ៉ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

លំដាប់នោះ ឯកឧត្តម ផូ-ព្រឿង ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងធម្មការ ក៏បានឡើងថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះដ៏កល់លើត្បូង

សូមព្រះរាជទាន ក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត

សូមព្រះរាជទាន ក្រាបបង្គំទូលសម្តេចសហជីវិន ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា

សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងនូវអំណរព្រះករុណាធិគុណ ព្រមទាំងកតញ្ញូធម៌ដ៏ជ្រាលជ្រៅ ចំពោះសម្តេចទាំងពីរព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតីភាព និងជាព្រះរាជាធិបតីភាព ក្នុងព្រះពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី ១៧ សម្រាប់ឆ្នាំជូតទោស័កនេះ ដោយសោមនស្សចេតនាដ៏ក្រៃលែង ។

សូមទ្រង់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះវរោកាស លម្អងធូលីព្រះបាទ ប្រាស្រ័យជាមួយសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ និងព្រះថេរានុត្ថេរៈទាំងអស់ ដែលបាននិមន្តមកជួបជុំ ក្នុងមហាសន្និបាតនេះ ដើម្បីនឹងបានប្រគេនពត៌មានខ្លះអំពីកិច្ចការខាងព្រះពុទ្ធសាសនា និងខាងអាណាចក្រ ។

សូមថ្វាយបង្គំសម្តេចទាំងពីរព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈទាំងអស់ដោយគោរព ។

ខ្ញុំព្រះករុណា សូមថ្លែងនូវសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះសម្តេចនិងព្រះករុណាគ្រប់ព្រះអង្គ ដែលបាននិមន្តមកកាន់ទីប្រជុំនេះ ព្រោះការជួបជុំជាឱកាសមួយដ៏ប្រសើរ អាចនាំមកនូវសេចក្តីចំរើននិងសេចក្តីចំរើន ជូនជាតិ-សាសនា និងព្រះមហាក្សត្រ ។

សម្តេច!

ព្រះករុណាគ្រប់ព្រះអង្គ!

ដូចសម្តេចនិងព្រះករុណាគ្រប់ព្រះអង្គ បានជ្រាបច្បាស់ហើយថា ប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាននេះ ទុកជាភ័ព្វមួយដ៏ប្រសើរក្រៃលែង ព្រោះព្រះពុទ្ធជាព្រះបរមគ្រូ ព្រះអង្គបានដកព្រះទ័យចេញផុតពីកាមារម្មណ៍គ្រប់យ៉ាង ហើយព្រះអង្គពេញព្រះទ័យចំពោះសន្តិភាពយ៉ាងក្រៃលែង អាស្រ័យហេតុដូច្នេះហើយ ទើបព្រះអង្គទ្រង់ប្រដៅពុទ្ធបរិស័ទឲ្យលះបង់អាឃាត ព្យាបាទជីវិតគ្នាទៅវិញទៅមក រហូតដល់បាណកសត្វ គឺសត្វល្អិតតូចតាច ក៏ទ្រង់ហាមមិនឲ្យសម្លាប់ដែរ ។

ខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមយ៉ាងមាំលើព្រះសង្ឃ ដែលជាសិស្សផ្ទាល់នៃព្រះពុទ្ធជាងគ្រហស្ថ: នឹងប្រកាន់សេចក្តីប្រតិបត្តិខាង

សន្តិភាព តាមគម្រោយនៃព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាយផ្លូវទុកឲ្យដើរ ពួកពុទ្ធសាសនិកជនទាំងអស់ក្នុងសាកលលោក ទោះបីជាតិខ្មែរក្តី ជាតិបរទេសក្តី ដែលមានសទ្ធាជឿជាក់ចំពោះព្រះពុទ្ធសាសនាមែនៗ បានបង្កើតសមាគមពុទ្ធសាសនាច្រើនប្រទេស ដើម្បីធ្វើការទាក់ទងគ្នាប្រាថ្នាចំពោះតែសន្តិភាពម្យ៉ាង ។

លទ្ធផលដ៏ប្រសើរនេះហើយ ដែលមានកិត្តិស័ព្ទ ផ្សាយទូទៅពេញសាកលលោកថា ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យដើរឆ្ពោះទៅរកសេចក្តីស្ងប់ គឺសន្តិភាព ។

សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋនិងជាព្រះអគ្គមគ្គុទ្ទេសក៍ ប្រទេសកម្ពុជាសព្វថ្ងៃនេះ ព្រះអង្គទ្រង់មានព្រះរាជហឫទ័យស្នេហាសន្តិភាពជាទីបំផុត រហូតដល់សាកលលោកទាំងមូល បានទទួលស្គាល់ច្បាស់ថាព្រះអង្គជាព្រះវីរបុរសមួយរូប ស្នេហាសន្តិភាពដោយពិត ដូចជានៅប្រទេសម៉ុងហ្គោលីក្នុងពេលថ្មីៗនេះ ក្រុមជំនុំសង្ឃ ដែលមានព្រះសង្ឃនាយកគេជាប្រធាន បានជំនុំថ្វាយព្រះបរមនាមដល់ព្រះអង្គថា ព្រះមហាបដិបបុរស មួយរូប សម្រាប់បំភ្លឺសាកលលោកឲ្យឃើញច្បាស់ នូវលទ្ធផលនៃសន្តិភាព ។

ព្រះតេជព្រះគុណ ក៏បានជ្រាបច្បាស់អំពីព្រះកិត្តិនាមរបស់ព្រះអង្គ

សព្វគ្រប់ហើយ; ខ្ញុំព្រះករុណាពុំអាចទូលពុទ្ធដីកាឲ្យវែងឆ្ងាយទេ ដ្បិតសន្តិភាពនេះជាគំពូលនយោបាយគ្រប់ប្រទេសទាំងអស់ មានអានុភាពទ្រទ្រង់ជីវភាពប្រជាពលរដ្ឋផង ទ្រទ្រង់ឯករាជ្យជាតិផង ឲ្យមានដំហរវឹងប៉ុនយ៉ាងជាក់ស្តែង; ព្រោះថា អ្នកស្រុកប្រកបអាជីវកម្មបានដោយស្រួលអាស្រ័យមកពីស្រុកសាន្តត្រាណ កាលៈបើអ្នកស្រុកប្រកបការងារបានពេញលេញហើយ ជាគុណធម៌អាចទ្រទ្រង់នូវឯករាជ្យជាតិឲ្យមានលក្ខណៈពេញបរិបូណ៌; កាលបើឯករាជ្យពេញបរិបូណ៌ហើយ ព្រះពុទ្ធសាសនាក៏រុងរឿងដែរ ។ អាស្រ័យហេតុនេះហើយ បានជាសម្តេចព្រះប្រមុខរដ្ឋយើង ព្រះអង្គខំបំពេញព្រះវិរិយភាពស្ទើរគ្រប់ប្រទេស ឲ្យគេទទួលស្គាល់សន្តិភាព តាមព្រះយោបល់ព្រះអង្គ ដើម្បីសេចក្តីសុខ-ចំរើននៃសាកល-លោក ព្រមទាំងធ្វើឲ្យសាកលលោក ស្គាល់នូវគុណានុភាពនៃប្រទេសខ្មែរកាន់តែជាក់ស្តែងឡើងថែមទៀត ។

ខ្ញុំព្រះករុណា ក្នុងឋានៈជាពលរដ្ឋខ្មែរមួយរូប ដែលមានបំណងចង់ឲ្យជាតិ -សាសនា- នឹងព្រះមហាក្សត្រ ពោលគឺប្រជាជាតិ បានស្គាល់នូវវឌ្ឍនភាពគ្រប់គ្រាន់ ឲ្យបានទទួលនូវសេចក្តីចុំចើនរុងរឿង សមនឹងឋានៈជាប្រទេសឯករាជ្យអព្យាក្រិតភាព ។ សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គ មេត្តាជួយណែនាំព្រះសង្ឃគ្រប់វត្ត ឲ្យមានព្រះទ័យស្ងប់ស្ងាត់

តាមព្រះមាគ៌ានយោបាយនៃសម្តេចព្រះប្រមុខរដ្ឋយើង ។ ទូលព្រះបង្គំជាខ្ញុំ.ខ្ញុំព្រះករុណា បានសង្កេតឃើញព្រះថេរានុត្ថេរៈទាំងឡាយ ក្នុងប្រទេសក្តី ក្រៅប្រទេសក្តី ដែលបានចេញទៅបន្តវិជ្ជានៅបរទេសទាំងប៉ុន្មាន សឹងបានជ្រាបច្បាស់នូវគោលការណ៍ទាំងឡាយ ដែលខ្ញុំព្រះករុណាបានទូលមកដោយស្រួស ៗ នេះជាស្រាកដថា ព្រះពជនយោបាយដំផ្តើមរបស់ព្រះប្រមុខរដ្ឋយើង មានអព្យាក្រិតភាពជាមាគ៌ានយោបាយរបស់ប្រទេស ព្រោះអព្យាក្រិតនេះជួយទ្រទ្រង់សន្តិភាពឲ្យបានគង់វង់ ។ ដោយហេតុនេះហើយ បានជាពុទ្ធចក្រនឹងអាណាចក្រក្នុងប្រទេសយើង ត្រូវតែមានការប្រាស្រ័យទាក់ទងគ្នាជាដរាប ទើបអាចនឹងបំពេញមុខការ ព្រមទាំងប្រយោជន៍ផ្សេង ៗ ដល់គ្នានឹងគ្នាទៅវិញទៅមកបាន ។

ជាទីបំផុត ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ សូមប្រសិទ្ធិពរបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងទេវតាទាំងមួយម៉ឺនលោក. ធាតុ ជួយទ្រទ្រង់ព្រះពុទ្ធសាសនា នឹងសម្តេចទាំងពីរព្រះអង្គ សូមព្រះអង្គបានប្រកបដោយបរមសុខ ព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋគ្រប់ប្រភេទតទៅ ។

សូមព្រះពុទ្ធសាសនា រុងរឿងចំរើនឡើងជាលំដាប់, សូមសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ នឹងព្រះថេរានុត្ថេរៈទាំងអស់ ព្រមទាំង

អស់លោកមន្ត្រីគ្រប់តំណែង នឹងប្រជាពលរដ្ឋទូទៅបានប្រកបដោយសេចក្តីសុខតាំងទៅក្នុងសាមគ្គីភាព ពួតដៃគ្នាកសាងប្រទេសជាតិ ឲ្យបានជាការប្រទេសមួយក្នុងសាកលលោក ដោយផ្អែកតាមព្រះមាគ៌ានយោបាយសម្តេចព្រះប្រមុខរដ្ឋតទៅ ។

× ×

×

លុះចប់សុន្ទរកថានៃឯកឧត្តម ជូ-ប៊ៀង នាយករដ្ឋមន្ត្រី នឹងជារដ្ឋ-មន្ត្រីក្រសួងធម្មការហើយ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សា ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ជាតំណាងនៃមន្ត្រីសង្ឃទាំងអស់ បានថ្លែងនូវសុន្ទរកថាមួយ ដូចតទៅនេះ៖

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត

សូមថ្វាយព្រះពរ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈក្នុងខេត្តក្រៅនឹងក្នុងរាជធានី ដែលឋិតនៅក្រោមឱវាទនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ហើយដែលបាននិមន្តមកជួបជុំក្នុងមហាសន្និបាតនេះ អាត្មាភាពសូមថ្វាយព្រះពរ ថ្លែងនូវអំណរព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ចំពោះសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជា

ព្រះរាជាធិបតីក្នុងពិធីអនុសំវច្ឆរមហាសន្និបាតទី ១៧ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ!

អម្បាញ់មិញនេះ, ឯកឧត្តមនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងធម្មការ បានថ្លែងសេចក្តីថ្វាយពត៌មានអំពីមហាសន្និបាតនេះ ដែលមានសេចក្តីទាក់ទងដល់គុណសម្បទនៃព្រះពុទ្ធសាសនា ដល់គណៈសង្ឃ និងដល់ប្រទេសកម្ពុជា រួចហើយ ។

ឥឡូវនេះ, អាត្មាភាពជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះរាជទានព្រះរាជឱកាស ដើម្បីថ្វាយពត៌មានខ្លះ អំពីសេចក្តីពេញចិត្តសេចក្តីរីករាយរបស់សង្ឃ ចំពោះភ័ព្វវាសនានៃប្រទេសកម្ពុជា និងព្រះពុទ្ធសាសនា ជាការឆ្លើយតបនឹងសេចក្តីថ្លែងនៃឯកឧត្តមទទួលបន្ទុកខាងក្រសួងធម្មការ ដូចមានតទៅនេះ ៖

ព្រះសង្ឃទាំងអស់បានដឹងច្បាស់លាស់ណាស់ថា ប្រទេសកម្ពុជាបានរួចផុតអំពីអំណាចនៃបរទេសហើយ បានទទួលឋានៈជាប្រទេសឯករាជ្យ អព្យាក្រឹត ដោយសារព្រះរាជសកម្មប្រយុទ្ធ ដ៏អង់អាចនៃសម្តេចព្រះប្រមុខរដ្ឋ ។ លុះបានដឹងដូច្នេះហើយ ក៏កើតមានចិត្តត្រេកអររីករាយយ៉ាងខ្លាំងក្លា ព្រមទាំងមានគារវកិច្ចប្រកបដោយកតញ្ញូតាធម៌យ៉ាងក្រៃលែង ចំពោះព្រះអង្គសម្តេចព្រះប្រមុខរដ្ឋជានិច្ចនិរន្តរ៍ ឥតមានអ៊ូនឹងមក

បំបាក់បំបែកបានឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះសង្ឃទាំងអស់ សឹងមានសេចក្តីសង្ឃឹមយ៉ាងកក់ក្តៅបំផុត ចំពោះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបច្ចុប្បន្នដែលមានព្រះអង្គសម្តេចព្រះប្រមុខរដ្ឋ ជាអគ្គមគ្គទេសក៍ថា នឹងជួយឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅមុខជាដរាប ។

ចំពោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា នាអតីតកាលដែលធ្លាប់បានទទួលសេចក្តីឧបត្ថម្ភគាំទ្រអំពីព្រះមហាក្សត្រិយ៍ ក្នុងបុរាណកាលនោះ អាត្មាភាពពុំចាំបាច់នាំយកមកថ្លែងក្នុងទីនេះឡើយ ដោយមានសិលាចារឹកបុរាណ ដែលទាក់ទងដល់ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានប្រាប់បញ្ជាក់ឲ្យច្បាស់លាស់ជាភស្តុតាងស្រាប់មកហើយ ។

រីឯក្នុងបច្ចុប្បន្នកាលនេះ ព្រះសង្ឃក្តី ប្រជាពលរដ្ឋជាពុទ្ធសាសនិកក្តី សុទ្ធសឹងតែបានឃើញច្បាស់នឹងចក្ខុ នូវព្រះពុទ្ធសាសនា ដែលបានទទួលព្រះបរមរាជូបត្ថម្ភ អំពីព្រះមហាក្សត្រិយ៍ជានិច្ចនិរន្តរ៍ ។ មានឧទាហរណ៍ដូចជាការសិក្សាខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជានេះ ដែលមាន ៣ ផ្នែកគឺ ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា នឹងពុទ្ធិកឧត្តមសិក្សា ព្រមទាំងការសិក្សាធម្មវិន័យ បានប្រព្រឹត្តទៅកាន់សេចក្តីចំរើន ដោយមានរបៀបរៀបរយល្អសព្វថ្ងៃនេះ គឺប្រាកដជាដោយសារព្រះករុណាធិគុណនៃព្រះមហាក្សត្រតាមលំដាប់កាល រៀងរហូតមកដល់

បច្ចុប្បន្នរដ្ឋកាលដែលមានសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ពុទ្ធិកសិក្សានេះ ព្រះសង្ឃទាំងអស់បានដឹងច្បាស់ថា ប្រសិនបើមិនមានព្រះមហាក្សត្រជាអគ្គពុទ្ធសាសនូបត្ថម្ភកទេ ប្រាកដជាពុំអាចនឹងកើតឡើងបាន ចំរើនឡើងបាន ដូចសព្វថ្ងៃនេះឡើយ ។

ក្រៅពីការសិក្សា មានកិច្ចការដទៃទៀត ដូចការគ្រប់គ្រងគណៈសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ឲ្យមានរបៀបរៀបរយ បានប្រព្រឹត្តទៅ ដោយសុខសន្តិភាព ក៏អាស្រ័យនឹងព្រះបរមរាជូបត្ថម្ភដែរ ។ ព្រះគុណរបស់ព្រះអង្គ ដែលជួយទ្រទ្រង់ឲ្យព្រះពុទ្ធសាសនាបានសុខ បានចំរើនលូតលាស់ មានពន្លឺរស្មីត្រចះក្នុងផ្លូវសិក្សា នឹងផ្លូវប្រតិបត្តិនេះ ជាព្រះគុណដ៏ខ្ពង់ខ្ពស់បំផុត ជ្រាលជ្រៅបំផុត ឥតមានព្រះសង្ឃរូបណាមួយបំភ្លេចបានឡើយ ។

សូមថ្វាយព្រះពរ!

អាត្មាភាពសូមថ្វាយសេចក្តីបញ្ជាក់ជាថ្មីម្តងទៀតថា ព្រះសង្ឃទាំងអស់ក្នុងប្រទេសកម្ពុជា តែងមានការយល់ឃើញថា ព្រះសង្ឃទុកដូចជាទាសនៃព្រះពុទ្ធ អាចរក្សាការពារព្រះពុទ្ធសាសនាដោយផ្ទាល់ ក្នុងផ្ទៃក្នុងបាន ប៉ុន្តែមិនអាចការពារសត្រូវខាងក្រៅ ដែលចូលមកប្រទុស្តបានឡើយ ឧទាហរណ៍ដូចប្រទេសឥណ្ឌាក្នុងសម័យបុរាណ ដែលជាកន្លែងប្រភពនៃ

ព្រះពុទ្ធសាសនា ។ នៅទីនោះ មិនយូរប៉ុន្មាន ព្រះពុទ្ធសាសនា ក៏ត្រូវ
រលាយរលុបអស់ ដោយហេតុមកពីឥតមានព្រះមហាក្សត្រជួយការពារ
ឥតមានរដ្ឋាភិបាលជួយគាំទ្រ ព្រះពុទ្ធសាសនាក៏ត្រូវរលាយដោយស្នាដៃ
នៃសត្រូវ មានឥស្លាមិកជនជាដើម ។

ព្រះពុទ្ធសាសនា ដែលផ្សាយចូលមកក្នុងប្រទេសកម្ពុជា តាំងពី
ក្រោយព្រះពុទ្ធទ្រង់ចូលបរិនិព្វានប្រមាណ ២៣៦ ឆ្នាំម៉្លេះ ក្នុងសម័យ
ដែលព្រះអរហន្ត ២ អង្គគឺ ព្រះសោណៈ នឹងព្រះឧត្តរៈមហាថេរជាសមណ
ទូតនាំមកផ្សាយ ក្នុងរជ្ជកាលនៃព្រះបាទធម្មាសោកមហារាជ ។ ព្រះពុទ្ធ
សាសនានេះ បានតម្កល់នៅក្នុងប្រទេសកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ
ដោយអាស្រ័យការឧបត្ថម្ភគាំពារនៃព្រះមហាក្សត្រក្នុងប្រទេសតៗមក ។

ដោយហេតុដូចខាងលើនេះ បានជាក្នុងបច្ចុប្បន្ននេះ ព្រះសង្ឃ
ទាំងអស់ តែងបានទទួលសេចក្ដីរីករាយសប្បាយ ចំពោះព្រះពុទ្ធសាសនា
ដែលមានទីពឹងពុំនាក់លើព្រះមហាក្សត្រិយ៍នឹងរាជរដ្ឋាភិបាល នឹងអាច
ជួយឧបត្ថម្ភឲ្យបានសុខចំរើន ជួយការពារមិនឲ្យរលាយរលត់បាត់បង់
ទៅបាន ។

សូមថ្វាយព្រះពរ !

ត្រង់ពាក្យថាព្រះពុទ្ធសាសនា បានសុខចំរើនដោយសារព្រះបរម-

កជួបត្ថម្ភនោះ ជាការជាក់ស្តែងណាស់ ព្រោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាបានទទួលការគោរពនិងភក្តីភាព អំពីព្រះមហាក្សត្រ អំពីឥស្សរជននិងអំពីប្រជាពលរដ្ឋទូទៅ ព្រមទាំងបានទទួលការឧបត្ថម្ភគ្រប់យ៉ាង នាំឲ្យព្រះពុទ្ធសាសនាបានលូតលាស់ចំរើនឡើងគ្រប់ផ្នែក រហូតដល់បានទទួលឋានៈជាសាសនារបស់រដ្ឋ ។

ត្រង់ពាក្យថាព្រះពុទ្ធសាសនា បានទទួលការឃុំគ្រងការពារនោះក៏ជាការជាក់ស្តែងណាស់ ព្រោះព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា មានចែងទុកក្នុងច្បាប់ថា អ្នកណាបៀតបៀន ឬប្រមាថមើលងាយពុំបាន ។ល។

មិនត្រឹមតែប៉ុណ្ណោះឡើយ ព្រះសង្ឃទាំងអស់ក្នុងប្រទេស ដែលជាកូនចៅរបស់ប្រជាពលរដ្ឋគ្រប់ប្រភេទ ដែលបានបួសក្នុងព្រះពុទ្ធសាស-នា បានឈ្មោះថាភិក្ខុ ថាសាមណេរ ឬសមណៈ ឬក៏ហៅថាព្រះសង្ឃ ។ នេះ ក៏បានទទួលសេចក្តីគោរពរាប់អាន នឹងការជួយឧបត្ថម្ភគាំទ្រឲ្យបានសុខស្រួល និងសេចក្តីចំរុងចំរើនដែរ ។

ដោយហេតុនេះហើយ បានជាព្រះសង្ឃទាំងអស់ តែងមានគារវភក្តីយ៉ាងខ្លាំងក្លាប្រកបដោយកតញ្ញូតាដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាធិគុណនៃសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះប្រមុខរដ្ឋឥតមានអ្វីនឹងមកធ្វើឲ្យរលាយរលត់បានឡើយ ។

នៅអវសាននេះ អាត្មាភាពក្នុងនាមនៃព្រះសង្ឃទាំងអស់ សូមថ្វាយនូវព្រះពរបវរសួស្តី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះសម្តេចព្រះមហាក្សត្រិយានី ចំពោះសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះជន្មវស្សាយឺនយូរ មានព្រះសុខភាពបរិបូរ ឈ្នះមារសត្រូវគ្រប់ទិសទី កុំបីឃ្លៀងឃ្លាតឡើយ ។

×

× ×

តមក ព្រះសង្ឃបានសូត្រជយន្តោ ថ្វាយព្រះពរជ័យ ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។ មួយរំពេចនោះ សម្តេចព្រះប្រមុខរដ្ឋជាទីគោរពទីងជាទីស្នេហារបស់ពលរដ្ឋខ្មែរ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យថ្លែងព្រះសុន្ទរកថាមួយយ៉ាងវែង ប្រកបដោយអត្ថន័យដ៏សំខាន់ៗ ជាទីបំផុត ។ ជាពិសេស គឺព្រះអង្គបានផ្តាំផ្ញើចំពោះព្រះសង្ឃ ដែលលោកមានព្រះនេត្រទិព្វ ព្រះសោតទិព្វ សុំជួយពង្រីកផែនការ ៤ ឆ្នាំ សុំឲ្យជួយពន្យល់ណែនាំទាយកទាយិកាឲ្យយល់ច្បាស់ អំពីប្រយោជន៍ព្រៃព្រឹក្សា គឺសុំឲ្យជួយហាមប្រាមកូនចៅ កុំឲ្យដុតព្រៃដែលបណ្តាលឲ្យឆាបឆេះដល់ឈើល្អៗ, ទីងសុំហាមកុំឲ្យចាប់ត្រីនៅខែណាដែលវាកំពុងពងកំពុងកូន, ព្រោះឈើព្រៃ ទីងត្រីនេះហើយដែលជាផ្ទើមប្រមាត់របស់សេដ្ឋកិច្ចជាតិ ។ល។ ព្រះរាជបន្ទូលមានសេចក្តីទូលំទូលាយ

ណាស់ ហើយសុទ្ធតែសំខាន់ ៗ បំផុត យើងមិនអាននឹងរៀបរាប់ឲ្យចប់សព្វគ្រប់បាន ។

ពិធីអនុសំវច្ឆរមហាសន្និបាតនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង២២ នៃរាត្រី ។ នៅពេលនោះ សម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូង, សម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់បានស្ដេចយាងនិវត្ត ចូលកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារផ្ដាល់ព្រះអង្គតាមហែ និងក្រុមក្មេងព្រះរាជទ្រព្យ ធ្វើគារវកិច្ច ដូចកាលព្រះអង្គយាងមកដល់ ។

# ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ
# នៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រិត ព្រះចៅប្រទេសកម្ពុជា ជាទីស្នេហា និងជាទីគោរពដ៏ខ្ពង់ខ្ពស់នៃប្រជាជាតិខ្មែរ ព្រះអង្គសោយព្រះទិវង្គត នៅថ្ងៃអាទិត្យទី៣ ខែមេសា គ.ស.១៩៦០, វេលាម៉ោង១២ និង៤៥នាទី ក្នុងព្រះជន្មវស្សាគំរប់៦៦ឆ្នាំ ។ ព្រះរាជរដ្ឋាភិបាលបានថ្វាយព្រះមរណនាមថា "ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ" ។

ប្រជាជាតិខ្មែរ ដោយមានសម្តេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ សម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ ជាព្រះប្រមុខរដ្ឋ ព្រមទាំងព្រះរាជរដ្ឋាភិបាល បានតម្កល់ព្រះបរមសពរបស់ព្រះអង្គ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងព្រះបរមរាជវាំង អស់រយៈកាល៤ខែ ១៧ថ្ងៃ ។

លុះមកដល់ថ្ងៃទី២០ ខែសីហា ព.ស. ២៥០៣ គ.ស ១៩៦០ ទើបរៀបចំធ្វើព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូង ។ ព្រះរាជពិធីនេះ បានប្រព្រឹត្តទៅដ៏មហោឡារិកអធិកអធមមហិមា អស់រយៈកាល ៧ យប់ ៧ ថ្ងៃ ទើបហើយស្រេច ។

លុះសម្រេចព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពហើយ បានតម្កល់

ព្រះបរមអដ្ឋិ នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ អស់រយៈវេលា ៤ ខែ ១៥ ថ្ងៃ គឺរហូតមកដល់ខែមករា ១៩៦១ ទើបធ្វើព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិក្នុងព្រះចេតិយ នាបរិវេណនៃព្រះវិហារព្រះកែវមរកត ។

ដោយក្រុមពុទ្ធសាសនបណ្ឌិត្យ មានចិត្តក្រៀមក្រំសោកស្ដាយអាឡោះអាល័យព្រះអង្គក្រៃពេក នឹងមានចិត្តកតញ្ញូចំពោះព្រះករុណាធិគុណដ៏ខ្ពង់ខ្ពស់នៃព្រះអង្គ ព្រោះព្រះអង្គជាព្រះមហាក្សត្រដ៏ប្រកបដោយគតិបណ្ឌិតទ្រង់ទសពិធរាជធម៌ ជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់បានទំនុកបំរុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាទីផ្សាយក្បួនច្បាប់ ធម៌វិន័យ ពុទ្ធចក្រជាដើម ទើបបាននិពន្ធអត្ថបទថ្លែងអំពីព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិនៃព្រះអង្គទុកជាទីរលឹកដោយគោរពតទៅ ។

ព្រះរាជពិធីនេះ ធ្វើអស់រយៈវេលា ៥ ថ្ងៃ៥ យប់ ដូចរៀបរាប់ដោយសង្ខេបតទៅនេះ ៖

ថ្ងៃទី១ (១១ មករា ១៩៦១) ជាថ្ងៃចូលព្រះរាជពិធី ដ៏ប្រកបដោយជោគជ័យមង្គល សិរីសួស្ដីមហាប្រសើរ ។ ក្នុងថ្ងៃនេះ វេលាម៉ោង ៩, ៣០ នាទី នៅព្រះទីនាំងទេវាវិនិច្ឆ័យ, សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង នឹងសម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ស្ដេចយាង ដោយមានព្រះរាជបរិពារផ្ដាល់ព្រះអង្គតាមហែផង បានស្ដេចយាង

អញ្ជើញមកដល់ ។ សម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋអញ្ជើញស្តេចយាង ព្រះកោដ្ឋព្រះបរមអដ្ឋិព្រះករុណា ព្រះមហាកាញ្ចនៈកោដ្ឋ ចេញពីហោព្រះអដ្ឋិទៅដំកល់នៅលើព្រះមហាបុស្បុក នាមុខព្រះមហាស្វេតច្ឆត្រ និមន្តព្រះសង្ឃ៦៦ អង្គ ថ្វាយព្រះសត្តប្បករណាភិធម្ម ។

ថ្ងៃទី ២ (១២ មករា ១៩៦១) ជាថ្ងៃដង្ហែព្រះបរមអដ្ឋិ ចេញអំពីព្រះទីនាំងទេវាវិនិច្ឆ័យ ទៅតម្កល់ក្នុងមហាបុស្បុក នាព្រះវិហារព្រះកែវមរកត ។

ថ្ងៃដង្ហែនោះ វេលាម៉ោង ៦ ព្រឹក, នៅព្រះទីនាំងទេវាវិនិច្ឆ័យ មានការជួបជុំព្រះរាជវង្សានុវង្ស ក្សត្រី ក្សត្រា ជំទាវ ខុនណាង រដ្ឋមន្ត្រី រដ្ឋ-លេខាធិការ អនុរដ្ឋលេខាធិការ សមាជិកសភាទាំងពីរ នាហ្មឺនសព្វមុខ-មន្ត្រី ទាហាន ស៊ីវិល មន្ត្រីកិត្តិយសជាច្រើន ។

ម៉ោង ៦ និង ៣០ នាទី, អគ្គទូតនានា នឹងភរិយាអញ្ជើញមកដល់ ។

ម៉ោង ៦ និង ៤៥ នាទី សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ស្តេចយាងដល់ ដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង ។ ទ្រង់ស្តេចយាងដល់ភ្លាម ក្រោយអំពីការថ្វាយបង្គំហើយ លោកឧកញ៉ាមហាមន្ត្រី ឆេង - ហាក់ នាយកក្រុមព្រះរាជមន្ទីរទូលឆ្លង, រួចនិមន្តព្រះសង្ឃ ៦៦ អង្គថ្វាយព្រះ

សត្តប្បករណាភិធម្ម ។

លុះចប់ហើយ, ថ្វាយបង្គំព្រះបរមអដ្ឋិ ៣ ដង តាមសង្ឃាក់គង ១០ អន្ទង ។

សម្ដេចព្រះឧបយុវរាជ អញ្ជើញស្ដេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិ ចេញពីមហាបុស្សបុក ទៅតម្កល់លើព្រះលាលៀងកុង នៅកើយខាងមុខ ព្រះទីនាំងទេវាវិនិច្ឆ័យ ហើយដង្ហែទៅតម្កល់នៅលើព្រះរាជរថបុស្សបុក នាមុខព្រះបរមរាជវាំង ដោយសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត លើត្បូងស្ដេចយាងហែជាព្រះរាជាធិបតានីភាព ដែលមានព្រះរាជបរិពារ ទាំងទាហាន-ស៊ីវិល តាមហែព្រះអង្គផង ។

សូមជ្រាបថា ក្នុងព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិនេះ មានពិធីបញ្ចុះ ព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនរោត្តម - គន្ធបុប្ផា ជាព្រះរាជបុត្រីនៃសម្ដេច ព្រះនរោត្តម - សីហនុ ព្រះប្រមុខរដ្ឋផង ។ វេលាដង្ហែព្រះបរមអដ្ឋិ មានដង្ហែព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនោះក្នុងពេលជាមួយនោះដែរ ។

ចំណែកព្រះអដ្ឋិនៃព្រះអង្គម្ចាស់ក្សត្រីនរោត្តម គន្ធបុប្ផា ក៏បានតម្កល់ លើព្រះសាលៀងកុងមួយផ្សេង ដង្ហែពីខាងក្រោយព្រះបរមអដ្ឋិ ទៅ តម្កល់នៅលើព្រះរាជរថគ្រឿងជាន់មួយទៀត នៅខាងក្រោយព្រះរាជរថ បុស្សបុកតម្កល់ព្រះបរមអដ្ឋិ ។

ម៉ោង៧ ទឹង៣០នាទីក្បួនហែចេញ ។ បារគូថ្វាយស័ង្ខ ភ្លេងទាំងអស់ប្រគំថ្វាយ, ស្នកាំភ្លើងធំ ១០១ ណាត់ក៏បានបន្លឺឡើង ។ ក្បួនហែចេញទៅតាមមហាវិថីសុធារស,វិថីសម្តេចអ៊ុក,មហាវិថីព្រះបាទនពេត្តម, មហាវិថីព្រះបាទសុរាម្រឹត ទឹងមហាវិថីសុធារស ចូលវត្តព្រះកែវមរកត ដោយក្បួនហែជាសង្កាត់ ៗ យ៉ាងមហោឡារិក ដូចមានក្នុងកម្មវិធីក្បួនហែសព្វគ្រប់ស្រាប់ ។

ម៉ោង ៩,១៥ នាទី ក្បួនហែមកដល់, អញ្ជើញស្តេចយាងព្រះកោដ្ឋចុះពីព្រះទីនាំងបុស្សបុក ទៅតម្កល់នៅព្រះសាលៀងក្នុង រួចហែចូលទៅឈប់នៅមុខវិហារព្រះកែវមរកត ។ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះឧបយុវរាជ ស្តេចយាងហែ ដោយព្រះរាជបរិពារទាំងទាហាន ស៊ីវិលតាមហែផង ។ល។ លុះដល់យ៉ព្រះវិហារព្រះកែវមរកត សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់អញ្ជើញស្តេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិទៅតម្កល់លើមហាបុស្សបុក ក្នុងព្រះវិហារព្រះកែវមរកត ។

ក្នុងពេលជាមួយនោះ មានពិធីអញ្ជើញព្រះកោដ្ឋព្រះអដ្ឋិព្រះអង្គម្ចាស់ក្សត្រី នរោត្តម-គន្ធបុប្ផា ទៅតម្កល់លើព្រះសាលៀងក្នុង រួចហែចូលទៅឈប់នៅព្រះវិហារព្រះកែវមរកត អញ្ជើញស្តេចយាងទៅតម្កល់លើព្រះបញ្ចាត្ថុប ក្នុងព្រះវិហារនោះដែរ ។ បន្ទាប់មក និមន្តព្រះសង្ឃ ៦៦

អង្គថ្វាយព្រះសត្តប្បករណាភិធម្ម ហើយថ្វាយបង្គំព្រះបរមអដ្ឋិ ៣ ដង តាមសង្ឃាក់គង់ ។

ព្រះរាជពិធីក្បួនហោបានចប់សព្វគ្រប់នៅម៉ោង ១០ និង ៣០នាទី ។

ម៉ោង១៨ និង១៥នាទី ចូលព្រះរាជពិធីដោយហោរសូត្រប្រកាសទេវតា, អុជប្រទីបផ្កាលា តាមកំពែង ជុំវិញព្រះវិហារ និងតាមព្រះចេតិយ-ដ្ឋាន ព្រមទាំងតុដែលតាំងជាទីសក្ការបូជា ។ នៅអមមាត់ទ្វារខាងកើតគឺតុសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ, មាត់ទ្វារខាងត្បូងតុព្រះរាជាគ-ណៈ ទាំងពីរគណៈ, មាត់ទ្វារខាងជើងតុរបស់លោកសង្ឃខាងមហា-យាន និងគៅដាយ ។

ម៉ោង១៩ ជួបជុំព្រះរាជវង្សានុវង្សក្សត្រ ក្សត្រា ជីទាវ ខុនណាង រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សមាជិកសភាទាំងពីរ នាម៉ឺនសព្វមុខមន្ត្រី (ពាហាន - ស៊ីវិល) មន្ត្រីកិត្តិយស នៅក្នុងព្រះវិហារព្រះកែវមរកត ហើយនិមន្តព្រះសង្ឃ២២អង្គ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ចូលមកគង់លើអាសនៈ ដើម្បីចំរើនព្រះបរិត្ត ។

ម៉ោង១៩, ១០នាទី សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង ស្តេចយាងដល់ ទ្រង់ប្រារព្ធនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាន

និច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះបរិត្ត និងព្រះធម៌ទេសនាធម្មគារវ ហូត ដល់ម៉ោង ៦១-១០នាទី ទើបស្ដេចយាងត្រឡប់ចូលព្រះបរមរាជវាំង ។

ថ្ងៃទី៣ (១៣ មករា ១៩៦១) ថ្ងៃនេះ ម៉ោង ១០ ព្រឹក សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងចេញប្រថាប់នៅក្នុងព្រះវិហារព្រះកែវមរកត ។

ក្រោយពីសម្ដេចទាំងពីរព្រះអង្គទ្រង់ប្រារព្ធទៀនធូបនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាននិច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះសង្ឃ ១០០ អង្គ ថ្វាយព្រះសត្តប្បករណាភិធម្ម ទ្រង់ប្រារព្ធរាប់បាត្រ ហើយអាចារ្យវេរសង្ឃភត្ត ឧទ្ទិសព្រះរាជកុសល ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាការុញនគោដ្ឋ និងថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះអង្គម្ចាស់ក្សត្រីនរោត្ដម-គន្ធបុប្ផា ។ នៅពេលព្រះសង្ឃកំពុងធ្វើភត្តកិច្ច សម្ដេចទ្រង់សព្វព្រះរាជហឫ-ទ័យ ស្ដេចយាងទតផ្ទាល់ព្រះអង្គនិងទ្រង់ព្រះបញ្ជាឲ្យចាត់ចែងចង្ហាន់ ប្រគេនព្រះសង្ឃ ដោយទឹកព្រះទ័យជ្រះថ្លាមហាសាទ្រ ហូតដល់ម៉ោង១១,៤០ ទើបស្ដេចយាងចូលព្រះបរមរាជវាំងវិញ ។

នៅពេលល្ងាចនៃថ្ងៃនេះ ដូចល្ងាចថ្ងៃទី ២ ដែរ, ប៉ុន្តែថ្ងៃនេះ, មានសំដែងរឿងទេសជាតក៍ ។

ថ្ងៃទី៤ (១៤មករា ១៩៦១) ពេលព្រឹកថ្ងៃនេះ ដូចពេល

ព្រឹកថ្ងៃទី៣ ។ ពេលល្ងាចក៏ដូចជាពេលល្ងាចថ្ងៃទី៣ដែរ; ប៉ុន្តែថ្ងៃនេះមានសំដែងភ្លេងបឋមគ្រាស់ នឹងអភិសេកព្រះពុទ្ធរូប ។

ថ្ងៃទី៤ (១៤ មករា ១៩៦១) ថ្ងៃនេះជាថ្ងៃធ្វើព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ ។

ម៉ោង៩, ៣០នាទី ជួបជុំព្រះរាជវង្សានុវង្សដូចព្រឹកថ្ងៃទី២ ។

ម៉ោង៩, ៤៥នាទី អគ្គទូតនានាអញ្ជើញដល់ដូចថ្ងៃទី២ ។

ម៉ោង១០ សម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់យាងដល់ព្រះវិហារព្រះកែវមរកត; ហោរាសូត្រប្រកាសទេវតា បារគូថ្វាយស័ង្ខ-ភ្លេងពិណពាទ្យ រួចនិមន្តព្រះសង្ឃ ៦០ អង្គថ្វាយព្រះសត្តប្បករណាភិធម្ម ។ បន្ទាប់មកសម្តេចព្រះប្រមុខរដ្ឋ អញ្ជើញស្តេចយាងព្រះកោដ្ឋព្រះបរមអដ្ឋិ ហែចេញពីព្រះវិហារ ទៅប្រទក្សិណព្រះចេតិយ៣ជុំ ដោយមានព្រះរាជវង្សានុវង្ស អគ្គទូត ប្រជាទាសកាទាំងពីរ នឹងគណៈរដ្ឋមន្ត្រីតាមហែផង ។ លុះគ្រប់ ៣ ជុំហើយ សង្ឃការី១នាក់ និមន្តព្រះពុទ្ធរូបឡើងទៅតម្កល់លើកំពូលព្រះចេតិយ ។ ខណៈនោះ, សម្តេចព្រះប្រមុខរដ្ឋ អញ្ជើញស្តេចយាងព្រះបរមអដ្ឋិទៅបញ្ចុះក្នុងព្រះចេតិយ ដែលនៅពេលនោះ បារគូថ្វាយស័ង្ខ-ភ្លេងពិណពាទ្យ- ភ្លេងក្លងខែក - តន្ត្រីព្រះរាជទ្រព្យ នឹងក្រុមទាហានទាំងអស់គោរពយ៉ាងស្ងប់

សៀម ស្កូវកាំភ្លើងធំ ១០១ ណាត់ក៏បន្លឺឡើងព្រមនៅពេលជាមួយគ្នានោះ; ព្រះសង្ឃ៣០០អង្គថ្វាយជយន្តោ ។ លុះតម្កល់ព្រះបរមអដ្ឋិក្នុងព្រះចេតិយរួចហើយ មានពិធីថ្វាយបង្គំ៣ដងតាមចង្វាក់គង ។

បន្ទាប់មកសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ទ្រង់ព្រះកោដ្ឋព្រះអដ្ឋិព្រះអង្គម្ចាស់ក្សត្រីនរោត្តម- គន្ធបុប្ផា ហែប្រទក្សិណព្រះចេតិយដែលតាំងនៅខាងកើតព្រះចេតិយនៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ៣ ជុំ ដោយមានព្រះរាជវង្សានុវង្ស អគ្គទូត ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រីតាមហែ ។ លុះគ្រប់៣ជុំហើយ, សង្ឃការី១នាក់ និមន្តព្រះពុទ្ធរូបឡើងទៅតម្កល់លើកំពូលព្រះចេតិយ ។ ពេលនោះ, សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះកោដ្ឋព្រះអដ្ឋិទៅបញ្ចុះក្នុងព្រះចេតិយ, ក្រុមបារគូថ្វាយស័ង្ខ - ភ្លេងពិណពាទ្យ - ភ្លេងក្លងខែក តន្ត្រីព្រះរាជទ្រព្យ នឹងក្រុមទាហានទាំងអស់គោរព ។ ក្នុងពេលជាមួយគ្នានោះ, ព្រះសង្ឃ ៣០០ អង្គក៏ថ្វាយជយន្តោ ។

ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិក្នុងព្រឹកនេះ ចប់នៅម៉ោង ៧,៣០ រួចហើយ សម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងចូលព្រះរាជវាំងវិញ ។

នៅពេលម៉ោង ១០ ព្រឹកក៏មានព្រះរាជពិធីដូចថ្ងៃទី៣-៤ ដែរ ។

ម៉ោង១៦ បានជួបជុំព្រះរាជវង្សានុវង្ស ដូចពីពេលព្រឹក ។

ម៉ោង ១៧ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ស្ដេចយាងមកដល់ព្រះវិហារព្រះកែវមរកត ។ ក្រោយពីនោះ ទ្រង់ថ្វាយព្រះទៀនធូបនមស្ការព្រះរតនត្រ័យ ទ្រង់សមាទាននិច្ចសីល ទ្រង់ព្រះសណ្ដាប់ព្រះធម្មទេសនាត្រៃបី ៣ អង្គ អានត្រៃ៤អង្គ ហត្ថបាស ១០០ អង្គ នៅក្នុងព្រះវិហារព្រះកែវមរកត ។

បប់កិច្ចទេសនា សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ព្រះនិវត្តន៍ចូលព្រះបរមរាជវាំងវិញ ។

យើងសូមបញ្ជាក់ថា: ចាប់តាំងពីម៉ោង ២០ទៅ មានអុជគាំជ្រួចន្ទាភ្លើងទៀន, បញ្ចាំងភាពយន្ត ណាំងស្បែក ណាំងទ្រលុង នៅមុខព្រះបរម-រាជវាំង និងនៅវាលព្រះមេរុ រាល់យប់, ចំពោះយប់ទី ៣ ក្រុមល្ខោនព្រះរាជទ្រព្យ និងល្ខោនជាតិ សំដែងរឿងទសជាតក៍, យប់ទី ៤ រឿងពុទ្ធប្រវត្តិ នៅក្នុងវិហារព្រះកែវមរកត ។

ព្រះរាជពិធីបញ្ចុះព្រះបរមអដ្ឋិ បានបប់សព្វគ្រប់នៅវេលាម៉ោង ១ អធ្រាត្រនៃរាត្រីថ្ងៃទី ១៩ មករា ១៩៦១ ។

ពុទ្ធសាសនបណ្ឌិត្យ សូមឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធរបស់ព្រះតេជព្រះគុណព្រះសាសនមុនី មាស-កង សូមព្រះតេជព្រះគុណបានទទួលនូវសេចក្ដីសុខក្សេមក្សាន្ត ក្នុងសម្បត្តិមនុស្ស, សម្បត្តិទេព្តា ៗ ជាពិសេស នៅទីបំផុត, សូមព្រះតេជព្រះគុណបានដល់នូវឋានបរមសុខស្ងប់ គឺព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ ៗ

ពុទ្ធសាសនបណ្ឌិត្យ